ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលជលផល

# ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច ជលផលសមុទ្រ

# ឆ្នាំ ២០២០ - ២០២៤



## មាតិកា


អារម្ភកថា ................ iv
បញ្ជីតារាង ................ v
បញ្ជីរូបភាព ................ v
ពាក្យបំព្រួញ ................ vi
១. សេចក្តីផ្តើម ................ ១
១.១. ក្របខ័ណ្ឌគោលនយោបាយ ................ ១
១.២. គោលបំណង ................ ១
១.៣. គោលដៅ ................ ១
១.៤. វិសាលភាព ................ ១
១.៥. បរិបទសម្រាប់ការរៀបចំផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ................ ២
១.៦. ស្ថានភាពវិស័យជលផល ................ ៣
១.៧. ការពិពណ៌នាអំពីការនេសាទក្នុងដែនសមុទ្រ ................ ៤
១.៧.១. ឆ្នេរសមុទ្រនិងដែននេសាទសមុទ្រ ................ ៤
១.៧.២. វិធានការគ្រប់គ្រងជលផលសមុទ្រ ................ ៥
១.៧.៣. នាវានេសាទនិងការធ្វើនេសាទ ................ ៧
១.៧.៤. ការធ្វើនេសាទដោយនាវានេសាទបរទេស ................ ១០
១.៧.៥. កំពង់ផែនេសាទ ឬកន្លែងឡើងផលនេសាទ និងកន្លែងកែច្នៃផលនេសាទ ................ ១០
១.៨. ការធ្វើនេសាទរបស់នាវានេសាទកម្ពុជានៅក្រៅដែនយុត្តាធិការជាតិ ................ ១០
១.៩. ស្ថាប័នមានសមត្ថកិច្ច ................ ១០
១.៩.១. តួនាទីនិងភារកិច្ចស្ថាប័នមានសមត្ថកិច្ច ................ ១០
១.១០. ធនធានសម្រាប់ការត្រួតពិនិត្យជលផល ................ ១២
១.១០.១. ឧបករណ៍សម្ភារ ................ ១២
១.១០.២. ធនធានមនុស្ស ................ ១៣
១.១១. សកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច ................ ១៣
១.១២. ការវិភាគ SWOT នៃសកម្មភាពតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល ................ ១៣
១.១៣. បញ្ហាចម្បង ................ ១៤
១.១៤. សកម្មភាពចម្បងៗទាក់ទងនឹងផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ................ ១៥
១.១៤.១. ពង្រឹងការអនុវត្តច្បាប់ ................ ១៥
១.១៤.២. ការពង្រឹងសមត្ថភាពអង្គភាព ក្នុងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល ................ ១៦
១.១៤.៣. ការដោះស្រាយនូវការខ្វះខាតសម្ភារ ................ ១៦

២. យុទ្ធសាស្ត្រក្នុងការត្រួតពិនិត្យនិងអធិការកិច្ចជលផលក្នុងដែននេសាទសមុទ្រ........................ ១៦
២.១. ពង្រឹងការរៀបចំផ្នែករដ្ឋបាល.................................................................................. ១៧
២.១.១. បង្កើតការិយាល័យតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ដើម្បីអនុវត្តការត្រួតពិនិត្យ និងអធិការកិច្ច ..............................................................................១៧
២.១.២. បង្កើតក្រុមពិសេសដើម្បីបង្ក្រាបនិងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់...១៧
២.១.៣.បង្កើតក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត ..............................១៨
២.២. ការរៀបចំនិញសម្ភារសំខាន់ៗសម្រាប់ការត្រួតពិនិត្យនិងអធិការកិច្ច........................១៩
២.២.១. សម្ភារសំខាន់ៗសម្រាប់ការត្រួតពិនិត្យ ..................................................................១៩
២.២.២ សម្ភារសំខាន់ៗសម្រាប់ការឃ្លាំមើល......................................................................១៩
២.៣. ពង្រឹងការកត់ត្រា និងការផ្តល់លិខិតអនុញ្ញាត .........................................................២៤
២.៣.១. ចុះបញ្ជីនិងកត់ត្រានាវានេសាទដែលកំពុងធ្វើនេសាទក្នុងដែននេសាទសមុទ្រ ...........២៤
២.៣.២. ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ.................................................................២៤
២.៣.៣. ការផ្តល់សៀវភៅកត់ត្រាស្ថិតិសម្រាប់នាវានេសាទខ្នាតធំនិងខ្នាតមធ្យម..................២៥
២.៣.៤. ការស្រង់ស្ថិតិ ផែនេសាទ និងកន្លែងឡើងផលនេសាទសាធារណៈនិងឯកជនទាំងអស់ ២៥
២.៤. ពង្រឹងការអនុវត្តច្បាប់ចំពោះឧបករណ៍នេសាទ និងតំបន់ហាមឃាត់តាមរយៈការធ្វើអធិការកិច្ច និងការផាកពិន័យ ..............................................................................................២៦
២.៤.១. ការអនុវត្តយុទ្ធសាស្ត្រ ការអប់រំតាមរយៈការពិន័យ.....................................................២៦
២.៤.២. កំណត់តំបន់នេសាទសម្រាប់នាវានេសាទអួនអូសនៅតាមតំបន់ឆ្នេរ និងការនេសាទក្នុងកន្លែងហាមឃាត់ និងកន្លែងអភិរក្ស (សូមអានអនុសាសន៍ស្តីពីការកំណត់ដែននេសាទក្នុងឧបសម្ព័ន្ធ២) ....................................................................................................................២៦
២.៤.៣. អនុវត្តសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច ........................................................២៧
២.៥. ចំណុចដៅនៃការត្រួតពិនិត្យនិងអធិការកិច្ច..................................................................២៩
២.៦. ការជ្រើសរើសលក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើអធិការកិច្ច.......................................... ៣០
៣. ផែនការសកម្មភាពសម្រាប់ការត្រួតពិនិត្យ និងអធិការកិច្ចបទល្មើសជលផលក្នុងដែននេសាទសមុទ្រ .............................................................................................................................៣២
៣ .១.សកម្មភាពអាទិភាព....................................................................................................៣២
៤. ការចំណាយ..................................................................................................................... ៥៦
៤.១. ធនធានមនុស្ស...............................................................................................................៥៦
៤.១.១. សកម្មភាពគ្រប់គ្រង ...............................................................................................៥៦
៤.១.២. សកម្មភាពល្បាតនៅលើដីគោកផ្សេងទៀត...............................................................៥៧
៤.១.៣. ថវិកានិងការចំណាយ ............................................................................................. ៦០
៥. ការតាមដាន និងការវាយតម្លៃ........................................................................................... ៦៦
៥.១. ការផ្ទៀងផ្ទាត់ និងសូចនាករដែលសម្រេចបាន................................................................ ៦៦

៥.២. និរន្តរភាពវិស័យជលផល ........................................ ៦៧
៥.៣. ការកាត់បន្ថយសកម្មភាពដែលធ្វើឱ្យមហន្តរាយដល់ផលស្តុក ........................................ ៦៨
៥.៤. ការវិភាគថ្លៃចំណេញ ........................................ ៦៨
៥.៥. សន្និដ្ឋាន ........................................ ៦៨
៦.ឧបសម្ព័ន្ធ ........................................ ៧០
៦.១. ឧបសម្ព័ន្ធ១ ផែនការសកម្មភាព ........................................ ៧០
៦.២. ឧបសម្ព័ន្ធ២ ........................................ ៧៤
៦ .៣.ឧបសម្ព័ន្ធ៣ .ការអនុវត្តប្រព័ន្ធតាមដាននាវានេសាទ ........................................ ៧៧
៦.៤. ឧបសម្ព័ន្ធ៤ ការវាយតម្លៃផលនេសាទ ........................................ ៧៨

## បញ្ជីតារាង

តារាងទី១. ឆ្នេរសមុទ្រនិងភូមិនេសាទសមុទ្រ.......................................................................................៤
តារាងទី២. ចំនួននាវានេសាទសមុទ្រដែលបានធ្វើជំរឿននៅតាមបណ្តាខេត្តតំបន់ឆ្នេរ .................................៧
តារាងទី៣.ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៣ក្រុមតាមប្រវែងបណ្តោយសរុបនៅតាមបណ្តាខេត្តតំបន់ឆ្នេរ ... ៨
តារាងទី៤.ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៥ក្រុមតាមប្រវែងបណ្តោយសរុបនៅតាមបណ្តាខេត្តតំបន់ឆ្នេរ .... ៨
តារាងទី៥.តម្លៃទិញសម្ភារ.........................................................................................................២០
តារាងទី៦.ចំណុចដៅនៃការធ្វើអធិការកិច្ច .....................................................................................២៥
តារាងទី៧.ចំណាត់ថ្នាក់នៃការវាយតម្លៃហានិភ័យ ........................................................................... ៣០
តារាងទី៨.តារាងម៉ាទ្រីតសកម្មភាពសំខាន់ៗត្រូវអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ៣៣
តារាងទី៩.សកម្មភាពប្រតិបត្តិការអាទិភាពជាក់លាក់ធនធានមនុស្សនិងសកម្មភាពជាក់លាក់.....................៥៧
តារាងទី១០.ស្ថានភាពធនធានមនុស្ស និងកម្រិតសកម្មភាព ...........................................................៥៨
តារាងទី១១.ការចំណាយប្រតិបត្តិការ និងមូលធននៃការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ច ជលផលសមុទ្រ ...........................................................................................................................៦១
តារាងទី១២. ការចំណាយប្រតិបត្តិការ និងមូលធននៃការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ច ជលផលសមុទ្រៈសម្រាប់ចំណាយលើប្រព័ន្ធតាមដាននាវាសមុទ្រ.............................................. ៦៣
តារាងទី១៣.សូចនាករគោល .....................................................................................................៦៦

## បញ្ជីរូបភាព

រូបទី១. ដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ............................................................... ៤
រូបទី២. តំបន់ដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាង ........................................ ៥
រូបទី៣. ស្ថាប័នពាក់ព័ន្ធនានា និងការគ្រប់គ្រងជលផលក្នុងដែនសមុទ្រ ........................................... ១២
រូបទី៤.បញ្ហា ត្រួតពិនិត្យ និងសម្របសម្រួល.................................................................................១៨
រូបទី២.១.ប្រអប់ថ្មប្រឆាំងនឹងឧបករណ៍នេសាទអួនអូស......................................................................៧៥
រូបទី២.២.ប្រអប់ថ្មប្រឆាំងនឹងឧបករណ៍នេសាទ ...............................................................................៧៥
រូបទី២.៣.ប្រអប់ថ្មជាជម្រកវារិសត្វ ..............................................................................................៧៦

## ពាក្យបំព្រួញ

| | |
|---|---|
| Abalobi | កម្មវិធីអេឡិចត្រូនិកសម្រាប់តាមដាននាវានេសាទ និងកត់ត្រាផលនេសាទ |
| AIS | ប្រព័ន្ធកំណត់អត្តសញ្ញាណដោយស្វ័យប្រវត្តិអន្តរជាតិ |
| CCAMLR | អនុសញ្ញាសម្រាប់ការអភិរក្សធនធានសមុទ្ររស់អង់តាកទិក |
| EEZ | តំបន់សេដ្ឋកិច្ចផ្តាច់មុខ |
| EC-DGMARE | អគ្គនាយកដ្ឋានកិច្ចការសមុទ្រ និងជលផលនៃសហភាពអឺរ៉ុប |
| FAO | អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ |
| GMS | ប្រព័ន្ធទូរស័ព្ទដៃតាមដាននាវានេសាទ |
| ICCAT | អនុសញ្ញាអន្តរជាតិសម្រាប់ការអភិរក្សត្រីធូណាក្នុងមហាសមុទ្រអាត្លង់ទិច |
| MCS | ការតាមដាន ត្រួតពិនិត្យ និងការឃ្លាំមើល |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MSY | ផលចាប់សរុបមិនលើសកម្រិតកំណត់និរន្តរភាពអតិបរមា |
| NCMS | គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ |
| Our Fish | កម្មវិធីអេឡិចត្រូនិកសម្រាប់តាមដាននាវានេសាទ និងកត់ត្រាផលនេសាទ |
| SAT | ប្រព័ន្ធតាមដានតាមផ្កាយរណប |
| SEAFDEC | មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានជលផលអាស៊ីអាគ្នេយ៍ |
| Smart Tool | កម្មវិធីអេឡិចត្រូនិកសម្រាប់តាមដាននាវានេសាទ និងកត់ត្រាផលនេសាទ |
| SMOTT | ក្រុមបង្រ្កាប និងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ |
| SWOT | ការវិភាគចំណុចខ្លាំង ខ្សោយ ឱកាស និងការគំរាមកំហែង |
| VMS | ប្រព័ន្ធតាមដាននាវានេសាទ |
| ការនេសាទអាយយូយូ | ការនេសាទខុសច្បាប់ គ្មានលិខិតអនុញ្ញាត និងគ្មានរបាយការណ៍ |

# អារម្ភកថា

វិស័យជលផលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិថា មានសារៈសំខាន់ណាស់ចំពោះសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសភាពសម្បូរបែបនៃផលនេសាទទឹកសាប។ ដូចគ្នានេះដែរ ផលនេសាទសមុទ្របានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះដោយបានបង្កើតការងារ និងសន្តិសុខស្បៀងក្នុងសហគមន៍តំបន់ឆ្នេរសមុទ្រកម្ពុជា។ ជាពិសេសតំបន់ឆ្នេរដែលសម្បូរទៅដោយទីជម្រកវារិសត្វសំខាន់ៗដូចជាព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រដែលមានផលិតភាពខ្ពស់ បាននិងកំពុងរងនូវការគំរាមកំហែងដោយការនេសាទខុសច្បាប់និងវិធីនេសាទដែលបំផ្លិចបំផ្លាញខ្លាំងដូចជាទូកនេសាទអួនអូសជាដើម។

ដើម្បីការពារ និងទប់ស្កាត់នូវសកម្មភាពអវិជ្ជមានទាំងនេះ យើងបានបង្កើតវិធានការគ្រប់គ្រងថ្មីៗ ដូចជាការគ្រប់គ្រងតាមបែបសហគមន៍នេសាទនៅតាមតំបន់ឆ្នេរដែលមកទល់ពេលនេះមានចំនួន៤១សហគមន៍ រួមទាំងការការពារទីជម្រកនិងតំបន់គ្រប់គ្រងជលផលសមុទ្រដែលគ្រប់គ្រងដោយសហគមន៍នេសាទ កិច្ចសហការជាមួយស្ថាប័នថ្នាក់ជាតិ និងអាជ្ញាធរខេត្តជាដើម។ បើទោះបីជាមានវិធានការមួយចំនួនដូចបានរៀបរាប់ខាងលើក៏ដោយ ក៏នៅមានភស្តុតាងបង្ហាញថា ធនធានជលផលសមុទ្រកំពុងរងនូវសម្ពាធខ្លាំងពីការបំផ្លិចបំផ្លាញទីជម្រកសំខាន់ៗ និងការនេសាទហួសកម្រិត។ ពិតណាស់ថា ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ គឺជាកត្តាចម្បងមួយដែលធ្វើឱ្យការអនុវត្តផែនការគ្រប់គ្រងធនធានជលផលមិនទទួលបានប្រសិទ្ធភាពខ្ពស់ ធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃធនធានជលផលសមុទ្រ និងសន្តិសុខស្បៀងផងដែរ ជាពិសេសអ្នកនេសាទដែលងាយរងគ្រោះ។

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រឆ្នាំ២០២០-២០២៤ នេះគឺជាផ្នែកមួយនៃផែនការជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២០-២០២៤ ដែលត្រូវបានរៀបចំនិងមានគោលបំណង គោលដៅយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ ដើម្បីពង្រឹងនិងលើកកម្ពស់ការការពារធនធានជលផលសមុទ្រតាមរយៈការកសាងសមត្ថភាពមន្ត្រី ការបំពាក់សម្ភារសម្រាប់ការអនុវត្ត និងការពង្រឹងកិច្ចសហការរវាងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ និងសហគមន៍នេសាទ ដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាពខ្ពស់។

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ត្រូវបានរៀបចំឡើងតាមរយៈការពិគ្រោះយោបល់ជាមួយសមត្ថកិច្ច និងអ្នកពាក់ព័ន្ធទាំងអស់នៅតំបន់សមុទ្រដើម្បីរិះរកគន្លឹះ ក្នុងការការពារនិងថែរក្សាសុវត្ថិភាពបរិស្ថាន និងធនធានជលផលសមុទ្រ ដោយកំណត់បាននូវយុទ្ធសាស្ត្រសំខាន់ៗ ក្នុងការដោះស្រាយ និងកាត់បន្ថយការគំរាមកំហែងចំពោះធនធានជលផលសមុទ្រ។

ជាមួយនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលជលផលពាក់ព័ន្ធទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំផែនការសកម្មភាពនេះ ជាពិសេសសហភាពអឺរ៉ុបដែលបានគាំទ្រថវិកា និងជំនួយបច្ចេកទេសក្នុងការរៀបចំ ក៏ដូចជាការអនុវត្តផែនការនាពេលខាងមុខ។

ខ្ញុំសង្ឃឹមថាផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រនេះ ប្រាកដជានឹងជួយដល់រដ្ឋបាលជលផលក្នុងការគ្រប់គ្រងធនធានជលផលសមុទ្រប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាពិសេសគឺកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ឱ្យបានដល់កម្រិតអប្បបរមា និងធានាបាននូវការនេសាទប្រកបដោយនិរន្តរភាព។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**វេង សាខុន**

# ១. សេចក្ដីផ្ដើម

## ១.១. ក្របខ័ណ្ឌគោលនយោបាយ

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ត្រូវបានកំណត់ដោយផ្អែកលើក្របខ័ណ្ឌគោលការណ៍ចំនួនពីរ៖

ក. កាតព្វកិច្ចនិងការប្ដេជ្ញាចិត្តខាងគោលនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះថ្នាក់តំបន់និងអន្តរជាតិ

ខ. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជា រួមទាំងផែនការសកម្មភាពជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ សេចក្ដីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្ដីពីគោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រ និងច្បាប់ស្ដីពីជលផលឆ្នាំ២០០៦ ដែលកំពុងធ្វើវិសោធនកម្ម។

## ១.២. គោលបំណង

គោលបំណងផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ គឺរៀបចំ "ការត្រួតពិនិត្យ" យុទ្ធសាស្ត្រ និង "ការត្រួតពិនិត្យ" ធនធានក្នុងមធ្យោបាយចំណាយមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់សកម្មភាពខុសច្បាប់ និងធានាឱ្យមានការអនុលោមតាម "ការត្រួតពិនិត្យ" មានន័យថាការតាមដាន ការឃ្លាំមើល និងការធ្វើអធិការកិច្ច។

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រមានគោលបំណងរៀបចំគោលដៅយុទ្ធសាស្ត្រតាមដាន ឃ្លាំមើល និងអធិការកិច្ច និងអភិវឌ្ឍការរៀបចំធនធាន "មនុស្សនិងសម្ភារ" ដើម្បីអនុវត្តនិងចំណាយមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ។

## ១.៣. គោលដៅ

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រមានគោលដៅដូចខាងក្រោម៖

ក. ផ្ដល់គោលការណ៍ណែនាំ និងគាំទ្រដល់ការអនុវត្តសកម្មភាពនានាដើម្បីបំពេញកាតព្វកិច្ចផ្អែកច្បាប់ជាតិ និងអន្តរជាតិ

ខ. អនុវត្តគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការត្រួតពិនិត្យនិងអធិការកិច្ច

គ.គាំទ្រការអនុវត្តលើការងារគ្រប់គ្រងជលផលសមុទ្រ(រួមបញ្ចូលទាំងផែនការគ្រប់គ្រងជលផលសមុទ្រ ដែលនឹងរៀបចំនាពេលអនាគត)

ឃ. គាំទ្រការអនុវត្តផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ។

## ១.៤. វិសាលភាព

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច ត្រូវអនុវត្តចំពោះវិធានការគ្រប់គ្រងនិងអភិរក្ស ថ្នាក់ជាតិនិងអន្តរជាតិដែលត្រូវអនុវត្តដូចខាងក្រោម៖

- ក. គ្រប់សកម្មភាពនេសាទសមុទ្ររួមមាននេសាទគ្រួសារ និងនេសាទពាណិជ្ជកម្មក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងតំបន់សមុទ្របូរណភាពដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា
- ខ.គ្រប់សកម្មភាពនេសាទសមុទ្រដែលពាក់ព័ន្ធនឹងនាវានេសាទកម្ពុជាក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខនៃបណ្ដារដ្ឋដទៃ និងសមុទ្រអន្តរជាតិ
- គ. កំពង់ផែនេសាទ និងកន្លែងចូលចតទាំងអស់ ដែលនាវានេសាទឡើងផលនេសាទ កន្លែងផ្ទេរផលនេសាទ និងក្រុមហ៊ុនកែច្នៃផលនេសាទ

ឃ. រាល់ការនាំចេញផល ផលិតផលជលផលដែលនេសាទបានក្នុងប្រទេស និងនាំចូលពីក្រៅប្រទេស។

### ១.៥. បរិបទសម្រាប់ការរៀបចំផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ

ការរៀបចំផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ គឺជាវិធានការមួយក្នុងចំណោមវិធានការនានាជាច្រើនដែលជាលទ្ធផលនៃការចរចារវាងរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មការសហភាពអឺរ៉ុប ។

រាជរដ្ឋាភិបាលកម្ពុជា និងអគ្គនាយកដ្ឋានកិច្ចការសមុទ្រនិងជលផលនៃសហភាពអឺរ៉ុប (EC-DGMARE) បានផ្តួចផ្តើមការពិភាក្សាស្តីពីការនេសាទអាយយូយូ។ ជាលទ្ធផល ភាគីទាំងពីរបានឯកភាពលើកិច្ចខិតខំប្រឹងប្រែងដើម្បីសហការដោះស្រាយបញ្ហាការនេសាទអាយយូយូប្រកបដោយប្រសិទ្ធភាពរួមមាន៖

ក. គោលនយោបាយជលផលជាតិសម្រាប់ធនធានជលផលសមុទ្រ

ខ. ផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ

គ. ពង្រឹងស្ថាប័នរដ្ឋបាល និងការកសាងសមត្ថភាព

ឃ. ក្របខ័ណ្ឌច្បាប់ស្តីពីជលផល

ង. ផែនការគ្រប់គ្រងជលផល

ច. ការវាយតម្លៃវិទ្យាសាស្ត្រទិន្នន័យជលផលនិងផលស្តុកត្រី

ឆ. ការចុះបញ្ជីនិងការផ្តល់លិខិតអនុញ្ញាតនាវានេសាទ

ជ. ការតាមដាន ត្រួតពិនិត្យ និងការឃ្លាំមើល

ឈ. កិច្ចសហប្រតិបត្តិការអន្តរជាតិ។

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការចាប់ផ្តើមរៀបចំ និងអនុម័តវិធានការនានា ដែលអាចនាំឱ្យមានការលើកលែងកាតក្រហម។

រដ្ឋបាលជលផលបានបញ្ចប់សេចក្តីព្រាងផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូឆ្នាំ២០២០-២០២៤ ដោយមានភ្ជាប់ផែនការបីឆ្នាំសម្រាប់ការអនុវត្តផងដែរ។

នៅទីបញ្ចប់ ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ដែលជំនួសឱ្យការតាមដាន ត្រួតពិនិត្យ និងការឃ្លាំមើល របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវបានរៀបចំឡើងដើម្បីរួមចំណែកក្នុងការដកប្រទេសកម្ពុជាចេញពីបញ្ជីនៃប្រទេសទី៣ ដែលមិនសហការគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូ។ ផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ គឺជាវិធានការច្បាប់មួយដែលបង្កើតឡើងដោយអគ្គនាយកដ្ឋានកិច្ចការសមុទ្រនិងជលផលនៃសហភាពអឺរ៉ុប ហើយមានចែងក្នុងបទប្បញ្ញត្តិរបស់គណៈកម្មការអឺរ៉ុបលេខ១២២៤/២០០៩។ និយមន័យដែលបានប្រើក្នុងឯកសារនេះខុសពីនិយមន័យនៃការតាមដាន ត្រួតពិនិត្យ និងការឃ្លាំមើលរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ប៉ុន្តែទាំងផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ និងការតាមដានត្រួតពិនិត្យ និងការឃ្លាំមើលអនុវត្តតាមគោលដៅយុទ្ធសាស្ត្រដូចគ្នា ដើម្បីធានាការអនុវត្តទៅតាមច្បាប់គ្រប់គ្រងជលផល និងបទប្បញ្ញត្តិនានា។

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ត្រូវអនុវត្តរួមគ្នាជាមួយនឹងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលបានកែសម្រួល និងសមស្របជាមួយផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ។ ផែនការទាំងពីរនេះនឹងផ្តល់នូវសកម្មភាពសំខាន់ៗនៃកំណែទម្រង់វិស័យជលផលសមុទ្រ។

ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រមានវិធានការសំខាន់ពីរ៖ ១. សកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជារួមទាំងការធ្វើពាណិជ្ជកម្មផល ផលិតផលជលផល និងការដឹកជញ្ជូនផល ផលិតផលជលផលឆ្លងកាត់ព្រំដែន និង ២. សកម្មភាពនេសាទដោយនាវានេសាទ

កម្ពុជាក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋដទៃ និងក្នុងសមុទ្រអន្តរជាតិ។ ផែនការជាតិត្រួតពិនិត្យ និងអធិការកិច្ចមានចែងអំពី៖

ក. កំណត់នូវវិធានការត្រួតពិនិត្យ និងអធិការកិច្ចក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាសម្រេចបើកឱ្យមានការចុះបញ្ជីនាវាអន្តរជាតិឡើងវិញ

ខ. ធ្វើការប៉ាន់ប្រមាណនូវការចំណាយពាក់ព័ន្ធនានាដូចជាប្រព័ន្ធតាមដាននាវានេសាទ(ប្រព័ន្ធតាមដានត្រួតពិនិត្យ)និងកម្មវិធីអ្នកសង្កេតការណ៍ដោយផ្អែកលើស្ថានភាពដែលមាន មុនពេលបិទមិនឱ្យបន្តការចុះបញ្ជី (ទាក់ទងទៅនឹងចំនួននិងប្រភេទនៃនាវានេសាទនិងតំបន់នេសាទ។ ល។)។

## ១.៦. ស្ថានភាពវិស័យជលផល

ជលផលក្នុងប្រទេសកម្ពុជា រួមមានជលផលទឹកសាប សមុទ្រ និងវារីវប្បកម្ម។ អ្នកចូលរួមក្នុងវិស័យទាំងនេះ រួមមានអ្នកនេសាទចិញ្ចឹមជីវិតដោយប្រើប្រាស់ឧបករណ៍នេសាទបែបបុរាណ អ្នកនេសាទគ្រួសារដែលប្រើឧបករណ៍នេសាទមានបច្ចេកទេសទាប អ្នកនេសាទបែបសិប្បកម្មនិងឧស្សាហកម្មដែលប្រើឧបករណ៍និងសម្ភារនេសាទទំនើប។

ទិន្នន័យរដ្ឋបាលជលផលបានបង្ហាញថាផលិតផលជលផលសរុប (រាប់បញ្ចូលទាំងវារីវប្បកម្ម)មានប្រហែល ៩០០ ០០០តោនក្នុងឆ្នាំ២០១៨ ដែលមានតម្លៃប្រមាណ១,៨ពាន់លានដុល្លារ និងផ្តល់ទិន្នផលសរុបពី៨%ដល់១០% នៃផលិតផលក្នុងស្រុកសរុប។ តម្លៃនៃការនាំចេញត្រីត្រូវបានគេប៉ាន់ប្រមាណថាមានរហូតដល់១០០លានដុល្លារក្នុងមួយឆ្នាំ។ បន្ថែមពីលើការនាំចេញជាផ្លូវការ បរិមាណផលិតផលនេសាទសមុទ្រជាទូទៅភាគច្រើនជាត្រី បង្កង បង្គា និងមឹកដែលមានតម្លៃខ្ពស់ត្រូវបាននាំចេញទៅព្រំដែនប្រទេសថៃ និងវៀតណាមដែលមិនមានរបាយការណ៍[១]។

ការនេសាទសមុទ្រនៅកម្ពុជាបានអភិវឌ្ឍយឺតៗ បើប្រៀបធៀបទៅនឹងការនេសាទទឹកសាប និងការនេសាទសមុទ្ររបស់ប្រទេសជិតខាង។ ទោះជាយ៉ាងណាក៏ដោយ មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងការនេសាទរយៈពេល១៥ឆ្នាំកន្លងមកនេះ។ ស្ថិតិរដ្ឋបាលជលផលបានបង្ហាញថាបរិមាណផលនេសាទសមុទ្រសរុបកើនឡើងចំនួន៣ដងគឺចាប់ពី៣៦ ០០០តោនក្នុងឆ្នាំ២០០០ ដល់១២០ ៥០០តោនក្នុងឆ្នាំ២០១៧[២]។ បរិមាណផលនេសាទសមុទ្រអាចមានចំនួនខ្ពស់ជាង១២០ ០០០តោន។ វិស័យជលផលសមុទ្ររួមចំណែកប្រមាណពី១៤%ដល់១៥%នៃផលិតផលសរុបក្នុងប្រទេស។ របាយការណ៍ថ្មីមួយបានបង្ហាញថាការនេសាទខ្នាតតូចជាពិសេសការនេសាទគ្រួសារដើម្បីចិញ្ចឹមជីវិតមិនត្រូវបានរាយការណ៍ ហើយបើបូកបញ្ចូលផលិតផលនេសាទសមុទ្រសរុប អាចមានប្រហែលជាង ២០០ ០០០តោន[៣]។

ការកើនឡើងយ៉ាងខ្លាំងនៃបរិមាណផលនេសាទចាប់តាំងពីឆ្នាំ២០០០មក បង្ហាញថាចំនួននាវានេសាទក៏បានកើនឡើងច្រើនដែរក្នុងរយៈពេលនោះហើយចំនួននិងទំហំនាវានេសាទ ចំនួននិងទំហំនៃឧបករណ៍នេសាទ និងរយៈពេលនៃការនេសាទក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។

សកម្មភាពពាក់ព័ន្ធនឹងជលផល ផ្តល់មុខរបរដល់ប្រជាជនស្ទើរតែពាក់កណ្តាលនៃប្រជាជនកម្ពុជា ដែលក្នុងនោះមានប្រហែល២៥% គឺការនេសាទពេញម៉ោង ហើយនៅសល់គឺការនេសាទក្រៅម៉ោង និងការនេសាទម្តងម្កាល[៤]។

ត្រីនិងវារីសត្វផ្សេងៗមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អាហារ និងអាហារូបត្ថម្ភនៅកម្ពុជាដែលមានអត្រាកង្វះអាហារូបត្ថម្ភខ្ពស់បំផុតក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ កង្វះជាតិប្រូតេអ៊ីន និងថាមពល និងកង្វះមីក្រូសារជាតិនៅតែមានជាទូទៅ ជាពិសេសក្នុងតំបន់ជនបទ និងក្នុងចំណោមកុមារដែលមានអាយុក្រោម៦ឆ្នាំ និងស្ត្រីដែលមានផ្ទៃពោះ និងបំបៅកូនដោយទឹកដោះ។ ត្រីជាប្រភពសម្បូរប្រូតេអ៊ីន អាស៊ីត ខ្លាញ់ វីតាមីន សារធាតុរ៉ែចាំបាច់ និងវារីសត្វផ្សេងៗមានចំនួន៨១,៥% នៃប្រូតេអ៊ីនសាច់សត្វសរុប[៥]។

## ១.៧. ការពិពណ៌នាអំពីការនេសាទក្នុងដែនសមុទ្រ

### ១.៧.១. ឆ្នេរសមុទ្រ និងដែននេសាទសមុទ្រ

ការនេសាទក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅតាមបណ្ដោយឈូងសមុទ្រថៃពីព្រំដែនថៃនៅទិសពាយ័ព្យ និងព្រំដែនវៀតណាមនៅទិសអាគ្នេយ៍។ តំបន់ឆ្នេរ រួមមានឆកធំៗ និងកោះជាច្រើនហើយលាតសន្ធឹងតាមបណ្ដាខេត្ត កោះកុង ព្រះសីហនុ កំពត និងខេត្តកែប (រូបទី១)។ យោងតាមច្បាប់ស្ដីពីជលផលបច្ចុប្បន្ននេះ "ដែននេសាទសមុទ្រ" លាតសន្ធឹងពីឆ្នេរសមុទ្រទៅកាន់ព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងគ្របដណ្ដប់លើដែនទឹកប្រមាណ ៥៥ ០០០គីឡូម៉ែត្រការ៉េ[៦]។ តំបន់នេះមានជម្រៅទឹករាក់ ជាមធ្យមប្រហែល៥០ម៉ែត្រ។ ឆ្នេរសមុទ្រមានប្រវែង៤៣៥ គីឡូម៉ែត្រ ហើយមានភូមិនៅតាមតំបន់ឆ្នេរសរុបចំនួន១៩២ភូមិ (តារាងទី១) និងចំនួនប្រជាពលរដ្ឋលើសពី១លាន នាក់ (ចំនួន៩៣៨ ៩៨៦នាក់ ជំរឿនឆ្នាំ២០០៨)។ ផែនេសាទឬកន្លែងឡើងផលនេសាទមាននៅតាមបណ្ដោយឆ្នេរ សមុទ្រ និងមានផែនេសាទធំៗក្នុងក្រុងនៃខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប។

រូបទី១. ដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា




តារាងទី១. ឆ្នេរសមុទ្រ និងភូមិនេសាទសមុទ្រ[៧]

| ខេត្ត | បណ្ដោយឆ្នេរ (គីឡូម៉ែត្រ) | ចំនួនភូមិនេសាទ តាមបណ្ដោយឆ្នេរ | ចំនួនប្រជាពលរដ្ឋ (ជំរឿនប្រជាជន ឆ្នាំ២០០៨) |
|---|---|---|---|
| កោះកុង | ២៣៧ | ១២៧ | ១១៧ ៤៨១ |
| ព្រះសីហនុ | ១០៥ | ៣៥ | ១៩៩ ៩០២ |
| កំពត | ៦៧ | ២៣ | ៥៨៥ ៨៥០ |
| កែប | ២៦ | ៧ | ៣៥ ៧៥៣ |
| **សរុប** | **៤៣៥** | **១៩២** | **៩៣៨ ៩៨៦** |

បច្ចុប្បន្ន ដែននេសាទសមុទ្រត្រូវបានបែងចែកជាកន្លែងនេសាទតាមឆ្នេរ (តំបន់ដែលស្ថិតនៅក្នុងខ្សែបន្ទាត់ដែលមានជម្រៅទឹក២០ម៉ែត្រ) និងកន្លែងនេសាទសមុទ្រក្រៅ (តំបន់ដែលស្ថិតនៅក្រៅខ្សែបន្ទាត់ដែលមានជម្រៅទឹក២០ម៉ែត្រ) ។

កន្លែងនេសាទមិនអាចត្រូវបានពិភាក្សាគ្រប់ជ្រុងជ្រោយទេ បើមិនបានគិតបញ្ចូលអំពីតំបន់ដែលមានវិវាទ (រូបទី២)។ ប្រទេសវៀតណាមបានចុះបញ្ជីទាមទារតំបន់សេដ្ឋកិច្ចផ្តាច់មុខនៅឆ្នាំ១៩៧១ បន្ទាប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៧២ និងប្រទេសថៃនៅឆ្នាំ១៩៧៣។ ការទាមទាររបស់ប្រទេសជិតខាងទាំងពីរបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើដែនទឹកបូរណភាពដែនដី និងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។

ស្ថានភាពបច្ចុប្បន្ន តំបន់ដែលមានការទាមទារត្រួតគ្នាជាមួយប្រទេសថៃត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ និងគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃដែលអនុញ្ញាតឱ្យមានការនេសាទដោយនាវានេសាទកម្ពុជា និងថៃក្នុងតំបន់មានវិវាទ។ តំបន់នេសាទក្នុងដែនទឹកប្រវត្តិសាស្រ្តជាមួយវៀតណាមក៏មិនត្រូវបានដោះស្រាយផងដែរ ហើយនាវាឆ្មាំសមុទ្រវៀតណាមតែងតែការពារនាវានេសាទខ្នាតធំ និងនាវាអួនអូសគូវៀតណាមឱ្យធ្វើនេសាទក្នុងដែនទឹកប្រវត្តិសាស្រ្ត (រូបទី២)។

រូបទី២. តំបន់ដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាង[៩]




## ១.៧.២. វិធានការគ្រប់គ្រងជលផលសមុទ្រ

ដែននេសាទសមុទ្រគឺជាដែននេសាទសាធារណៈ ដែលអ្នកនេសាទសមុទ្រកម្ពុជាទាំងអស់អាចធ្វើនេសាទបានដោយគ្មានការហាមឃាត់ជាមួយនឹងនាវានេសាទគ្រប់ខ្នាត ដែលបានចុះកំណត់ត្រាជាមួយរដ្ឋបាលជលផល (សម្រាប់នាវានេសាទតូចៗដែលមិនពាក់ព័ន្ធជាមួយនឹងក្រសួងសាធារណការនិងដឹកជញ្ជូន) និងទទួលបានលិខិតអនុញ្ញាតឱ្យធ្វើនេសាទនិងប្រើឧបករណ៍នេសាទដែលអនុញ្ញាត។

អ្នកនេសាទសមុទ្រអាចនេសាទត្រីពេញមួយឆ្នាំ ហើយពួកគេអាចផ្លាស់ប្តូរឧបករណ៍នេសាទតាមរដូវ។ យោងតាមទិន្នន័យរបស់រដ្ឋបាលជលផលឆ្នាំ២០១៨ បរិមាណត្រីជីមានប្រមាណ៤០% នៃផលនេសាទសរុប បន្ទាប់មកមានបង្គា មឹក ត្រីកាតឹម និងក្តាមសេះ។ ប្រភេទផលនេសាទដែលមានតម្លៃសេដ្ឋកិច្ចដូចជាគ្រែងឈាម និងសិប្បីសត្វដទៃទៀតក៏មានបរិមាណច្រើនបង្គួរដែរ។ ប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចដូចជាត្រីក្រហម ត្រីចោរ ត្រីកន្ទុយរឹង ត្រីកាម៉ុង បបែល ត្រីឆ្មោង និងពួកត្រីខ្សាច់ គឺជាប្រភេទត្រីដែលនេសាទបានច្រើន។ ប្រហែល២០%នៃផលនេសាទ

ដែលមានបរិមាណតិចតួចមានដូចជាត្រីតុកកែ ឆ្កង់ អាំងកើយ ការ៉ាវ ប្រមា សំប៉ាន និងត្រីចាប។ ក្ដាមថ្ម បង្កងកណ្ដូប ងាវផ្ចិត ខ្យងហុល និងមឹកផ្សេងៗត្រូវបាននេសាទយកមកលក់ផងដែរ។

ទិដ្ឋភាពនៃការធ្វើនេសាទក្នុងដែនសមុទ្រ បានបង្ហាញថាមិនមានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់សមត្ថភាពនេសាទឱ្យមានកម្រិតនិរន្តរភាពនោះទេ។ លិខិតអនុញ្ញាតឱ្យធ្វើនេសាទនាពេលបច្ចុប្បន្ននេះ គ្រាន់តែដើម្បីប្រមូលថ្លៃឈ្នួលនេសាទជាជាងការត្រួតពិនិត្យធនធានជលផល។ ទោះបីជាមានច្បាប់ស្ដីពីជលផល (ឆ្នាំ២០០៦) ផ្ដល់អំណាចដល់រដ្ឋាភិបាលដើម្បីគ្រប់គ្រងសកម្មភាពនេសាទខុសច្បាប់ក៏ដោយ ក៏ការអនុវត្តមិនសូវមានប្រសិទ្ធភាពទេនៅក្នុងដែនសមុទ្រ។

វិធានការគ្រប់គ្រងសំខាន់ៗសម្រាប់ការនេសាទមានចែងក្នុងច្បាប់ស្ដីពីជលផលឆ្នាំ២០០៦។ ច្បាប់នេះបានបង្ហាញនូវភាពខុសគ្នារវាងការនេសាទខ្នាតតូច និងការនេសាទជាលក្ខណៈគ្រួសារ (នេសាទតាមប្រពៃណី) ដែលពីមុនដាក់បញ្ចូលគ្នា និងការនេសាទខ្នាតមធ្យមនិងខ្នាតធំ។ លើសពីនេះទៀតច្បាប់ស្ដីពីជលផលឆ្នាំ២០០៦ ទទួលស្គាល់ការនេសាទពាណិជ្ជកម្មព្រមទាំងបានកំណត់ស្ថាប័នទទួលខុសត្រូវដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមានរដ្ឋបាលជលផលជាសេនាធិការ។ មុខងារគ្រប់គ្រងនិងការអនុវត្តច្បាប់ជាច្រើនត្រូវបានប្រគល់ទៅឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតំបន់ឆ្នេរ និងអនុវត្តដោយខណ្ឌរដ្ឋបាលជលផល ហើយត្រូវរាយការណ៍ទៅអភិបាលនៃគណៈអភិបាលខេត្ត (មើលរូបទី៤)។

ក. វិធានការគ្រប់គ្រងជលផលសំខាន់ៗរួមមាន៖

- ហាមឃាត់ការនេសាទដោយអួនអូសក្នុងតំបន់ហាមឃាត់ក្នុងដែនសមុទ្រដែលមានខ្សែបន្ទាត់ជម្រៅទឹករាក់ជាង២០ម៉ែត្រ
- បញ្ជីឧបករណ៍នេសាទដែលបានអនុញ្ញាត និងទំហំក្រឡាដែលហាមឃាត់
- រដូវបិទនេសាទគឺចាប់ពីពាក់កណ្ដាលខែមករា ដល់បំណាច់ខែមីនា(សម្រាប់ត្រីកាម៉ុង)
- ការហាមឃាត់ការនេសាទក្នុងកន្លែងអភិរក្សជលផល តំបន់ស្មៅសមុទ្រ និងផ្កាថ្ម។

ច្បាប់ស្ដីពីជលផលឆ្នាំ២០០៦ មាត្រា១១ បញ្ជាក់ថា: តំបន់ស្មៅសមុទ្រ ផ្កាថ្ម និងព្រៃកោងកាងដែលមានសារៈសំខាន់សម្រាប់និរន្តរភាពនៃធនធានជលផល ក៏ត្រូវបានចាត់ថ្នាក់ជា "តំបន់គ្រប់គ្រងជលផល"។ លើសពីនេះទៀតមាត្រា១៨ បញ្ជាក់ថា: កន្លែងដែលមានសារៈសំខាន់សម្រាប់និរន្តរភាពនៃធនធានជលផលទាំងនេះ ត្រូវបានចាត់ថ្នាក់ជា "កន្លែងការពារនិងអភិរក្សធនធានជលផល"។

ខ. រហូតមកដល់បច្ចុប្បន្នតំបន់គ្រប់គ្រងជលផលសមុទ្រចំនួនពីរត្រូវបានបង្កើតឡើងគឺ៖

- តំបន់គ្រប់គ្រងជលផលសមុទ្រមានផ្ទៃទំហំប្រមាណ៤០៥គីឡូម៉ែត្រការ៉េ នៅជុំវិញកោះរ៉ុង និងកោះរ៉ុងសន្លឹម (ឆ្នាំ២០១៦)
- តំបន់គ្រប់គ្រងជលផលសមុទ្រមានផ្ទៃទំហំប្រមាណ១១ ៣៥៤ហិកតា នៅជុំវិញប្រជុំកោះ នៅខេត្តកែប (ឆ្នាំ២០១៨)។

តំបន់ហាមឃាត់ដូចគ្នានេះ ក៏មានចែងក្នុងច្បាប់ស្ដីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ របស់ក្រសួងបរិស្ថាន។ តំបន់គ្រប់គ្រងជលផលសមុទ្រកោះរ៉ុងត្រូវបានប្រកាសថាជាឧទ្យានសមុទ្រជាតិដោយអនុក្រឹត្យរាជរដ្ឋាភិបាល។ មិនមានភាពច្បាស់លាស់ដែលថាស្ថាប័នណាមានសិទ្ធិសម្រេចចុងក្រោយ ក្នុងការការពារបរិស្ថានសមុទ្រក្នុងតំបន់នេះហាក់ដូចជាមិនមានភាពច្បាស់លាស់។

គ. វិធានការរដ្ឋបាលផ្សេងទៀតរួមមាន៖

- ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ត្រូវអនុលោមទៅតាមអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិ

- ការដឹកជញ្ជូនត្រូវសុំលិខិតអនុញ្ញាត
- លិខិតអនុញ្ញាតនាំចូល នាំចេញ និងការរឹតបន្តឹងការផ្ទេរផលនេសាទ។

ក្នុងចំណោមលក្ខខណ្ឌទាំងនេះ មានតែលិខិតអនុញ្ញាតនាំចូល នាំចេញប៉ុណ្ណោះត្រូវបានប្រើប្រាស់។

សហគ្រប់គ្រងជាមួយសហគមន៍នេសាទក្នុងកន្លែងនេសាទសហគមន៍ គឺជាវិធានការគ្រប់គ្រងបន្ទាប់ទី២ ដែលអនុវត្តនៅកម្ពុជា។ ចំណុចសំខាន់នេះអនុញ្ញាតឱ្យសហគមន៍នេសាទគ្រប់គ្រងកន្លែងនេសាទសហគមន៍ជាក់លាក់។ ដំណើរការបង្កើតសហគមន៍នេសាទត្រូវបានកំណត់ដោយប្រកាសលេខ៣១៦ ស្តីពីគោលការណ៍ណែនាំសម្រាប់សហគមន៍នេសាទ អនុម័តក្នុងឆ្នាំ២០០៧។ ក្នុងកន្លែងនេសាទសហគមន៍មានកន្លែងអភិរក្សយ៉ាងហោចណាស់មួយ ដែលបានប្បញ្ញត្តិក្នុងការធ្វើនេសាទមានទីតាំងជាក់លាក់ ដែលបានកំណត់ជាតំបន់ដែលមិនអាចធ្វើនេសាទបាន។

ក្នុងកន្លែងនេសាទសហគមន៍មានបញ្ហាប្រឈមជាច្រើន ឧទាហរណ៍ សហគមន៍នេសាទមិនគ្រប់គ្រងការចូលមកនេសាទដោយអ្នកនេសាទដែលមិនមែនជាសមាជិកសហគមន៍ទេ។ សមាជិកសហគមន៍នេសាទមានសិទ្ធិទប់ស្កាត់បទល្មើសនេសាទក្នុងដែនរបស់ខ្លួន តែមិនមានសិទ្ធិក្នុងការដាក់ពិន័យ។ ទន្ទឹមនឹងនោះនៅមានបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រងសហគមន៍ និងបង្ក្រាបបទល្មើសនេសាទគឺការឧបត្ថម្ភថវិកាមានកម្រិត និងគ្មានថវិកាតែម្តង។ មន្ត្រីខណ្ឌរដ្ឋបាលជលផល និងមន្ត្រីរដ្ឋបាលជលផលថ្នាក់កណ្តាលបានជួយសហគមន៍នេសាទក្នុងការអនុវត្តច្បាប់ និងគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ទិន្នន័យ និងព័ត៌មាននេសាទសមុទ្រត្រូវបានរាយការណ៍មករដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ត្រីខណ្ឌរដ្ឋបាលជលផលជាអ្នកប្រមូលស្ថិតិផលនេសាទ តាមរយៈសៀវភៅកត់ត្រាស្ថិតិពីអ្នកនេសាទនៅមានកម្រិត។

ទិន្នន័យផលនេសាទពិបាកផ្ទៀងផ្ទាត់ ព្រោះវាបានគណនាចេញពីប្រភពមិនច្បាស់លាស់និងហួសសម័យ។ ទិន្នន័យប្រវែងត្រី ទិន្នន័យផលចាប់ក្នុងមួយឯកតា និងការវាយតម្លៃផលស្តុកគឺមិនមានទេ។

### ១.៧.៣. នាវានេសាទ និងការធ្វើនេសាទ

#### ក. ការធ្វើចំណាត់ថ្នាក់នាវានេសាទ

លទ្ធផលនៃការធ្វើជំរឿននាវានេសាទសមុទ្រឆ្នាំ២០១៨ បានបង្ហាញថានាវានេសាទសមុទ្រសរុបមានចំនួន ៧ ៥៥២គ្រឿងដែលមានក្នុងតារាងទី២ តាមបណ្តាខេត្តដូចខាងក្រោម៖

តារាងទី២. ចំនួននាវានេសាទសមុទ្រដែលបានធ្វើជំរឿននៅតាមបណ្តាខេត្តតំបន់ឆ្នេរ

| **ខេត្តតំបន់ឆ្នេរ** | **ចំនួននាវានេសាទសមុទ្រ** | **ចំនួននាវានេសាទសមុទ្រ (%)** |
|---|---|---|
| កោះកុង | ៣ ៣៩៦ | ៤៥,០ |
| ព្រះសីហនុ | ២ ៥២៣ | ៣៣,៤ |
| កំពត | ១ ០៣៩ | ១៣,៨ |
| កែប | ៥៩៤ | ៧,៩ |
| **សរុបរួម** | **៧ ៥៥២** | **១០០,០** |

ការធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រតាមប្រវែងបណ្តោយនាវា និងមាន២ជម្រើសសំខាន់ៗ៖

ជម្រើសទី១. យោងតាមច្បាប់ស្តីពីជលផលដែលកំពុងធ្វើវិសោធនកម្ម នាវានេសាទសមុទ្រមានម៉ាស៊ីននៅតាមបណ្តាខេត្តតំបន់ឆ្នេរត្រូវបានបែងចែកជា៣ប្រភេទតាមប្រវែងបណ្តោយសរុបរបស់នាវានេសាទសមុទ្រគឺនាវានេសាទខ្នាតធំ (≥ ២៤ម៉ែត្រ) ខ្នាតមធ្យម (១២ - < ២៤ម៉ែត្រ) និងនាវានេសាទខ្នាតតូច ( < ១២ម៉ែត្រ)។ ជាមួយគ្នានេះដែរ

នាវានេសាទអួនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រត្រូវបានចាត់បញ្ចូលក្នុងប្រភេទនាវានេសាទខ្នាតមធ្យម (តារាងទី៣)។

តារាងទី៣. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៣ប្រភេទតាមប្រវែងបណ្តោយសរុបនៅតាមបណ្តាខេត្តតំបន់ឆ្នេរ

| ប្រភេទនាវានេសាទ | ចំណាត់ថ្នាក់ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|---|
| នាវានេសាទខ្នាតធំ | **≥២៤** | ១០ | ០ | ០ | ០ | ១០ |
| នាវានេសាទខ្នាតមធ្យម | **១២ - <២៤** | ៩៦២ | ១៥៤៥ | ៦២៩ | ៣៦៧ | ៣៥១២ |
| នាវានេសាទខ្នាតតូច | **<១២** | ២៤២៤ | ៩៧៨ | ៤១០ | ២២៧ | ៤០៣០ |
| **សរុប** | | ៣៣៩៦ | ២៥២៣ | ១០៣៩ | ៥៩៤ | ៧៥៥២ |

ជម្រើសទី២. ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង នាវានេសាទសមុទ្រត្រូវបានបែងចែកជា ៥ក្រុមដូចជា៖ នាវានេសាទសមុទ្រដែលមានប្រវែងលើសពី២៤ម៉ែត្រ មានចំនួន១០គ្រឿង ចាប់ពី១៨-២៤ម៉ែត្រមានចំនួន១១៥គ្រឿង ចាប់ពី១២-១៨ម៉ែត្រមានចំនួន ២ ២០៩គ្រឿង ចាប់ពី៦-១២ម៉ែត្រមានចំនួន ៤ ២៩៤គ្រឿង និងនាវានេសាទសមុទ្រដែលមានប្រវែងខ្លីជាង៦ម៉ែត្រមានចំនួន៩២៤គ្រឿង។ ចំនួននាវានេសាទសមុទ្រដែលបែងចែកជា៥ក្រុមតាមបណ្តាខេត្តតំបន់ឆ្នេរមានបង្ហាញដូចក្នុងតារាងទី៤ ខាងក្រោម។

តារាងទី៤. ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៥ក្រុមតាមប្រវែងបណ្តោយសរុបនៅតាមបណ្តាខេត្តតំបន់ឆ្នេរ

| ការចាត់ថ្នាក់តាមប្រវែងនាវា(ម៉ែត្រ) | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុប |
|---|---|---|---|---|---|
| ≥ ២៤ | ១០ | ០ | ០ | ០ | ១០ |
| ១៨ - < ២៤ | ៦៧ | ៤២ | ៦ | ០ | ១១៥ |
| ១២ - < ១៨ | ៧០៦ | ៨៨៨ | ៣១១ | ៣០៤ | ២ ២០៩ |
| ៦ - < ១២ | ១ ៧២៧ | ១ ៥៥៩ | ៧១៨ | ២៩០ | ៤ ២៩៤ |
| < ៦ | ៨៨៦ | ៣៤ | ៤ | ០ | ៩២៤ |
| **សរុប** | **៣ ៣៩៦** | **២ ៥២៣** | **១ ០៣៩** | **៥៩៤** | **៧ ៥៥២** |

លើសពីនេះ នាវានេសាទសមុទ្រកម្ពុជាមាន៣ក្រុមយោងតាមលក្ខណៈឬទីតាំងម៉ាស៊ីន គឺនាវានេសាទគ្មានម៉ាស៊ីន នាវានេសាទម៉ាស៊ីនក្រៅ និងនាវានេសាទម៉ាស៊ីនក្នុង។

- **នាវានេសាទគ្មានម៉ាស៊ីន** គឺជានាវានេសាទគ្រួសារដែលមានប្រហែល១២%។ នាវាទាំងនេះប្រើឧបករណ៍លបក្តាម មងត្រី និងលបប្រើសច្រើន។ល។ លបប្រើសច្រើនជាឧបករណ៍នេសាទខុសច្បាប់។ អ្នកនេសាទប្រើនាវាទាំងនេះភាគច្រើនធ្វើនេសាទតាមព្រែកនិងក្នុងព្រៃកោងកាង។

- **នាវានេសាទម៉ាស៊ីនក្រៅ** (នាវាឈើដែលគ្មានគ្រែង) គឺជានាវានេសាទកន្ទុយវែង មានចំនួនច្រើន (ប្រមាណ៣ ៥០០គ្រឿង) ដែលភាគច្រើនមានប្រវែងចាប់ពី៦ដល់១២ម៉ែត្រ ចាត់ទុកជានាវានេសាទខ្នាតតូច ប៉ុន្តែប្រសិនបើនាវាទាំងនេះប្រើឧបករណ៍នេសាទលើសការកំណត់ក្នុងប្រកាសលេខ៣១៩ប្រ.ក កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៥ ត្រូវចាត់ទុកជាការនេសាទពាណិជ្ជកម្ម។ នាវានេសាទកន្ទុយវែងភាគច្រើន ប្រើឧបករណ៍នេសាទដូចជា មងក្តាម មងបង្គា មងត្រី និងលបក្តាម។ ឧបករណ៍នេសាទផ្សេងៗទៀតដែលបានប្រើរួមមានលបមឹក មងត្រីកាម៉ុង មងត្រីស្រទាប់លើ សន្ទូចរនង ឈិបយន្ត អួនហ៊ុមតាមឆ្នេរ និងលបប្រើសច្រើន។ នាវានេសាទភាគច្រើនមានឧបករណ៍នេសាទច្រើនជាងមួយប្រភេទ (តាមរដូវកាល)។ ការនេសាទភាគច្រើនធ្វើក្នុងតំបន់នេសាទដែលមានខ្សែបន្ទាត់ជម្រៅទឹករាក់ជាង២០ម៉ែត្រ។ នាវានេសាទកន្ទុយវែងនេះអាចចេញទៅធ្វើនេសាទរហូតដល់ចម្ងាយ១២០គីឡូម៉ែត្រពីឆ្នេរ។

- **នាវានេសាទម៉ាស៊ីនក្នុង** (នាវាមានគ្រែង) គឺមានកម្លាំងពី១៤សេះ រហូតដល់ធំជាង៣០០សេះ (ប្រវែងនាវា៩-២៣ម៉ែត្រ)។ នាវាទាំងនេះភាគច្រើនមានបំពាក់ឧបករណ៍អេឡិចត្រូនិចដូចជាវិទ្យុទាក់ទងនិងឧបករណ៍កំណត់ ទីតាំង(GPS)។ នាវានេសាទមានគ្រែងភាគច្រើនប្រើឧបករណ៍នេសាទអួនអូស។ លើសពីនេះ នាវានេសាទម៉ាស៊ីនបាតមួយចំនួនប្រើឧបករណ៍នេសាទលបក្តាម លបមឹក អួនហ៊ុម និងអួនហោះ (អួនអូសស្រទាប់លើ)។ល។ ការនេសាទដោយអួនអូសនេសាទបានវារីសត្វគ្រប់ប្រភេទដូចជាត្រី ក្តាម បង្គា មឹក និងត្រីជី។ល។

នាវានេសាទអួនអូសខ្នាតតូចភាគច្រើនធ្វើនេសាទពេលយប់ និងធ្វើនេសាទក្នុងតំបន់ដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ។

នាវានេសាទម៉ាស៊ីនបាតក៏ប្រើឧបករណ៍អួនហ៊ុម ឈ្នាងអូសឈ្លើងសមុទ្រ និងលបមឹកដែលភាគច្រើននេសាទនៅតំបន់ទឹកជ្រៅជាង២០ម៉ែត្រ ដោយឡែកនៅខេត្តកោះកុងមាននាវានេសាទប្រវែងលើសពី២០ម៉ែត្រ ដែលមានកម្លាំងម៉ាស៊ីនធំជាង១៨០សេះ។

នាវានេសាទម៉ាស៊ីនបាតក៏ប្រើអួនអូសស្រទាប់លើ(អួនហោះត្រូវបានប្រើដើម្បីចាប់ត្រីស្រទាប់លើ មឹក ត្រីបេការ ត្រីកាម៉ុង។ល។ ប៉ុន្តែ នៅពេលនេសាទត្រីកាកឹម និងត្រីតូចៗស្រទាប់លើ អ្នកនេសាទបានប្តូរកន្ទុយក្រឡាអួនទៅ ០,៥មីល្លីម៉ែត្រ) សន្ទូចរនង មងត្រី អួនហ៊ុមក្រឡាញឹក លបត្រី លបមឹក ឈ្នាងអូសឈ្លើងសមុទ្រ ឈ្នាងអូសគ្រែងឈាម។

នាវានេសាទអួនអូសមួយចំនួនបានប្តូរទៅជាឧបករណ៍នេសាទអួនអូសឆក់ និងអួនអូសស្រទាប់លើ។

**ខ. សមត្ថភាពនាវានេសាទ**

ការវាយតម្លៃសមត្ថភាពនាវានេសាទ គឺជាការប៉ាន់ប្រមាណផលចាប់អតិបរមា ក្នុងមួយឯកតាឧបករណ៍នេសាទនៃនាវានេសាទ និងគិតទៅតាមលក្ខណៈរបស់នាវា(ប្រវែងបណ្តោយ ទទឹង និងចំណុះផ្ទុក) ប្រសិទ្ធភាពក្នុងការចាប់ដោយឧបករណ៍នេសាទជាក់លាក់ក្នុងមួយឯកតា និងប្រសិទ្ធភាពនៃការធ្វើឧបករណ៍នេសាទ កម្លាំងសេះ និងជំនាញក្នុងការធ្វើនេសាទរបស់ប្រធាននាវានេសាទ។

នៅឆ្នាំ២០១៨ រដ្ឋបាលជលផលបានធ្វើជំរឿននាវានេសាទសមុទ្រ ដែលផ្តល់ទិន្នន័យលម្អិតអំពីលក្ខណៈនាវានេសាទ ដូចជាប្រភេទ កម្លាំងម៉ាស៊ីន ប្រវែងបណ្តោយ ទទឹង និងចំណុះផ្ទុក។ល។ ដែលជាជំហានដំបូងក្នុងការវាយតម្លៃសមត្ថភាពនាវានេសាទ។ ទិន្នន័យទាំងនេះនឹងជួយបង្កើនការយល់ដឹងនិងគណនាសមត្ថភាពនេសាទជាក់លាក់សម្រាប់នាវានេសាទកម្ពុជា។

**គ. កម្មសិទ្ធិនាវានេសាទ**

យោងតាមលទ្ធផលនៃការធ្វើជំរឿននាវានេសាទឆ្នាំ២០១៨ បានបង្ហាញថាម្ចាស់កម្មសិទ្ធិនាវានេសាទភាគច្រើននៅក្នុងខេត្តកំពតនិងកែបមាននាវានេសាទតែមួយក្នុងមួយគ្រួសារ ដែលជានាវានេសាទខ្នាតតូចនិងខ្នាតមធ្យមកម្រិតតូច (១២ - ១៨ម៉ែត្រ)។ ពួកគាត់ជាម្ចាស់ផងនិងជាអ្នកដឹកនាំការនេសាទផង។ ចំណែកខេត្តកោះកុងនិងខេត្តព្រះសីហនុចំពោះនាវានេសាទខ្នាតធំនិងខ្នាតមធ្យមកម្រិតធំ (១៨ - ២៤ម៉ែត្រ) ម្ចាស់នាវានេសាទអាចមាននាវានេសាទចាប់ពី២គ្រឿងឡើងទៅ (១-២%)និងជួលតៃកុងទូកធ្វើនេសាទ។ ចំណែកនាវានេសាទខ្នាតតូចគឺម្ចាស់ និងតៃកុងទូកគឺជាមនុស្សតែម្នាក់។

**ឃ. ការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតសម្រាប់នាវានេសាទ**

នាវានេសាទដែលស្នើសុំលិខិតអនុញ្ញាតមានចំនួនតិច បើប្រៀបធៀបនឹងចំនួននាវានេសាទទាំងអស់។

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមនានាគឺទាក់ទងនឹងលិខិតបទដ្ឋានគតិយុត្ត។ បច្ចុប្បន្ននាវានេសាទតម្រូវឱ្យចុះបញ្ជីនៅក្រសួងសាធារណការនិងដឹកជញ្ជូនជាមុន។

ក្នុងអំឡុងពេលធ្វើជំរឿននាវានេសាទសមុទ្រនៅឆ្នាំ២០១៨ ដោយរដ្ឋបាលជលផល នាវានេសាទសមុទ្រចំនួន៧ ៥៥២គ្រឿងត្រូវបានបាញ់ស្លាកលេខសម្គាល់ និងផ្តល់បណ្ណសម្គាល់នាវា ដែលក្នុងនោះនាវានេសាទដែលមានប្រវែងលើសពី២៤ម៉ែត្រ មានចំនួន១០គ្រឿង ចាប់ពីប្រវែង១២-២៤ម៉ែត្រមានចំនួន២ ៣២៤គ្រឿង និងនាវានេសាទដែលមានប្រវែងខ្លីជាង១២ម៉ែត្រ មានចំនួន៥ ២១៨គ្រឿង។

### ១.៧.៤. ការធ្វើនេសាទដោយនាវានេសាទបរទេស

នាវានេសាទ២គ្រឿងមកពីប្រទេសចិនត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលកម្ពុជាដើម្បីនេសាទនៅកម្ពុជាក្នុងឆ្នាំ២០១៨ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននាវាទាំង២គ្រឿងនេះមិនទាន់មានវត្តមាននៅឡើយ។

### ១.៧.៥. កំពង់ផែនេសាទ ឬកន្លែងឡើងផលនេសាទនិងកន្លែងកែច្នៃផលនេសាទ

ប្រទេសកម្ពុជាមិនទាន់កំណត់កំពង់ផែនេសាទណាមួយសម្រាប់នាវានេសាទបរទេសនៅឡើយទេ ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ។ បច្ចុប្បន្នកម្ពុជាកំពុងតែរៀបចំកំណត់កំពង់ផែនេសាទសម្រាប់នាវានេសាទបរទេស។ លិខិតអនុញ្ញាតត្រូវបានផ្តល់សម្រាប់កន្លែងឡើងផលនេសាទ និងកន្លែងកែច្នៃផលនេសាទជាលក្ខណៈសិប្បកម្ម និងឧស្សាហកម្ម។

បច្ចុប្បន្ន ការឡើង និងការលក់ផលនេសាទទាំងអស់ធ្វើឡើងនៅកន្លែងឯកជន ហើយការគ្រប់គ្រងកន្លែងទាំងនោះនៅមានកម្រិតនៅឡើយ។ មានផែឡើងផលនេសាទឯកជនធំៗ នៅខេត្តកោះកុង និងខេត្តព្រះសីហនុ។

ការផ្ទេរផលនេសាទនៅសមុទ្រ និងកន្លែងឡើងផលនេសាទមួយចំនួន ជិតព្រំដែនត្រូវបានដឹកជញ្ជូនទៅលក់ឱ្យប្រទេសជិតខាង។ ការដឹកជញ្ជូនផលនេសាទពីនាវានេសាទទៅឱ្យអ្នកទិញផលនេសាទនៅតាមឆ្នេរមិនត្រូវបានចាត់ទុកថាជាការផ្ទេរផលនេសាទទេ ។

## ១.៨. ការធ្វើនេសាទរបស់នាវានេសាទកម្ពុជានៅក្រៅដែនយុត្តាធិការជាតិ

កម្ពុជាបានបិទការចុះបញ្ជីនាវាអន្តរជាតិទាំងអស់ក្នុងឆ្នាំ២០១៥។ បច្ចុប្បន្នមិនមាននាវានេសាទណាមួយត្រូវបានចុះបញ្ជីធ្វើអាជីវកម្មនៅតំបន់ក្រៅដែនយុត្តាធិការជាតិឡើយ។ ក្រសួងសាធារណការនិងដឹកជញ្ជូនបាននិងកំពុងពិចារណាបើកឱ្យមានការចុះបញ្ជីនាវាដឹកជញ្ជូន និងនាវានេសាទនាពេលអនាគត។ កន្លងមកមាននាវានេសាទបំពាក់ទង់ជាតិកម្ពុជាចំនួន៦គ្រឿង បានធ្វើសកម្មភាពក្នុងដែនសមុទ្រដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃអនុសញ្ញាសម្រាប់ការអភិរក្សធនធានសមុទ្រអង់តាកទិក (CCAMLR- Commission for the Conservation of Antarctic Marine Living Resources) និងនាវាដឹកផលនេសាទ១គ្រឿងបានធ្វើសកម្មភាពក្នុងដែនសមុទ្រដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃអនុសញ្ញាអន្តរជាតិសម្រាប់ការអភិរក្សត្រីធូណាក្នុងមហាសមុទ្រអាត្លង់ទិច (ICCAT- International Commission for the Conservation of Atlantic Tunas)។

កម្ពុជានឹងពិភាក្សាអំពីប្រព័ន្ធចុះបញ្ជីសម្រាប់នាវាដែលមិនមែនជានាវានេសាទអាយយូយូ ដើម្បីនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋដទៃ សមុទ្រអន្តរជាតិ និងតំបន់គ្រប់គ្រងដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់។

## ១.៩. ស្ថាប័នមានសមត្ថកិច្ច

### ១.៩.១. តួនាទីនិងភារកិច្ចស្ថាប័នមានសមត្ថកិច្ច

ការត្រួតពិនិត្យ និងអធិការកិច្ចគឺជាភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រដែលមានស្នាក់ការនៅខេត្តព្រះសីហនុ និងខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តតំបន់ឆ្នេរដែលគ្រប់គ្រងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ (NCMS-National Committee for Maritime Security) ត្រូវបានបង្កើតឡើងក្នុងខែធ្នូ ឆ្នាំ២០០៩ ដើម្បីជំរុញការសម្របសម្រួលក្រសួង-ស្ថាប័ន ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសជិតខាង ប្រទេសក្នុងតំបន់ដៃគូសន្តិសុខ និងស្ថាប័នអន្តរជាតិនានា ក្នុងកិច្ចប្រឹងប្រែងពង្រឹងសន្តិសុខលម្ហសមុទ្រ និងការឆ្លើយតបនឹងការគំរាមកំហែងគ្រប់រូបភាព មានជាអាទិ៍ ភេរវកម្ម ចោរសមុទ្រ ចរាចរគ្រឿងញៀន អន្តោប្រវេសន៍ខុសច្បាប់ នេសាទខុសច្បាប់ ការបំពុលបរិស្ថាន ការបំផ្លាញធនធានធម្មជាតិ និងគ្រោះមហន្តរាយ។

គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រដឹកនាំដោយសម្ដេចពិជ័យសេនាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ដែលមានសមាសភាពមកពីក្រសួង-ស្ថាប័នសំខាន់ៗដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងយុត្តិធម៌ ក្រសួងបរិស្ថាន រដ្ឋបាលជលផល អគ្គនាយកដ្ឋានគយនិងរដ្ឋាករ អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរ។ល។ គណៈកម្មាធិការជាតិនេះមានទីបញ្ជាការដ្ឋានមុខក្នុងកងទ័ពជើងទឹកមូលដ្ឋានសមុទ្ររាម ដើម្បីដឹកនាំប្រតិបត្តិការរួមនៃសមត្ថកិច្ចចម្រុះ។ គណៈកម្មាធិការប្រជុំពេញអង្គមួយឆ្នាំពីរដង ហើយអគ្គលេខាធិការនៃគណៈកម្មាធិការនេះប្រជុំជារៀងរាល់ខែបូកសរុបលទ្ធផលការងារ និងទិសដៅដើម្បីអនុវត្តបន្តលើបញ្ហាដែលកើតមានមួយចំនួនលើផ្ទៃសមុទ្រ។

លើសពីនេះមានគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្ដោយព្រំដែនសមុទ្រកម្ពុជា-ថៃ។ គណៈកម្មការនេះមានសមាសភាពដូចជា អភិបាលនៃគណៈអភិបាលខេត្តកោះកុង ទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មេបញ្ជាការភូមិភាគទី៣ មេបញ្ជាការរងកងទ័ពជើងទឹក នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ មេបញ្ជាការនគរបាលព្រំដែនទឹក និងមន្ទីរ អង្គភាពពាក់ព័ន្ធខេត្តកោះកុង។ គណៈកម្មការនេះមានភារកិច្ច បង្ក្រាបការធ្វើនេសាទអនាធិបតេយ្យ និងការពារការធ្វើនេសាទស្របច្បាប់របស់ប្រជាពលរដ្ឋ បង្ក្រាបការដឹកជញ្ជូនផល អនុផលព្រៃឈើ និងឈើកែច្នៃគ្រប់ប្រភេទដែលគ្មានច្បាប់ បង្ក្រាបការដឹកជញ្ជូនទំនិញគេចពន្ធ គ្រឿងញៀន និងបទល្មើសនានា សហការ និងទំនាក់ទំនងជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចថៃស្ដីពីការគ្រប់គ្រងលើការធ្វើអាជីវកម្មនេសាទ និងបញ្ហាពាក់ព័ន្ធផ្សេងទៀតលើដែនសមុទ្រកម្ពុជា-ថៃ និងក្នុងតំបន់ទាមទារត្រួតគ្នានៃសមុទ្ររវាងកម្ពុជា-ថៃ និងពិភាក្សាដោះស្រាយទំនាស់នានាជាមួយភាគីថៃដោយមិត្តភាព និងសន្តិវិធី។ល។ គណៈកម្មការនេះប្រជុំរៀងរាល់៣ខែម្ដង ដើម្បីសរុបសកម្មភាព និងលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នគរបាលការពារព្រំដែនទឹកបានធ្វើការល្បាតនៅលើផ្ទៃសមុទ្រ ក្នុងនោះក៏ធ្វើការត្រួតពិនិត្យនាវានេសាទផងដែរ។

ទោះជាយ៉ាងនេះក៏ដោយ ការសម្របសម្រួលក្នុងការត្រួតពិនិត្យបទល្មើសនេសាទជាប្រចាំនៅតាមបណ្ដាខណ្ឌរដ្ឋបាលជលផលតាមតំបន់ឆ្នេរ និងអាជ្ញាធរដែនដីនៅមានកម្រិត។ ការត្រួតពិនិត្យបទល្មើសនេសាទក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជាបញ្ហាអាកាសធាតុមិនអំណោយផល ចំនួនមន្ត្រីមិនគ្រប់គ្រាន់ ហើយអនុវត្តភារកិច្ចច្រើន រួមផ្សំឧបករណ៍សម្រាប់ការធ្វើអធិការកិច្ច ដូចជានាវាល្បាតមានល្បឿនយឺត ចាស់ទ្រុតទ្រោម និងមិនមានយានយន្តសម្រាប់ធ្វើអធិការកិច្ចនៅតាមផែនេសាទ និងនៅតាមទីតាំងត្រួតពិនិត្យសំខាន់ៗឡើយ។

រូបទី៣. ស្ថាប័នពាក់ព័ន្ធនានានិងការគ្រប់គ្រងផលផលក្នុងដែនសមុទ្រ




## ១.១០. ធនធានសម្រាប់ការត្រួតពិនិត្យជលផល

### ១.១០.១. ឧបករណ៍សម្ភារ

ឧបករណ៍សម្ភារមានតិចតួចសម្រាប់ការត្រួតពិនិត្យបទល្មើសជលផល នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត។ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រមាននាវាល្បាតសំបកដែកចំនួន២គ្រឿងដែលមួយគ្រឿងៗមានប្រវែង១៨ម៉ែត្រ មានអាយុកាល៣៧ឆ្នាំ មិនមានឧបករណ៍ត្រួតពិនិត្យទំនើប តែមានសកម្មភាពល្បាតជាទៀងទាត់។ ខណ្ឌរដ្ឋបាលជលផលកោះកុង ព្រះសីហនុ និងកែប ខណ្ឌរដ្ឋបាលជលផលនីមួយៗមាននាវាល្បាត១គ្រឿង ដោយឡែកខណ្ឌរដ្ឋបាលជលផលកំពតមាន២គ្រឿង។ នាវាល្បាតស្ទើរតែទាំងអស់មិនមានបំពាក់ឧបករណ៍ឃ្លាំមើល ឧបករណ៍ទំនាក់ទំនង និងឧបករណ៍បំពងសំឡេង។

នាវាល្បាតមិនមានប្រព័ន្ធតាមដាននាវានេសាទ ដើម្បីតាមដាននាវានេសាទក្នុងស្រុក ប៉ុន្តែកងទ័ពជើងទឹកមូលដ្ឋានសមុទ្រមានស្ថានីយ៍រ៉ាដាដើម្បីតាមដានសកម្មភាពនាវា។ ទិន្នន័យអំពីទីតាំងនាវាដែលបានពីប្រព័ន្ធកំណត់អត្តសញ្ញាណដោយស្វ័យប្រវត្តិអន្តរជាតិ (AIS) ត្រូវបានផ្តល់ឱ្យតាមរយៈភាគីចិន ប៉ុន្តែប្រព័ន្ធនេះមិនទាន់បានគ្របដណ្តប់លើនាវានេសាទទេ។

បច្ចុប្បន្នអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រមានរថយន្តសម្រាប់ការងារល្បាត១គ្រឿង ដោយឡែកខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរមិនមានរថយន្តល្បាតទេ។ ការឃ្លាំមើលពីលើអាកាសក៏មិនមានដែរ។

### ១.១០.២. ធនធានមនុស្ស

បញ្ហាប្រឈមចម្បងមួយក្នុងបញ្ហានានា គឺខ្វះធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ខេត្ត។ មន្ត្រីភាគច្រើននៅខណ្ឌរដ្ឋបាលជលផលធ្វើការច្រើនជំនាញ ដូចជាការងារសហគមន៍នេសាទ ការងាររដ្ឋបាល និងបង្ក្រាបបទល្មើសជលផល ការងារវារីវប្បកម្ម និងការងារអភិរក្ស។ល។ ប៉ុន្តែមន្ត្រីរដ្ឋបាលជលផលថ្នាក់ជាតិធ្វើការតាមភារកិច្ច។ មន្ត្រីអធិការកិច្ចខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរ រួមមាន៖ ខេត្តកែបមានចំនួន២រូប កំពតមានចំនួន៨រូប ព្រះសីហនុមានចំនួន៩រូប និងខេត្តកោះកុងមានចំនួន៥រូប។ មន្ត្រីអធិការកិច្ចរដ្ឋបាលជលផលសមុទ្រមានចំនួន២៧រូប ដែលក្នុងនោះរួមមាន នាយអធិការ១រូប នាយរង៦រូប មន្ត្រីរដ្ឋបាលចំនួន៥រូប មន្ត្រីល្បាតជាប្រចាំចំនួន៨រូប មន្ត្រីបើកបរចំនួន២រូប អ្នកពិនិត្យម៉ាស៊ីន២រូប និងអ្នកចម្អិនម្ហូបចំនួន២រូប។ មន្ត្រីនគរបាលយុត្តិធម៌មានចំនួន១៩រូប។ ដើម្បីអនុវត្តការងារអធិការកិច្ចឱ្យមានប្រសិទ្ធភាពក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងជ្រើសរើសមន្ត្រីអធិការកិច្ចនៅតំបន់ឆ្នេរបន្ថែមទៀត។

មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនិងមន្ត្រីខណ្ឌរដ្ឋបាលតំបន់ឆ្នេរទទួលបានការបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចជាមូលដ្ឋានបានមួយចំនួន ប៉ុន្តែត្រូវបណ្តុះបណ្តាលជំនាញបន្ថែមមួយចំនួនទៀតដូចខាងក្រោម៖

ក. វិធីសាស្ត្រនៃការឡើងនិងការធ្វើអធិការកិច្ចលើនាវានេសាទ ដែលទាក់ទងនឹងវិធានការរដ្ឋម្ចាស់កំពង់ផែ

ខ. ច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងឧក្រិដ្ឋកម្មសមុទ្រ អធិការកិច្ចសមុទ្រ ការក្លែងបន្លំឯកសារ ការកំណត់អត្តសញ្ញាណប្រភេទត្រី ឧបករណ៍នេសាទ និងការប្រមូលភស្តុតាង។ល។

គ. ការត្រួតពិនិត្យ ប្រមូលផ្តុំ និងវិភាគទិន្នន័យអធិការកិច្ច សម្រាប់អនុវត្តប្រព័ន្ធតាមដាននាវានេសាទ។

### ១.១១. សកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច

អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រអនុវត្តការល្បាតភាគច្រើននៅសមុទ្រ។ ការល្បាតក្នុងសមុទ្រជាមធ្យមពី១០ទៅ១៥ថ្ងៃក្នុងមួយខែដោយនាវាល្បាតទាំង២។ សកម្មភាពល្បាតត្រួតពិនិត្យតាមនាវាមានភាពមមាញឹក ដោយផ្តោតលើនាវានេសាទខុសច្បាប់និងឧបករណ៍នេសាទដែលនាវាប្រើ។ ខណ្ឌរដ្ឋបាលជលផលធ្វើសកម្មភាពល្បាតជាមធ្យមពី៧ថ្ងៃដល់១០ថ្ងៃក្នុងមួយខែ។ ការល្បាតដោយរថយន្តមានសកម្មភាពតិចនៅតាមមូលដ្ឋាន ដោយខ្វះមធ្យោបាយ និងមានថវិកាមិនគ្រប់គ្រាន់។

### ១.១២. ការវិភាគ SWOT នៃសកម្មភាពតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល

ការវិភាគ SWOT (Strengths, Weaknesses, Opportunities, and Threats) បានវាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងនៃសកម្មភាពតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល ។ ចំណុចខ្លាំង និងឱកាសគឺមានតិចតួច បញ្ហាប្រឈមគឺការគាំទ្រផ្នែកនយោបាយនៅមានកម្រិត។ បញ្ហាចម្បងនៃចំណុចខ្សោយមានដូចខាងក្រោម៖

ក.ការយកចិត្តទុករបស់អ្នកពាក់ព័ន្ធលើវិស័យជលផលនៅមានកម្រិត នាំឱ្យការប្រមូលចំណូលពីវិស័យជលផលមានកម្រិតទាប ថ្វីត្បិតតែវិស័យនេះបានចូលរួមចំណែកប្រមាណ៨ភាគរយនៃផលិតផលសរុបក្នុងស្រុក។ ហេតុដូច្នេះហើយថវិកាសម្រាប់គ្រប់គ្រងវិស័យជលផលមានតិចតួច រួមទាំងថវិកាសម្រាប់ការតាមដាន ត្រួតពិនិត្យ និងអង្កេត មិនមានទិន្នន័យបញ្ជាក់ពីស្ថានភាពនៃផលស្តុក ការយល់ដឹងពីសារៈសំខាន់នៃធនធានជលផលសម្រាប់ប្រជាពលរដ្ឋក្រីក្រ នាំឱ្យមានបញ្ហាដល់សន្តិសុខស្បៀង។

ខ. ការផ្តល់លិខិតអនុញ្ញាតឱ្យនាវានេសាទមានការលំបាក ដោយមុននឹងចេញលិខិតអនុញ្ញាតត្រូវមានការចុះបញ្ជីនាវានៅក្រសួងសាធារណការ និងដឹកជញ្ជូនជាមុន

គ. ការធ្វើនេសាទ និងដឹកជញ្ជូនផល ផលិតផលផលផលឆ្លងកាត់ព្រំដែនរវាងកម្ពុជា ថៃ និងវៀតណាម មិនទាន់មានការគ្រប់គ្រងច្បាស់លាស់។

### ១.១៣. បញ្ហាចម្បង

បញ្ហាចម្បងនៃសកម្មភាពនេសាទអាយយូយូមានដូចខាងក្រោម៖

**ការនេសាទដោយគ្មានការអនុញ្ញាត**

- នាវានេសាទកម្ពុជាភាគច្រើនធ្វើនេសាទដោយមិនបានចុះបញ្ជី ឬគ្មានលិខិតអនុញ្ញាតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ
- សមត្ថភាពនេសាទកំពុងតែកើនឡើងក្នុងដែននេសាទដែលជាកន្លែងនេសាទសាធារណៈ
- ការកើនឡើងនូវការសាងសង់ "នាវានេសាទអួនអូសធំៗ" ឧទាហរណ៍នាវាមានចំណុះផ្ទុកធំនិងកម្លាំងសេះធំជាងនាវានេសាទធម្មតាច្រើនដង
- នាវានេសាទមិនបានអនុវត្តតាមបទប្បញ្ញត្តិជាធរមាន
- ការនាំចេញផល ផលិតផលផលផលពីការនេសាទអាយយូយូ ទៅកាន់ប្រទេសជិតខាង
- ការឡើងផលនេសាទនៅផែ ឬកន្លែងឡើងផលនេសាទដែលមិនបានចុះបញ្ជី
- កន្លែងកែច្នៃផលនេសាទមួយចំនួនមិនបានចុះបញ្ជី ឬគ្មានលិខិតអនុញ្ញាត
- នាវានេសាទបរទេសលួចចូលធ្វើនេសាទដោយគ្មានលិខិតអនុញ្ញាតពីកម្ពុជា។

**ការនេសាទគ្មានរបាយការណ៍**

- ចំនួននាវានេសាទប្រទេសជិតខាងលួចចូលធ្វើនេសាទខុសច្បាប់ក្នុងដែនសមុទ្រកម្ពុជាមិនច្បាស់លាស់
- គ្មានស្ថិតិផលនេសាទពីនាវានេសាទកម្ពុជាដែលបានឡើងនៅផែប្រទេសជិតខាង
- គ្មានស្ថិតិផលនេសាទដែលបានឡើងនៅកម្ពុជា និងនាំចេញទៅប្រទេសជិតខាង
- គ្មានស្ថិតិទិន្នផលចាប់ សមាសភាពផលនេសាទ និងការវិភាគប្រេកង់ប្រវែងត្រី។

**ការនេសាទខុសច្បាប់**

**នាវានេសាទកម្ពុជា**

- នាវានេសាទមួយចំនួនធ្វើនេសាទដោយគ្មានការចុះបញ្ជី គ្មានកំណត់ត្រា និងគ្មានលិខិតអនុញ្ញាត
- ការរំលោភបំពានដោយនាវាអួនអូសក្នុងដែននេសាទក្នុងខ្សែបន្ទាត់ដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ
- ការបំផ្លិចបំផ្លាញទីជម្រកដោយនាវានេសាទ (ផ្កាថ្មនិងស្មៅសមុទ្រ)
- នាវានេសាទស្របច្បាប់និងខុសច្បាប់ដែលប្រើឧបករណ៍នេសាទ មានក្រឡាខុសច្បាប់ដូចជាអួនអូសមងត្រី លបក្តាម អួនហ៊ុម និងឧបករណ៍នេសាទខុសច្បាប់ដែលច្នៃដូចជា អួនក្រឡាញឹកនៅផ្នែកខាងក្រោយសម្រាប់អួនអូស អួនអូសឆក់ ឧបករណ៍នេសាទដែលមិនទាន់កំណត់ដូចជា អួនហោះនិងឈ្នាងអូសឈ្លើងសមុទ្រ
- ការប្រើឧបករណ៍នេសាទហាមឃាត់ដូចជាគ្រឿងផ្ទុះ ឈើបយន្ត អួនអូសឆក់ លបប្រើសច្រើន រនាស់ឈ្លើងសមុទ្រ
- ការនេសាទលក្ខណៈគ្រួសារ ប្រើឧបករណ៍នេសាទលើសប្រវែងកំណត់
- ការនេសាទក្នុងរដូវបិទនេសាទ

- ការនេសាទក្នុងកន្លែងហាមឃាត់ កន្លែងអភិរក្ស និងកន្លែងអភិរក្សសហគមន៍
- ការនេសាទដោយឧបករណ៍ហាមឃាត់ក្នុងកន្លែងនេសាទសហគមន៍។

**នាវានេសាទបរទេស**

- នាវានេសាទប្រទេសជិតខាងអាចឡើងផលនេសាទនៅប្រទេសកម្ពុជា (បច្ចុប្បន្ននាវានេសាទទាំងនោះត្រូវបានតាមដានដោយឧបករណ៍កំណត់ទីតាំង: ចំពោះតែនាវាមានចំណុះផ្ទុកធំជាង៣០តោនប៉ុណ្ណោះ។ នាវានេសាទទាំងនោះអាចឡើងផលនេសាទនៅកម្ពុជាប្រសិនបើមានការអនុញ្ញាតពីរដ្ឋបាលជលផល)
- នាវានេសាទប្រទេសជិតខាងលួចចូលធ្វើនេសាទក្នុងដែនសមុទ្រកម្ពុជាគ្មានការអនុញ្ញាត និងប្រើឧបករណ៍ខុសច្បាប់ដូចជាអួនអូសគូ អួនអូសឆក់ និងនាវានេសាទប្រើភ្លើង។

**ប្រជាជនកម្ពុជា**

- ផ្ទេរនិងដឹកជញ្ជូនផលនេសាទអាយយូយូ ទៅប្រទេសជិតខាង
- នាំចេញផលនេសាទអាយយូយូទៅប្រទេសជិតខាង
- បំផ្លាញទីជម្រកជលផលដូចជាព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រជាដើម។

**ប្រទេសជិតខាង**

- នាំចេញផលនេសាទ ដែលប្តូរឈ្មោះពីផលនេសាទអាយយូយូពីប្រទេសកម្ពុជា
- អនុញ្ញាតឱ្យនាវានេសាទកម្ពុជាឡើងផលនេសាទ
- ប្រើត្រីជីនាំចូលពីកម្ពុជាដែលនេសាទបានដោយការនេសាទអាយយូយូទៅក្នុងរោងចក្រកែច្នៃចំណីត្រី និងសត្វ។

## ១.១៤. សកម្មភាពចម្បងៗ ទាក់ទងនឹងផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ

### ១.១៤.១. ពង្រឹងការអនុវត្តច្បាប់

ការវាយតម្លៃហានិភ័យនៃធនធានជលផល និរន្តរភាពនៃផលស្តុក តំបន់អភិរក្សតាមព្រំដែន ដែលបានវាយតម្លៃក្នុងពេលអនុវត្តផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូ និងការពិនិត្យឡើងវិញនូវដំណើរនៃផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្របានកំណត់នូវការគំរាមកំហែងធំបំផុតចំពោះនិរន្តរភាពនៃធនធានជលផល និងសន្តិសុខស្បៀង ដើម្បីកំណត់គោលដៅផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច។

ការវាយតម្លៃខាងលើបានកំណត់នូវសកម្មភាពសំខាន់ៗក្នុងការអន្តរាគមន៍ជាយុទ្ធសាស្ត្រដូចខាងក្រោម៖

- ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ រួមមានការចុះបញ្ជី និងកត់ត្រានាវានេសាទ (កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលជលផល និងក្រសួងសាធារណការ និងដឹកជញ្ជូន)
- បញ្ឈប់ការនេសាទក្នុងតំបន់ហាមឃាត់ ឬតំបន់ការពារ (ការនេសាទដោយអួនអូសក្នុងតំបន់ហាមឃាត់ឬនេសាទក្នុងតំបន់អភិរក្សសហគមន៍នេសាទក្នុងតំបន់ហាមឃាត់នៃតំបន់គ្រប់គ្រងជលផល)
- ទប់ស្កាត់ការនេសាទដោយខុសច្បាប់រួមទាំងឧបករណ៍នេសាទដែលគ្មានការអនុញ្ញាត
- ឃាត់ចាប់នាវានេសាទបរទេសដែលគ្មានលិខិតអនុញ្ញាតក្នុងដែនសមត្ថកិច្ចរបស់កម្ពុជា។

### ១.១៤.២. ការពង្រឹងសមត្ថភាពអង្គភាព ក្នុងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល

សកម្មភាពអាទិភាពមានដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ថ្នាក់ដឹកនាំរដ្ឋបាលជលផលពាក់ព័ន្ធនឹងការងារការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល។ រដ្ឋបាលជលផលត្រូវបង្កើតក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិក្រោមការដឹកនាំរបស់អគ្គនាយករង១រូប។ ក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលអនុវត្ត តាមគោលបំណងរបស់ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងសមត្ថភាពអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រលើជំនាញពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាការតាមដាន ត្រួតពិនិត្យនិងឃ្លាំមើល និងការនេសាទអាយយូយូ ដោយអនុវត្តតាមគោលបំណងរបស់ផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ
- បង្កើតក្រុមការងារគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលតាមខេត្តតំបន់ឆ្នេរ
- ជួយបណ្តុះបណ្តាលខណ្ឌរដ្ឋបាលជលផលនូវជំនាញអធិការកិច្ច ដើម្បីអនុវត្តការតាមដាន ត្រួតពិនិត្យនិងឃ្លាំមើល និងដោះស្រាយបញ្ហាការនេសាទអាយយូយូ ដោយអនុវត្តតាមផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ។

### ១.១៤.៣. ការដោះស្រាយនូវការខ្វះខាតសម្ភារ

សម្ភារប្រើប្រាស់គឺជាលក្ខខណ្ឌចាំបាច់មួយ ដែលធ្វើឱ្យការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រប្រកបដោយប្រសិទ្ធភាព។ សម្ភារប្រើប្រាស់ដែលមានប្រសិទ្ធភាពដូចជានាវាល្បាត និងប្រព័ន្ធឃ្លាំមើលពីលើអាកាស និងប្រព័ន្ធឃ្លាំមើលនាវា ដើម្បីលើកតម្កស់សមត្ថភាពប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពក្នុងការអនុវត្តប្រព័ន្ធតាមដាន និងអធិការកិច្ច ដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូ ។

ការប្រើនាវាល្បាតថ្មីនឹងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ព្រោះវាអាចធ្វើដំណើរបានឆ្ងាយ ដឹកមនុស្សបានច្រើន ស៊ីប្រេងតិច អាចមានវត្តមាននៅលើសមុទ្របានយូរ ហើយធន់នឹងអាកាសធាតុ។

ប្រព័ន្ធតាមដាននាវានេសាទនឹងបង្កើនប្រសិទ្ធភាពនៃនាវាល្បាត ដោយផ្តល់នូវព័ត៌មានអំពីតំបន់គោលដៅដែលមានការប្រមូលផ្តុំនៃនាវានេសាទ។ នាវាល្បាតនេះអាចធ្វើដំណើរទៅកាន់តំបន់ប្រមូលផ្តុំនាវានេសាទបានទាន់ពេលវេលា ឬតាមដាននាវាដែលធ្វើដំណើរឆ្លងកាត់ព្រំដែន ដែលមិនបានដឹងពីមុនមក។ ប្រព័ន្ធតាមដាននាវានេសាទនេះនឹងបង្កើនការការពារតំបន់ការពារ ដើម្បីធ្វើឱ្យប្រសើរឡើងនូវធនធានជលផលសមុទ្រ និងធ្វើឱ្យផលនេសាទកើនឡើង។

ការជួលយន្តហោះដើម្បីល្បាតឃ្លាំមើលពីលើអាកាស នឹងជួយក្នុងការអនុវត្តច្បាប់ស្តីពីជលផលឱ្យមានប្រសិទ្ធភាពខ្ពស់។ ការហោះហើរដើម្បីស្រាវជ្រាវ លក្ខណៈទូទៅនៃការនេសាទ របាយនាវានេសាទក្នុងសមុទ្រ និងតំបន់នេសាទ និងជួយបន្ថែមនូវចំណេះដឹង និងប្រសិទ្ធភាពក្នុងការកំណត់តំបន់ និងការដាក់ផែនការពង្រាយនាវាល្បាតទៅតាមតំបន់ដែលចាំបាច់ ករណីនេះអាចកាត់បន្ថយពេលវេលាល្បាត ប្រេងឥន្ធនៈ និងពេលវេលាល្បាតរបស់មន្ត្រី។ ជម្រើសនានាសម្រាប់ការតាមដានពីលើអាកាសដែលមានប្រសិទ្ធភាពត្រូវបានកំណត់។ កម្ពុជាអាចប្រើយន្តហោះគ្មានមនុស្សបើក ឬយន្តហោះដែលមានមនុស្សបើកសម្រាប់កំណត់ផែនការល្បាត។

## ២. យុទ្ធសាស្ត្រក្នុងការត្រួតពិនិត្យ និងអធិការកិច្ចជលផលក្នុងដែននេសាទសមុទ្រ

ដើម្បីកាត់បន្ថយ ទប់ស្កាត់ និងលុបបំបាត់ហានិភ័យដែលបានកំណត់ក្នុងចំណុច១.១៣ និង១.១៤ខាងលើ ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រមានគោលដៅយុទ្ធសាស្ត្រ៤ដូចខាងក្រោម៖

- ពង្រឹងការរៀបចំរដ្ឋបាលសម្រាប់រដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ផ្គត់ផ្គង់សម្ភារបរិក្ខារសំខាន់ៗសម្រាប់នាវាល្បាត និងឧបករណ៍ផ្សេងៗទៀតសម្រាប់ការងារល្បាត
- អនុវត្តការចុះបញ្ជី ការកត់ត្រា និងការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទកម្ពុជា
- អនុវត្តការល្បាត តាមនាវានិងរថយន្ត ដើម្បីត្រួតពិនិត្យនិងអធិការកិច្ច និងគោលការណ៍អប់រំតាមរយៈការពិន័យ។

## ២.១. ពង្រឹងការរៀបចំផ្នែករដ្ឋបាល

### ២.១.១. បង្កើតការិយាល័យតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ដើម្បីអនុវត្តការត្រួតពិនិត្យ និងអធិការកិច្ច

ក្រុមការងារគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិត្រូវទទួលខុសត្រូវចំពោះការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ និងត្រូវរាយការណ៍ទៅប្រធានរដ្ឋបាលជលផល។ ប្រធានរដ្ឋបាលជលផលត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចម្លងជូនអភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរ។ ក្រុមការងារគ្រប់គ្រងនេះត្រូវមានទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ឬគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃដើម្បីជួយអន្តរាគមន៍ (សូមមើលរូបទី៤)។

ក្រុមការងារគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិត្រូវសម្របសម្រួលក្នុងការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រដូចខាងក្រោម៖

- ពិនិត្យឡើងវិញនូវព័ត៌មានការនេសាទអាយយូយូ និងអនុវត្តផែនការជាក់លាក់ ដើម្បីទប់ស្កាត់និងលុបបំបាត់បទល្មើសកម្រិតធ្ងន់ ដោយប្រើក្រុមបង្ក្រាប និងដោះស្រាយបទល្មើសកម្រិតធ្ងន់។
- ជំរុញការអនុវត្តសកម្មភាពរដ្ឋបាលនានាដូចជា ការចុះបញ្ជីនាវានេសាទ ការកត់ត្រា និងការផ្តល់លិខិតអនុញ្ញាត និងជំរុញការត្រួតពិនិត្យនិងអធិការកិច្ច ត្រូវធ្វើឡើងដើម្បីផ្ទៀងផ្ទាត់យន្តការរដ្ឋបាលដែលបានអនុវត្ត និងមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការនេសាទ។

ក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិ ត្រូវជួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងខណ្ឌរដ្ឋបាលជលផល ដើម្បីបង្កើតក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្ត តំបន់ឆ្នេរ ក្រោមការដឹកនាំដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដោយមានការសម្របសម្រួលពីរដ្ឋ-បាលជលផល។ ក្រុមការងារនេះមានសមាសភាព ខណ្ឌរដ្ឋបាលផលផល និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្ត និងសហការអនុវត្តផែនការជាតិជាប្រចាំ។

ក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំបើលថ្នាក់ខេត្តត្រូវរាយការណ៍ទៅជូនក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិ និងផ្តល់កិច្ចសម្របសម្រួលរវាងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត។

### ២.១.២. បង្កើតក្រុមពិសេសដើម្បីបង្ក្រាប និងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់

ក្រុមការងារគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល ថ្នាក់ជាតិត្រូវជួយសម្របសម្រួលក្នុងការបង្កើតក្រុមពិសេសមួយ ដើម្បីបង្ក្រាបនិងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់ អនុវត្តការស៊ើបអង្កេតនានា និងរៀបចំផែនការត្រួតពិនិត្យ និងអធិការកិច្ច។ ក្រុមពិសេសគឺក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ (SMOTT) ដែលមានសមាសភាពមន្ត្រីនគរបាលយុត្តិធម៌នៃរដ្ឋបាលជលផល និងថ្នាក់ដឹកនាំរបស់មន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ជាន់ខ្ពស់ក្នុងអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនៃរដ្ឋបាលជលផល។

### ២.១.៣.បង្កើតក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត

ក្រុមការងារគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្តត្រូវជួយសម្របសម្រួលក្នុងការបង្កើត ក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្តនៅតាមខេត្តតំបន់ឆ្នេរនីមួយៗ ដែលមានសមាសភាពជាមន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ខណ្ឌរដ្ឋបាលជលផល និងសមត្ថកិច្ចពាក់ព័ន្ធ (សមាសភាពក្រុមការងារបង្កើតឡើងទៅតាមធនធានដែលមាន)។ ក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្តត្រូវទទួលខុសត្រូវ ចំពោះក្រុមការងារគ្រប់គ្រងតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្ត ហើយរាយការណ៍លទ្ធផលការងារ និងបញ្ហាប្រឈមនានា។

ក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្តមានភារកិច្ចដូចខាងក្រោម៖

- បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ដែលមានចែងក្នុងច្បាប់ស្តីពីជលផលឆ្នាំ២០០៦
- រៀបចំផែនការ និងអនុវត្តផែនការតាមសមុទ្រនិងលើដី
- ទំនាក់ទំនងជាមួយក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ និងរាយការណ៍ជូនក្រុមការងារគ្រប់គ្រងតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិ
- អនុវត្តការធ្វើអធិការកិច្ចជលផលជាប្រចាំនៅសមុទ្រ និងលើដី
- ជួយខណ្ឌរដ្ឋបាលជលផលក្នុងការការពារធនធានជលផលសមុទ្រ។

រូបទី ៤.បញ្ជា ត្រួតពិនិត្យ និងសម្របសម្រួល



## ២.២. ការរៀបចំទិញសម្ភារសំខាន់ៗសម្រាប់ការត្រួតពិនិត្យ និងអធិការកិច្ច

### ២.២.១. សម្ភារសំខាន់ៗសម្រាប់ការត្រួតពិនិត្យ

រដ្ឋបាលជលផលត្រូវរៀបចំទិញនាវាល្បាតធុនធំ និងតូចមួយចំនួន រថយន្ត កុំព្យូទ័រ និងឧបករណ៍តាមដានដទៃទៀត (ម៉ាស៊ីនថត និងកែវយឺតមើលពេលយប់) (សូមមើលតារាងទី៥)។

ចំណុចសំខាន់មួយក្នុងចំណោមចំណុចសំខាន់នានានៃការត្រួតពិនិត្យគឺទីតាំងនាវានេសាទ។ ករណីនេះ ប្រព័ន្ធត្រួតពិនិត្យនាវានេសាទមានសារសំខាន់។ នាវានេសាទត្រូវបានត្រួតពិនិត្យ និងឃ្លាំមើលតាមពេលវេលាជាក់ស្តែងឬរយៈពេលខ្លីបន្ទាប់។ នាវានេសាទធ្វើនេសាទក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវបំពាក់ប្រព័ន្ធតាមដាននាវានេសាទ តាមផ្កាយរណប ដែលកំណត់ទីតាំង និងរក្សាទុកកស្តុតាងអនុលោមតាមលក្ខខណ្ឌជាក់លាក់ ដែលទទួលស្គាល់ដោយកិច្ចប្រជុំរបស់ភ្នាក់ងារជលផលប្រចាំតំបន់ប៉ាស៊ីហ្វិក។

វិធានការសម្រាប់អនុវត្តប្រព័ន្ធតាមដាននាវានេសាទសមុទ្រមានដូចខាងក្រោម៖

- ប្រព័ន្ធតាមដាននាវានេសាទតាមផ្កាយរណប ត្រូវបំពាក់សម្រាប់នាវានេសាទខ្នាតធំធ្វើនេសាទនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ
- ប្រព័ន្ធតាមដាននាវានេសាទតាមប្រព័ន្ធទូរស័ព្ទសម្រាប់នាវានេសាទខ្នាតមធ្យម និងខ្នាតធំត្រូវបំពាក់លើនាវានេសាទសមុទ្រធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់កម្ពុជា
- ប្រព័ន្ធតាមដាននាវានេសាទ មិនតម្រូវឱ្យបំពាក់ចំពោះនាវានេសាទខ្នាតតូច និងនាវានេសាទគ្រួសារ។

នាវានេសាទសមុទ្រភាគច្រើន ធ្វើនេសាទក្នុងតំបន់ដែលមានសេវាកម្មទូរស័ព្ទគ្របដណ្តប់។ ប្រព័ន្ធបញ្ជូនទូរស័ព្ទអាចដាក់នៅលើកោះដាច់ស្រយាលក៏ដូចជានៅលើនាវាល្បាត។ ព័ត៌មានលម្អិតបន្ថែមទៀតមាននៅក្នុងឧបសម្ព័ន្ធ៣។

### ២.២.២. សម្ភារសំខាន់ៗសម្រាប់ការឃ្លាំមើល

ការឃ្លាំមើលពីលើអាកាស គឺជាមធ្យោបាយមួយដ៏ល្អបំផុតក្នុងការប្រមូលព័ត៌មានអំពីសកម្មភាពនេសាទ ដើម្បីរៀបចំផែនការល្បាតដោយនាវា ប៉ុន្តែត្រូវចំណាយថវិកាច្រើន។ ដើម្បីធ្វើផែនការល្បាតដោយនាវាមានប្រសិទ្ធភាពការឃ្លាំមើលពីលើអាកាសត្រូវហោះហើរយ៉ាងតិចឱ្យបានពីរដងក្នុងមួយសប្តាហ៍។ សកម្មភាពនេះអាចត្រូវបានសម្របសម្រួលតាមរយៈគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។

រដ្ឋបាលជលផលគួរពិចារណាឱ្យបានដិតដល់លើការអនុវត្តប្រព័ន្ធឃ្លាំមើលនាវាជាមួយនឹងបន្ទប់ប្រតិបត្តិការ (សូមមើលអនុសាសន៍លើប្រព័ន្ធតាមដាននាវានេសាទខាងលើ)។

សម្ភារដែលមានសារសំខាន់ដែលស្នើឡើង និងថ្លៃដើមដែលត្រូវបានបង្ហាញមានដូចក្នុងតារាងទី៥ខាងក្រោម (ផ្នែកនៃតម្លៃវិនិយោគត្រូវកំណត់និងដេញថ្លៃដោយក្រុមហ៊ុនឯកជន)៖

តារាងទី ៥.តម្លៃទិញសម្ភារ

| ប្រភេទ | ធនធាន/សម្ភារដែលមានបច្ចុប្បន្ន | សម្ភារត្រូវការ | ចំនួនសម្ភារស្នើសុំទិញ | តម្លៃ | |
|---|---|---|---|---|---|
| | | | | តម្លៃសម្ភារ | តម្លៃសម្ភារ |
| នាវាល្បាតតាមបណ្ដោយព្រំដែន និងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | នាវាល្បាត២គ្រឿង ល្បឿនយឺត ល្បាតគ្មានប្រសិទ្ធភាព ពិបាកចាប់នាវានេសាទខុសច្បាប់។ មិនមានបំពាក់ឧបករណ៍ត្រួតពិនិត្យអេឡិចត្រូនិចដូចជារ៉ាដា គ្មានឧបករណ៍ធ្វើនាវាចរណ៍នៃឧបករណ៍ទំនាក់ទំនងទំនើប | នាវាមានប្រវែងពី២០-២៤ម៉ែត្រ សំបកអាលុយមីញ៉ូម។ មានគ្រែដេក១៤ ល្បឿន១៦ ណូត ល្បឿនអតិបរមា៖ ២២ណូត ប្រេងឥន្ធនៈ ៨០០០ (ធុងប្រេងឥន្ធនៈបន្ថែម ៥០០០លីត្រ) មានម៉ាស៊ីនត្រជាក់ នាវាសង្គ្រោះ៨,៥ម៉ែត្រ | នាវា១ គ្រឿង នាវិក៨នាក់ ដើម្បីល្បាតជាមួយមន្ត្រីជលផលពី ១២-១៥នាក់ | តម្លៃ៧-៨០០ ០០០ ដុល្លារ ផលិតផលក្នុងស្រុក។ សំបកអាលុយមីញ៉ូមជាមួយម៉ាស៊ីននាវាសមុទ្រ។<br>១០០ ០០០ដុល្លារ សម្រាប់រ៉ាដាទំនាក់ទំនង នាវាអធិការកិច្ច៨,៥ម៉ែត្រ និងឧបករណ៍ពន្លត់អគ្គីភ័យ។ | ៣៦០ ០០០ដុល្លារ/ឆ្នាំ ឬ៣០ ០០០ដុល្លារ/ខែ ដោយធ្វើប្រតិបត្តការ១៥ថ្ងៃក្នុង១ខែ។ ១០០លីត្រ/១ម៉ោង x ២ម៉ាស៊ីន = ២០០លីត្រ/ម៉ោង។ ១០ម៉ោង x ២០០លីត្រ = ២០០០លីត្រ /ថ្ងៃ ($1/liter)<br>តម្លៃចំណាយផ្សេងដែលមិនទាន់រួមបញ្ចូលមាន៖<br>- ថ្លៃជួសជុល ថែទាំ=៥០ ០០០ដុល្លារ/ឆ្នាំ<br>- ធានារ៉ាប់រង= គ្មាន<br>- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ=១៩នាក់ x ១០ថ្ងៃ x ១២ខែ x ៣៥ដុល្លារ= ៧៩ ៨០០ដុល្លារ/ឆ្នាំ |
| នាវាល្បាតនៅកន្លែងនេសាទតាមឆ្នេរ និងកន្លែងនេសាទសមុទ្រខាងក្រៅ | នាវាល្បាតតាមតំបន់ឆ្នេរចំនួន ៤គ្រឿង, ល្បឿនយឺតល្បាតគ្មានប្រសិទ្ធភាព ពិបាកចាប់នាវានេសាទខុសច្បាប់ | **ជម្រើសទី១.**<br>នាវាប្រវែង១៤ម៉ែត្រនិងមានកន្លែងស្នាក់នៅ | នាវាល្បាត៤គ្រឿងនៅកន្លែងនេសាទតាមឆ្នេរ មាននាវិក ៣នាក់និងមន្ត្រីជលផលពី៨-១២នាក់ក្នុងមួយគ្រឿង | ទិញនាវាល្បាតប្រើហើយ មានតម្លៃប្រហែល ២០០ ០០០-៥០០ ០០០ x ៤ គ្រឿង = ៨០០ ០០០ ដុល្លារ - ២ ០០០ ០០០ ដុល្លារ។<br>នាវាល្បាតសាងសង់ក្នុងស្រុកមានតម្លៃប្រហែល ៣០០ ០០០ដុល្លារ | ចំណាយ ៧២ ០០០ដុល្លារ x ៤គ្រឿង = ២៨៨ ០០០ដុល្លារ<br>ក្នុងមួយឆ្នាំ(៦ ០០០ដុល្លារ/ខែ និង១០ថ្ងៃក្នុងមួយខែ)<br>ប្រើប្រេង១០០លីត្រ/ម៉ោង (ប្រើម៉ាស៊ីនទាំងពីរ)<br>ប្រើ៦ម៉ោង /ថ្ងៃ = ៦០០ លីត្រ x ១ដុល្លា/លីត្រ = ៦០០ដុល្លា/ថ្ងៃ<br>តម្លៃចំណាយផ្សេងដែលមិនទាន់រួមបញ្ចូលមាន៖<br>-ថ្លៃជួសជុល ថែទាំ=៨០ ០០០ដុល្លា/ឆ្នាំ<br>-ធានារ៉ាប់រង= គ្មាន |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ=១៥នាក់ x ១០ថ្ងៃ x ១២ខែ x ៣៥ដុល្លារ = ៦៣ ០០០ដុល្លារ/ឆ្នាំ |
| | | **ជម្រើសទី២.** សាងសង់នាវាឈើថ្មីដែលមានប្រវែងពី១២-១៤ម៉ែត្រ។ នាវាឈើ ទាំងនេះអាចធ្វើល្បាតនៅតំបន់ការពារនិងដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យដោយភ្នែក | នាវាល្បាតឈើ២ នាវិក៣នាក់ក្នុងមួយគ្រឿង និងមានមន្ត្រីជលផលបានពី៨-១២នាក់ | ចំណាយ ៦០០ ០០០ ដុល្លារ (៣០០ ០០០ ដុល្លារក្នុងនាវានីមួយៗ) សាងសង់ក្នុងស្រុក | ចំណាយ១៤៤ ០០០ដុល្លា/ឆ្នាំ ឬ៦ ០០០ ដុល្លារក្នុងមួយខែ។ ល្បាត១០ថ្ងៃក្នុងមួយខែក្នុងមួយគ្រឿង៥០លីត្រ/ម៉ោង x ១២ម៉ោង / ថ្ងៃ x ២គ្រឿង x ១ដុល្លារ/លីត្រ = ១ ២០០ដុល្លារ/ថ្ងៃ |
| រថយន្តល្បាត | រថយន្តល្បាត១គ្រឿងសម្រាប់រដ្ឋបាលជលផល ១គ្រឿងសម្រាប់អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ និង ៤គ្រឿងសម្រាប់ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តតំបន់ឆ្នេរទាំង៤ | រថយន្តPick up កង់ 4x4 (អាចម៉ាកនីសាន់ ឬតូយ៉ូតា) | ៦គ្រឿង (១គ្រឿងសម្រាប់រដ្ឋបាលជលផល ១គ្រឿងសម្រាប់អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ និង ៤គ្រឿង) សម្រាប់ខណ្ឌរដ្ឋបាលជលផលខេត្តតំបន់ឆ្នេរទាំង៤) | ២៤០ ០០០ដុល្លារ (តម្លៃទិញ ៦គ្រឿង) | ចំណាយ៥៧ ៦០០ ដុល្លារក្នុងមួយឆ្នាំសម្រាប់រថយន្តទាំង៦។ ៩ ៦០០ដុល្លារ/ឆ្នាំក្នុងមួយរថយន្ត ឬ៨០០ដុល្លារ/ខែ។<br>ក្នុងមួយរថយន្ត (៤០លីត្រ/១ថ្ងៃ/គ្រឿង x ២០ថ្ងៃ x ១ដុល្លារ/លីត្រ = ៨០០ដុល្លារ / ខែ/គ្រឿង)<br>តម្លៃចំណាយផ្សេងដែលមិនទាន់រួមបញ្ចូលមាន៖<br>- ថ្លៃជួសជុល ថែទាំ=២ ៥០០ដុល្លារ/ឆ្នាំ/គ្រឿង x ៦គ្រឿង=១៥ ០០០ដុល្លា/ឆ្នាំ<br>- ធានារ៉ាប់រង=១២០០ដុល្លារ/គ្រឿង x ៦គ្រឿង = ៧ ២០០ដុល្លារ/ឆ្នាំ<br>- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ=៤នាក់ x ២០ថ្ងៃ x ១២ខែ x ៣៥ដុល្លារ=៣៣ ៦០០ដុល្លារ/ឆ្នាំ |
| ជួលយន្តហោះដើម្បីការឃ្លាំមើល | | | ៤ ០០០ដុល្លារ/ម៉ោង សម្រាប់មន្ត្រីអធិការ ២នាក់ | | ៤៣០ ០០០ដុល្លារ/ឆ្នាំ (ប៉ាន់ស្មានមធ្យម)<br>៥៧០ ០០០ដុល្លារ/ឆ្នាំ (ប៉ាន់ស្មានខ្ពស់) (១២ម៉ោង/ខែ)<br>២៨៨ ០០០ដុល្លារ/ឆ្នាំ (ប៉ាន់ស្មានតិច) (៦ម៉ោង/ខែ) |

| | | | | | |
|---|---|---|---|---|---|
| ប្រអប់ថ្មសម្រាប់ការពារនិងស្តារទីជម្រក | ប្រើចំនួន១០០០ប្រអប់ ប្រើថវិកាពីប្រភពខាងក្រៅ | ក្រុមហ៊ុនឯកជន ឬអង្គការ ឬដៃគូអភិវឌ្ឍន៍របស់រដ្ឋដើម្បីសង់ប្រអប់ថ្ម | ប្រហែល១០០០ប្រអប់ថ្ម | ៥០០ដុល្លារ/ប្រអប់ថ្ម ៥០០ ០០០ដុល្លារ សម្រាប់ការសាងសង់និងការដាក់ឱ្យប្រើប្រាស់ប្រអប់ថ្មចំនួន១០០០ | តម្លៃដឹកជញ្ជូនទម្លាក់ថ្មទៅក្នុងទឹក មានរួមបញ្ចូលក្នុងចំណាយធ្វើប្រអប់ថ្ម |
| ប្រព័ន្ធឃ្លាំមើលតាមដាន និងឃ្លាំមើលនាវានេសាទក្រៅដែនយុត្តាធិការជាតិ | មិនមានប្រព័ន្ធតាមដាននាវានេសាទនៅឡើយ មិនមានមន្ត្រីគ្រប់គ្រងបម្រើការក្នុងនាយកដ្ឋានថ្នាក់ជាតិ | ធ្វើលទ្ធកម្មនិងធ្វើកិច្ចសន្យាដំឡើងសម្រាប់អ្នកម៉ៅការ | ចំនួន១០ គ្រឿងដែលក្នុង១គ្រឿងតម្លៃ៣ ០០០ដុល្លារ | ការគ្រប់គ្រងបណ្តាញ និងតម្លៃប្រតិបត្តិការ ៦ ០០០ ដុល្លារ/នាវា។រដ្ឋបាលជលផលជាអ្នកទិញប្រព័ន្ធតាមដាននាវាតម្លៃ ១០០ ០០០/ប្រព័ន្ធ | ដាក់លើនាវា១០គ្រឿង |
| ប្រព័ន្ធតាមដាននាវានេសាទសម្រាប់នាវានេសាទមានគ្រែង (Satellite AIS) | | ធ្វើលទ្ធកម្ម និងធ្វើកិច្ចសន្យាដំឡើងសម្រាប់អ្នកម៉ៅការ | ៣០០០ គ្រឿង | ប្រហែល១ ០០០ ០០០ ដុល្លារ(ឧបករណ៍និងផ្នែកទន់ ៣០០ដុល្លារ/ឧបករណ៍) | ១០០ ០០០ដុល្លារ |
| ប្រព័ន្ធទូរស័ព្ទតាមដាននាវានេសាទ (GSM ទូរស័ព្ទដៃកម្មវិធី) | | ធ្វើលទ្ធកម្មនិងធ្វើកិច្ចសន្យាដំឡើងសម្រាប់អ្នកម៉ៅការ | ទាញយកកម្មវិធីសម្រាប់ដំឡើងGSM ចំនួន ៣ ០០០គ្រឿង | ចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ក្នុងតម្លៃប្រហែល ០,៥-១ លានដុល្លារដើម្បីទិញនិងដំឡើងឧបករណ៍ និងផ្តល់ឧបករណ៍សម្ភារ និងមូលដ្ឋានទិន្នន័យសម្រាប់ប្រព័ន្ធតាមដាននាវានេសាទនៅរដ្ឋបាលជលផល | ១០០ ០០០ដុល្លារ |

| | | | | | |
|---|---|---|---|---|---|
| ការិយាល័យតាមដាននិងឃ្លាំមើលនាវានេសាទ | | ធ្វើលទ្ធកម្ម និងទិញផ្នែករឹង (Hardwar) និងផ្នែកទន់ (Software) | មន្ត្រី៤ ទៅ ៦នាក់ | | |
| **សរុបតម្លៃ** | | | | តម្លៃជាក់ស្តែង<br>- ជម្រើសអប្បបរមាចំនួន ៤ ០០០ ០០០ដុល្លារ<br>- ជម្រើសអតិប្បរមាចំនួន ៦ ០០០ ០០០ដុល្លារ | តម្លៃជាក់ស្តែង ១ ៥០០ ០០០ដុល្លារ/ឆ្នាំ |

### ២.៣. ចុះបញ្ជីការកត់ត្រា និងការផ្តល់លិខិតអនុញ្ញាត

រដ្ឋបាលជលផល មិនអាចផ្តល់លិខិតអនុញ្ញាតឱ្យនាវានេសាទភាគច្រើន ស្របតាមច្បាប់ស្តីពីជលផលឆ្នាំ ២០០៦បាន ដោយសារការចុះបញ្ជីនាវានេសាទស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និង មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ។ ក្រសួងសាធារណការនិងដឹកជញ្ជូនបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ដើម្បីកែសម្រួលដំណើរការចុះបញ្ជីនាវានេសាទដែលមានភាពយឺតយ៉ាវ និងមិនទាន់ដឹងអនុម័តនៅពេលណា។ រដ្ឋបាលជលផលចាប់ផ្តើមកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ឬមន្ទីរសាធារណការនិងដឹកជញ្ជូនស្តីពីការចុះបញ្ជីនាវានេសាទ តាមរយៈក្រុមការងារបច្ចេកទេសរួមគ្នារវាងអង្គភាពទាំងពីរ។

#### ២.៣.១. ចុះបញ្ជី និងកត់ត្រានាវានេសាទដែលកំពុងធ្វើនេសាទក្នុងដែននេសាទសមុទ្រ

រដ្ឋបាលជលផលបានធ្វើជំរឿន ផ្តល់ប័ណ្ណសម្គាល់នាវា និងបំពាក់ស្លាកលេខជំរឿននាវានេសាទសមុទ្រនៅឆ្នាំ២០១៨។ ទិន្នន័យនេះត្រូវបានបញ្ចូលក្នុងមូលដ្ឋានទិន្នន័យ ហើយបង្កើតបានជាមូលដ្ឋានទិន្នន័យជាតិរបស់នាវានេសាទសមុទ្រ។ នាវានេសាទដែលទទួលបានប័ណ្ណសម្គាល់នាវា ត្រូវបានផ្តល់ជូននូវលិខិតអនុញ្ញាត។ រដ្ឋបាលជលផលនឹងបន្តកត់ត្រានាវានេសាទដែលមិនទាន់បានចុះបញ្ជី ឬមិនទាន់បានទទួលប័ណ្ណសម្គាល់នាវានេសាទ។

រដ្ឋបាលជលផលបានធ្វើចំណាត់ថ្នាក់នាវានេសាទសមុទ្រដូចខាងក្រោម៖

- នាវានេសាទខ្នាតធំ៖ មានប្រវែងសរុបលើសពី២៤ម៉ែត្រ
- នាវានេសាទខ្នាតមធ្យម៖ មានប្រវែងចាប់ពី១២ម៉ែត្រដល់២៤ម៉ែត្រ និងនាវានេសាទអួនអូសមានប្រវែងតិចជាង១២ម៉ែត្រ
- នាវានេសាទខ្នាតតូច៖ មានប្រវែងខ្លីជាង១២ម៉ែត្រ និងមិនរាប់បញ្ចូលនាវានេសាទអួនអូស
- នាវានេសាទគ្រួសារ ឬនេសាទប្រពៃណីគឺជានាវានេសាទគ្មានម៉ាស៊ីន។

#### ២.៣.២. ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ

រដ្ឋបាលជលផលត្រូវផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ ទោះបីជានាវាទាំងនោះមិនបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ដឹកជញ្ជូនតាមសមុទ្រ និងកំពង់ផែ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនក៏ដោយ ប្រសិនបើនាវាទាំងនោះមានប័ណ្ណសម្គាល់នាវាពីការធ្វើជំរឿននាវានេសាទសមុទ្រ។

រដ្ឋបាលជលផលត្រូវបង្កើតលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត និងផ្តល់លិខិតអនុញ្ញាតសម្រាប់នាវានេសាទដូចខាងក្រោម៖

ក. កំណត់ប្រភេទនាវានេសាទ (នាវានេសាទខ្នាតធំ ខ្នាតមធ្យមជាដើម។ល។) និងលក្ខខណ្ឌនៃឧបករណ៍នេសាទក្នុងលិខិតអនុញ្ញាត

ខ. កំណត់ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើ ទៅតាមតំបន់ ឬរដូវនេសាទ ឧទាហរណ៍គ្មានមងត្រីកាម៉ុងនៅលើនាវានេសាទនៅរដូវបិទនេសាទចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា

គ. រៀបចំប្រកាសដែលមានបញ្ជាក់ច្បាស់លាស់អំពីឧបករណ៍នេសាទស្របច្បាប់ និងឧបករណ៍នេសាទខុសច្បាប់ និងការអនុវត្តការនេសាទខុសច្បាប់ ជាពិសេសដូចជាការកែប្រែឧបករណ៍នេសាទអួនអូស ឧទាហរណ៍ដូចជា "កន្ទុយអួនប្រើសាច់អួន២ជាន់"។

បន្ទាប់មកទៀត រដ្ឋបាលជលផលថ្នាក់ជាតិ និងរដ្ឋបាលជលផលថ្នាក់ខេត្តត្រូវផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទដែលមានប័ណ្ណសម្គាល់នាវា តាមផែនការដូចខាងក្រោម៖

- ឆ្នាំទី១ ផ្តោតសំខាន់លើការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទដែលមានប្រវែងវែងជាង១៨ម៉ែត្រទាំងអស់ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០
- ឆ្នាំទី២ ក្នុងឆ្នាំ២០២១ ផ្តោតសំខាន់លើការបន្តផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទដែលមានប្រវែងខ្លីជាង១៨ម៉ែត្រទាំងអស់។ ផែនការសកម្មភាពផ្តល់លិខិតអនុញ្ញាតមានរៀបរាប់ក្នុងតារាងសកម្មភាពម៉ាទ្រីកទី៨។
- ចាប់ពីឆ្នាំទី៣ទៅទី៥ រដ្ឋបាលជលផលថ្នាក់ជាតិ និងរដ្ឋបាលជលផលថ្នាក់ខេត្ត ត្រូវបន្តផ្តល់លិខិតអនុញ្ញាតរាល់ឆ្នាំសម្រាប់នាវានេសាទដែលបានផ្តល់លិខិតអនុញ្ញាតកាលពីឆ្នាំកន្លងទៅ។

### ២.៣.៣. ការផ្តល់សៀវភៅកត់ត្រាស្ថិតិសម្រាប់នាវានេសាទខ្នាតធំនិងខ្នាតមធ្យម

នាវានេសាទភាគច្រើនមិនបានចុះបញ្ជីនាំឱ្យការគ្រប់គ្រងនាវានេសាទមិនបានល្អ។ ការកត់ត្រាទិន្នន័យនិងព័ត៌មានការនេសាទក្នុងសៀវភៅស្ថិតិគឺជាវិធីសាស្រ្តមួយមានអត្ថប្រយោជន៍។ បច្ចុប្បន្នរដ្ឋបាលជលផលបានផ្តល់សៀវភៅកត់ត្រាស្ថិតិចំពោះតែនាវានេសាទខ្នាតធំ និងខ្នាតមធ្យមនៅពេលផ្តល់លិខិតអនុញ្ញាត តែការអនុវត្តនៅមានកម្រិត។ ស្ថិតិផលនេសាទរបស់នាវានេសាទ ខ្នាតតូច និងនេសាទគ្រួសារនឹងត្រូវប្រមូលតាមការធ្វើសំណាក ឬការស្ទង់មតិដែលនឹងរៀបចំដោយរដ្ឋបាលជលផល (សូមពិនិត្យបន្ថែមក្នុងតារាងឧបសម្ព័ន្ធទី៤)។

**ការរៀបចំផែនការ និងអនុវត្តកម្មវិធីអង្កេតផលនេសាទ**

ផែនការអង្កេតផលនេសាទអាចគណនាបានផ្អែកតាមអនុសាសន៍ចំនួនដូចខាងក្រោម៖

-នាវានេសាទគ្រួសារជ្រើសរើសយកសំណាក ៥% សម្រាប់ប៉ាន់ប្រមាណផលនេសាទ ដើម្បីកាត់បន្ថយការចំណាយ ក្រុមអង្កេតផលនេសាទត្រូវបណ្តុះបណ្តាល និងលើកទឹកចិត្តដល់អ្នកនេសាទគ្រួសារ ធ្វើរបាយការណ៍ដោយខ្លួនឯងនូវផលនេសាទរបស់ខ្លួនក្នុងរយៈពេល២ដងក្នុងមួយឆ្នាំ ឧទាហរណ៍នៃប្រព័ន្ធទិន្នន័យរាយការណ៍ដោយខ្លួនឯង (ការប្រើប្រាស់បច្ចេកវិទ្យាទូរស័ព្ទចល័ត) គឺកម្មវិធី "Our Fish" ឬ "Abalobi"។ កម្មវិធីរាយការណ៍ដោយខ្លួនឯងមានអត្ថប្រយោជន៍ព្រោះវាដំណើរការក្នុងពេលជាក់លាក់គឺ"អ្នកប្រើត្រូវបង់លុយផ្ទាល់" ថ្លៃសេវាទូរស័ព្ទ គឺអ្នកនេសាទនឹងត្រូវចំណាយថ្លៃបញ្ជូនទិន្នន័យផលនេសាទហើយកម្មវិធីនេះអាចផ្តល់ទិន្នន័យសម្រាប់វាយតម្លៃស្តុក ប្រភេទផលនេសាទ ទីតាំងនាវា និងផលចាប់ក្នុងមួយឯកតា។ ជាទូទៅកម្មវិធីនេះប្រើបច្ចេកទេសបង្រួមទិន្នន័យ និងមានតម្លៃសមរម្យ។

-នាវានេសាទខ្នាតមធ្យម និងខ្នាតធំអាចអនុវត្តតាមកម្មវិធីអ្នកសង្កេតការណ៍ ប៉ុន្តែកម្រិតនៃការជ្រើសរើសសំណាកត្រូវមានកម្រិតទាបត្រឹម ២-៤% ក៏អាចតំណាងស្ថិតិផលនេសាទបាន ពីព្រោះនាវាទាំងនោះប្រើឧបករណ៍នេសាទប្រហាក់ប្រហែលគ្នា តំបន់នេសាទ និងកន្លែងស្តុកត្រីតែមួយ។ អ្នកសង្កេតការណ៍អាចមានចំនួន ២-៣% គឺមានលក្ខណៈសមស្របតាមវិទ្យាសាស្រ្ត និងតម្លៃសមរម្យ។ កម្មវិធីអ្នកសង្កេតការណ៍អាចត្រូវដាក់ឱ្យអនុវត្តជាជំហានៗ និងមានលក្ខណៈដូចគ្នា ចំពោះការធ្វើនេសាទ ក៏ដូចជាការស្នើសុំលិខិតអនុញ្ញាតធ្វើនេសាទ។

### ២.៣.៤. ការស្រង់ស្ថិតិ ផែនេសាទ និងកន្លែងឡើងផលនេសាទសាធារណៈ និងឯកជនទាំងអស់

ផែនេសាទ និងកន្លែងឡើងផលនេសាទសាធារណៈ និងឯកជនទាំងអស់ ត្រូវមានការអនុញ្ញាត និងលិខិតអនុញ្ញាត ប៉ុន្តែការផ្តល់លិខិតទាំងនេះមិនទាន់ដំណើរការល្អនៅឡើយទេ។ រដ្ឋបាលជលផលត្រូវស្រង់ស្ថិតិទីតាំងផែនេសាទ និងកន្លែងឡើងផលនេសាទសាធារណៈ និងឯកជនទាំងអស់ហើយដាក់ក្នុងរបាយការណ៍ប្រចាំឆ្នាំ។ ម្ចាស់ផែនេសាទ និងកន្លែងឡើងផលនេសាទសាធារណៈ និងឯកជនត្រូវបានលើកទឹកចិត្តឱ្យចុះបញ្ជីកន្លែងធ្វើអាជីវកម្មរបស់ពួកគេ។

## ២.៤. ព្រឹទ្ធការអនុវត្តច្បាប់ចំពោះឧបករណ៍នេសាទ និងតំបន់ហាមឃាត់តាមរយៈការធ្វើអធិការកិច្ច និងការដាក់ពិន័យ

### ២.៤.១. ការអនុវត្តយុទ្ធសាស្ត្រ ការអប់រំតាមរយៈការពិន័យ

បច្ចុប្បន្នការសង្កត់ធ្ងន់លើ "ការអប់រំ" ចំពោះអ្នកនេសាទខុសច្បាប់មិនមានប្រសិទ្ធភាព ដោយចំនួននៃការនេសាទអាយយូយូមិនបានថយចុះច្រើនទេ។ ទោះបីអ្នកនេសាទដឹងថាវិធានការអប់រំនេះត្រូវបានអនុវត្ត ដើម្បីការពារធនធានជលផលក៏ដោយ ក៏ការដាក់ទណ្ឌកម្មនៅមានកម្រិត ចំនួនសរុបនៃបទល្មើស និងការដាកពិន័យហាក់ដូចជាមានលក្ខណៈធម្មតា។ វិធីសាស្ត្រ "អប់រំជាមុន អនុវត្តច្បាប់តាមក្រោយ" ត្រូវតែបញ្ចប់ និងត្រូវជំនួសដោយ "ការអប់រំតាមរយៈការពិន័យ" ។

ក្នុងការអនុវត្តជាក់ស្តែង ការពិន័យបទល្មើសតាមរយៈសកម្មភាព ដែលមានចែងក្នុងជំពូកទី១៥ក្នុងច្បាប់ស្តីពីជលផល និងការអនុវត្តតាមការព្រមានមានន័យថា ឱ្យពួកគាត់ធ្វើកិច្ចសន្យាទទួលស្គាល់កំហុសឈប់ប្រព្រឹត្តម្តងទៀត។ ប៉ុន្តែ ការអនុវត្តរបៀបនេះមិនទទួលជោគជ័យក្នុងការកាត់បន្ថយការនេសាទអាយយូយូ ដូច្នេះការអនុវត្តកន្លងមកមិនមានប្រសិទ្ធភាពទេ។

ជំហានបន្ទាប់ការអប់រំតាមរយៈការផ្តន្ទាទោសត្រូវយកមកអនុវត្ត។ វិធីសាស្ត្រនៃការផ្តន្ទាទោសមួយដែលមានលក្ខណៈសមស្របគឺមិនមានចំណុចខ្សោយ មានការតាំងចិត្ត យកមកអនុវត្តជំនួសបណ្តើរៗ។ ការអនុវត្តត្រូវតែផ្តោតផងដែរ ក្នុងការធ្វើអធិការកិច្ច ចំពោះអ្នកប្រព្រឹត្តខុសច្បាប់នឹងត្រូវបានដាក់ទណ្ឌកម្ម ហើយអ្នកអនុវត្តច្បាប់ត្រូវបានអនុញ្ញាតឱ្យដំណើរការដោយគ្មានការរារាំង។

ប្រភេទបទល្មើសជលផលត្រូវផ្តោតលើករណីបទល្មើសធ្ងន់ធ្ងរ និងត្រូវអនុវត្តការត្រួតពិនិត្យ និងអធិការកិច្ចជាអាទិភាពដូចខាងក្រោម៖

- ជនប្រព្រឹត្តបទល្មើសដំបូងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ឧបករណ៍នេសាទខុសច្បាប់ទាំងអស់ត្រូវបានរឹបអូសនិងបំផ្លាញចោល
- ជនប្រព្រឹត្តបទល្មើសលើកទីពីរត្រូវពិន័យ និងឧបករណ៍នេសាទត្រូវបានបំផ្លាញ
- ជនប្រព្រឹត្តបទល្មើសមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ រឹបអូសនាវានេសាទ និងឧបករណ៍នេសាទ។

សំណើធ្វើវិសោធនកម្មច្បាប់ស្តីពីជលផលជំពូកទី១៥ ការដាក់ទោសទណ្ឌ ការដាក់ពិន័យ និងកែសម្រួលវិធានការរដ្ឋបាលនានាត្រូវស្នើឡើងដោយរដ្ឋបាលជលផល។

### ២.៤.២. កំណត់តំបន់នេសាទសម្រាប់នាវានេសាទអួនអូសនៅតាមតំបន់ឆ្នេរ និងការនេសាទក្នុងកន្លែងហាមឃាត់ និងកន្លែងអភិរក្ស (សូមអានអនុសាសន៍ស្តីពីការកំណត់ដែននេសាទក្នុងឧបសម្ព័ន្ធ២)

#### ក. សកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផល និងការរំលោភបំពានដែននេសាទដូចខាងក្រោម៖

- រដ្ឋបាលជលផល (នាយកដ្ឋានអភិរក្ស) និងខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការស្រាវជ្រាវដើម្បីកំណត់ទីតាំងផ្កាថ្ម និងស្មៅសមុទ្រ នៅតាមកន្លែងដែលមានផ្កាថ្ម និងស្មៅសមុទ្រ ដោយចាប់ផ្តើមប្រើវិធីសាស្ត្រសិក្សារបាយរបស់វា
- រដ្ឋបាលជលផល(នាយកដ្ឋានកិច្ចការជលផល) និងខណ្ឌរដ្ឋបាលជលផលត្រូវកំណត់ដែននេសាទដែលស្ថិតក្នុងខ្សែបន្ទាត់ដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ ដោយធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ ក្រុមនេសាទខ្នាតតូច ខ្នាតមធ្យម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំ

ផែនទីតំបន់នេសាទ សម្រាប់នាវានេសាទអួនអូសក្នុងខ្សែបន្ទាត់ដែលមានជម្រៅទឹករាក់ជាង២០ ម៉ែត្រ

- រដ្ឋបាលជលផលត្រូវទិញនាវាល្បាត រថយន្ត និងកុំព្យូទ័រ ដើម្បីបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យលើដី និងនៅសមុទ្រ
- រដ្ឋបាលជលផលត្រូវចាប់ផ្តើមអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ សម្រាប់នាវានេសាទ វែងជាង១២ ម៉ែត្រ និងនាវានេសាទអួនអូស។

**ខ. កែលម្អដែននេសាទឱ្យបានល្អប្រសើរក្នុងតំបន់ដែលមានហានិភ័យខ្ពស់**

រដ្ឋបាលជលផលត្រូវកំណត់តំបន់ដែលមានហានិភ័យខ្ពស់ដូចជាតំបន់ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង ដើម្បីគូសផែនទីទីតាំង និងដាក់ប្រអប់ថ្ម ឬបោះបង្គោលការពារ និងត្រូវធ្វើការត្រួតពិនិត្យឱ្យបានញឹកញាប់ទៅតាមផែនការកំណត់ (សូមអានឧបសម្ព័ន្ធ២ស្តីពីការកំណត់ដែននេសាទ ការប្រើប្រអប់ថ្ម និងជម្រើសនៃការការពារផ្សេងៗទៀត)

### ២.៤.៣. អនុវត្តសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ច

សកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចត្រូវអនុវត្តនៅលើសមុទ្រ លើដីគោក និងលើអាកាស។ វិធានការនេះគឺជាមធ្យោបាយតែមួយគត់ ដើម្បីធានាថាការនេសាទអាយយូយូអាចត្រូវបានរកឃើញបទល្មើសនេសាទ ទប់ស្កាត់ បង្ក្រាប និងពិន័យ។ សកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចខាងក្រោម គឺជាមូលដ្ឋាននៃការត្រួតពិនិត្យនិងអធិការកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

វិធានការត្រួតពិនិត្យដោយនាវាល្បាត គឺមានប្រសិទ្ធភាពបំផុត។ ចំណុចសំខាន់ៗដែលទទួលបានជោគជ័យដោយការត្រួតពិនិត្យតាមនាវាល្បាតមានដូចខាងក្រោម៖

- ពិនិត្យលិខិតអនុញ្ញាតនេសាទរបស់នាវានេសាទ
- ត្រួតពិនិត្យប្រព័ន្ធតាមដាននាវានេសាទខ្នាតមធ្យមនិងខ្នាតធំ
- រៀបចំប្រព័ន្ធឃ្លាំមើលនាវានេសាទ (មានមូលដ្ឋាននៅតាមឆ្នេរ និងក្នុងសមុទ្រក្រៅ)
- រៀបចំប្រព័ន្ធប្រមូលទិន្នន័យដែលមានសុក្រឹតភាពខ្ពស់ និងរៀបចំវិធីសាស្រ្តវាយតម្លៃផលស្តុកត្រី។

**ក. ការធ្វើអធិការកិច្ចដោយនាវានៅលើសមុទ្រ**

ការល្បាតដោយនាវាគឺជាវិធានការដ៏មានប្រសិទ្ធភាពមួយក្នុងការត្រួតពិនិត្យសកម្មភាពនេសាទនៅសមុទ្រ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូ។ ដើម្បីទទួលបានការត្រួតពិនិត្យ និងអធិការកិច្ចដែលមានប្រសិទ្ធភាពខ្ពស់នាវាល្បាតត្រូវតែមានតម្លៃសមរម្យ អាចស្ទាក់ចាប់និងគេចពីការគំរាមកំហែងនិងបង្ហាញឫទ្ធិអំណាច។ (ការពណ៌នាលម្អិតមាននៅជំពូកក្រោយ)។

នៅលើសមុទ្រ មន្ត្រីអធិការកិច្ចត្រូវត្រួតពិនិត្យការងារមួយចំនួនដូចខាងក្រោម៖

- ឯកសារចុះបញ្ជី លិខិតអនុញ្ញាត សៀវភៅនាវានេសាទ និងវិញ្ញាបនបត្រសមត្ថភាពរបស់ប្រធានក្រុមនាវា
- មុខងារប្រព័ន្ធតាមដាននាវា (ដំណើរការឬមិនដំណើរការ)
- សុខភាពនិងរបាយការណ៍អំពីអាកប្បកិរិយា អ្នកសង្កេតការណ៍
- ឧបករណ៍នេសាទ ដូចជាប្រភេទ ប្រវែងឬចំនួន ទំហំ ក្រឡា និងឯកសារភ្ជាប់
- ផលនេសាទ និងការវាយតម្លៃផលនេសាទ (បរិមាណ ទម្ងន់ ទំហំ និងផលចាប់បានចៃដន្យ) ដោយប្រៀបធៀបជាមួយសៀវភៅកត់ត្រាស្ថិតិ ឬការប្រកាសសុំចូលចត (ការធ្វើសំណាក)។ល។
- ផ្ទៀងផ្ទាត់នាវានេសាទដែលធ្វើចរាចរនៅលើផ្ទៃសមុទ្រដែលមានទង់ជាតិបរទេស។

**ខ. ការត្រួតពិនិត្យនៅលើដីគោក**

នៅលើដីគោកដូចជានៅផែនេសាទ កន្លែងឡើងផលនេសាទ កន្លែងផ្ទេរផលនេសាទ កន្លែងចុលចតបណ្តោះអាសន្ន ឬចុលចតអចិន្ត្រៃយ៍ មន្ត្រីអធិការកិច្ចត្រូវត្រួតពិនិត្យការងារមួយចំនួនដូចខាងក្រោម៖

- សុពលភាពនៃលិខិតអនុញ្ញាត
- ឯកសារចុះបញ្ជី លិខិតអនុញ្ញាត សៀវភៅនាវានេសាទ និងវិញ្ញាបនបត្រសមត្ថភាពរបស់ប្រធានក្រុមនាវា
- មុខងារប្រព័ន្ធតាមដាននាវា (ដំណើរការឬមិនដំណើរការ)
- សុខភាព និងរបាយការណ៍អំពីអាកប្បកិរិយាអ្នកសង្កេតការណ៍
- ឧបករណ៍នេសាទដូចជាប្រភេទ ប្រវែងឬចំនួន ទំហំ ក្រឡា និងឯកសារភ្ជាប់
- ផលនេសាទនិងការវាយតម្លៃផលនេសាទ (បរិមាណ ទម្ងន់ ទំហំ និងផលចាប់បានចៃដន្យ) ប្រៀបធៀបជាមួយសៀវភៅកត់ត្រាស្ថិតិឬប្រកាសសុំចុលចត (ការធ្វើសំណាក)។ល។
- លិខិតអនុញ្ញាតឱ្យដឹកជញ្ជូននិងការផ្ទេរផលនេសាទ
- នាវានេសាទបរទេសដោយអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងវិធានការរបស់រដ្ឋកំពង់ផែ
- សកម្មភាពនេសាទក្នុងតំបន់អនុញ្ញាត។ (កំណត់សម្គាល់៖ រដ្ឋបាលជលផលត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ខណ្ឌរដ្ឋបាលជលផល និងសមត្ថកិច្ច អាជ្ញាធរពាក់ព័ន្ធ ដើម្បីកំណត់តំបន់សម្រាប់នេសាទ។ ការកំណត់តំបន់នេសាទត្រូវអនុលោមតាមច្បាប់ស្តីពីជលផល។ (សូមមើលឧបសម្ព័ន្ធ២ស្តីពីការកំណត់កន្លែងនេសាទនិងប្រើប្រអប់ថ្ម)។

**ការធ្វើអធិការកិច្ចនៅទីផ្សារ និងរោងចក្រកែច្នៃផលនេសាទ**

នៅទីផ្សារ និងរោងចក្រកែច្នៃផលនេសាទការធ្វើអធិការកិច្ចត្រូវពិនិត្យចំណុចសំខាន់ៗដូចខាងក្រោម៖

- សុពលភាពនៃការអនុញ្ញាត ឬដំណើរការរបស់រោងចក្រ
- វិញ្ញាបនបត្រសុខភាព
- លិខិតអនុញ្ញាតដឹកជញ្ជូនផលនេសាទ
- ប្រវែង ឬទំហំត្រី
- ឯកសារនាំចូល ឬនាំចេញ ជាអាទិ៍ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមនៃផល ផលិតផលជលផល។

**ការត្រួតពិនិត្យកន្លែងនាំចូល និងនាំចេញ**

ការត្រួតពិនិត្យកន្លែងនាំចូល និងនាំចេញត្រូវពិនិត្យចំណុចសំខាន់ៗដូចខាងក្រោម៖

- ឯកសារនាំចូលឬនាំចេញ ជាអាទិ៍វិញ្ញាបនបត្របញ្ជាក់ប្រភពដើមនៃផល ផលិតផលជលផល
- ការអនុញ្ញាតពីអាជ្ញាធរសាយតេស្ត (ធនធានជលផលកំពុងរងគ្រោះថ្នាក់)

  វិញ្ញាបនបត្របញ្ជាក់ផលនេសាទ

**គ. ការត្រួតពិនិត្យនៅលើអាកាស**

ការឃ្លាំមើលពីលើអាកាសអាចនឹងត្រូវចំណាយច្រើន ប៉ុន្តែវាអាចជាមធ្យោបាយមួយល្អក្នុងការប្រមូលព័ត៌មានអំពីសកម្មភាពនេសាទ ដើម្បីរៀបចំផែនការល្បាត និងអនុវត្តការល្បាតនៅលើដី និងក្នុងសមុទ្រ។ ប្រសិនបើមានថវិកាគ្រប់គ្រាន់រដ្ឋបាលជលផលអាចជួលយន្តហោះ២ដងក្នុងមួយសប្តាហ៍ ថតសកម្មភាពនេសាទពីលើអាកាសនៅតាមឆ្នេរសមុទ្រ។ សកម្មភាពនេះត្រូវសហការសម្របសម្រួលតាមរយៈគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ។

## ២.៥. ចំណុចដៅនៃការត្រួតពិនិត្យ និងអធិការកិច្ច

ចំណុចដៅនៃការត្រួតពិនិត្យនិងអធិការកិច្ច គឺមានសារៈសំខាន់ក្នុងការវាស់វែងប្រសិទ្ធភាពនៃសកម្មភាពទាំងនោះ។ តារាងទី៦ បង្ហាញពីកម្រិតចំណុចដៅនៃការត្រួតពិនិត្យដែលអាជ្ញាធរខេត្ត (ខណ្ឌរដ្ឋបាលជលផល ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត) និងរដ្ឋបាលជលផល ត្រូវធ្វើការត្រួតពិនិត្យ និងអធិការកិច្ចឱ្យទទួលបានជោគជ័យ។

តារាងទី ៦.ចំណុចដៅនៃការធ្វើអធិការកិច្ច

| ចំណុចដៅនៃបទល្មើស ចំនួននាវា សកម្មភាពនេសាទ ឬកន្លែងនេសាទ ក្នុងខេត្តតំបន់ឆ្នេរនីមួយៗ (គិតជា%) | | | |
|---|---|---|---|
| **សកម្មភាព** | **ឆ្នាំ២០២០ (ឆ្នាំទី១)** | **២០២៤ (ឆ្នាំទី៥)** | **ទិន្នន័យដែលបានកត់ត្រាលើសកម្មភាពដែលបានអនុវត្តល្អជាងប្រព័ន្ធអេឡិចត្រូនិកដូចជា "Smart" ឬ "Abalobi"** |
| ការធ្វើអធិការកិច្ចនាវានេសាទនៅផែនេសាទ កន្លែងឡើង ឬកន្លែងផ្ទេរផលនេសាទដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ៥% នៃនាវាដែលត្រូវធ្វើអធិការកិច្ច | ៨០% ធ្វើអធិការកិច្ចក្នុងរយៈពេល ៥ឆ្នាំ | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ការធ្វើអធិការកិច្ចនាវានេសាទនៅសមុទ្រដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ៥%នៃនាវាដែលបានចុះបញ្ជីត្រូវធ្វើអធិការកិច្ច | ៨០% នៃនាវាដែលបានចុះបញ្ជីត្រូវធ្វើអធិការកិច្ចក្នុងរយៈពេល៥ឆ្នាំ | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគដោយការធ្វើអធិការកិច្ចនៅផែនេសាទ។ របាយការណ៍ដាក់ក្នុងគេហទំព័រវិធានការរដ្ឋម្ចាស់កំពង់ផែ |
| ធ្វើអធិការកិច្ចប្រព័ន្ធតាមដាននាវានេសាទអូនអូសទាំងអស់ នាវាខ្នាតមធ្យមដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ០% | ១០០%នៃនាវានេសាទ | ៨០% នៃនាវានេសាទទាំងអស់ត្រូវធ្វើអធិការកិច្ចក្នុងរយៈពេល៥ឆ្នាំ |
| ធ្វើអធិការកិច្ច និងលិខិតបញ្ជាក់ពីកន្លែងកែច្នៃផលនេសាទដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ៥% | ៥០%លិខិតបញ្ជាក់ពីកន្លែងកែច្នៃផលនេសាទក្នុងរយៈពេល៥ឆ្នាំ | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់ និងវិភាគ។ ៥០%នៃកន្លែងកែច្នៃផលនេសាទត្រូវបានធ្វើអធិការកិច្ចក្នុងរយៈពេល៥ឆ្នាំ |
| ល្បាតនិងត្រួតពិនិត្យកន្លែងនេសាទសហគមន៍ដោយខណ្ឌរដ្ឋបាលជលផល | ១០%កន្លែងនេសាទសហគមន៍ត្រូវបានត្រួតពិនិត្យ | ៨០%នៃនាវានេសាទ | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់ និងវិភាគ។ ៨០%នៃតំបន់សហគមន៍នេសាទត្រូវបានធ្វើអធិការកិច្ចក្នុងរយៈពេល៥ឆ្នាំ |
| រៀបចំ និងអនុវត្តប្រព័ន្ធចុះបញ្ជីនាវានេសាទទាំងអស់ដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ០% | ១០០%នៃនាវានេសាទ | ការទំនាក់ទំនងជាមួយក្រសួងសាធារណការ និងដឹកជញ្ជូននិងរបាយការណ៍ពីខណ្ឌរដ្ឋបាលជលផលប្រៀបធៀបជាមួយជាមួយទិន្នន័យជំរឿន |
| រៀបចំ និងអនុវត្តប្រព័ន្ធផ្តល់លិខិតអនុញ្ញាតទាំងអស់ដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ០% | ១០០%នៃនាវានេសាទ | រដ្ឋបាលជលផល និងរដ្ឋបាលជលផលថ្នាក់ខេត្ត បញ្ចប់ការផ្តល់លិខិតអនុញ្ញាត |

## ២.៦. ការជ្រើសរើសលក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើអធិការកិច្ច

តារាងទី៧ បង្ហាញការកំណត់និយមន័យនៃលក្ខណៈវិនិច្ឆ័យដើម្បីវាយតម្លៃកម្រិតហានិភ័យនៃការមិនអនុវត្តតាម(ទម្រង់ហានិភ័យ)ដើម្បីកំណត់ "កម្រិតគ្រោះថ្នាក់" សម្រាប់នាវានេសាទ (ហានិភ័យខ្ពស់ ហានិភ័យមធ្យម និងហានិភ័យទាប)។

ភាគច្រើននៃសកម្មភាពទាំងនេះ ត្រូវបានធ្វើឡើងក្នុងពេលធ្វើអធិការកិច្ចនៅតាមទីតាំងនាវានេសាទដោយមានការផ្ទៀងផ្ទាត់ខ្លះៗ ដោយមន្ត្រីដែលមានការិយាល័យនៅថ្នាក់ជាតិ។

តារាងទី ៧.ចំណាត់ថ្នាក់នៃការវាយតម្លៃហានិភ័យ

| **សកម្មភាព** | **ទម្រង់ហានិភ័យ** | **សកម្មភាពត្រួតពិនិត្យបទល្មើស** |
|---|---|---|
| | ទាប ឬមធ្យម ឬខ្ពស់ | ចំណាំ ឬត្រួតពិនិត្យ |
| ការអនុវត្តច្បាប់ពីមុន និងប្រវត្តិអធិការកិច្ចនៃនាវានេសាទ ប្រធាននាវា កន្លែងកែច្នៃ អ្នកនាំចូល ឬអ្នកនាំចេញ | **ទាប** មិនមានកំណត់ត្រានៃការរំលោភបំពាន<br>**មធ្យម** ការរំលោភតិចជាង៣ ដងក្នុងរយៈពេល៥ឆ្នាំកន្លងមក<br>**ខ្ពស់** ការរំលោភបំពានច្រើនជាង៣ ដងក្នុងរយៈពេល ៥ឆ្នាំកន្លងមក | **ប្រសិនបើទាប** កត់ចំណាំតែប៉ុណ្ណោះ<br>**ប្រសិនបើមធ្យម** ពិនិត្យមើលថាតើពេលវេលាអនុញ្ញាតឱ្យនិងមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយដែលបានរកឃើញ<br>**ប្រសិនបើខ្ពស់** ធ្វើអធិការកិច្ច |
| ការយល់ដឹងអំពីបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗ | មធ្យម ឬខ្ពស់ | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង<br>ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| របាយការណ៍បទល្មើសពីអ្នកអនុវត្តច្បាប់ ឬរបស់គណៈកម្មការ សហគមន៍នេសាទ | ខ្ពស់ | ធ្វើអធិការកិច្ច |
| ការប្រើឧបករណ៍នេសាទហាមឃាត់ ឬកន្លែងនេសាទហាមឃាត់សម្រាប់នាវានេសាទខ្នាតធំ | ខ្ពស់ | ធ្វើអធិការកិច្ច |
| ការប្រើឧបករណ៍នេសាទហាមឃាត់ ឬកន្លែងនេសាទហាមឃាត់សម្រាប់នាវានេសាទខ្នាតមធ្យម និងខ្នាតតូច | ទាប ឬមធ្យម | ប្រសិនបើទាប - កត់ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង |
| ការផ្ទៀងផ្ទាត់ឯកសារនិងលទ្ធផលត្រួតពិនិត្យជាក់ស្តែង (ឧ. ផលនេសាទមិនត្រូវតាមឧបករណ៍នេសាទ) | ប្រហាក់ប្រហែលគ្នា- ទាប<br>ខុសគ្នាតិចតួច -មធ្យម<br>ភាពមិនស្របគ្នា - ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង<br>ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ការពិនិត្យភាពជឿជាក់និងភាពត្រឹមត្រូវនៃឯកសារចាំបាច់ជាពិសេសសៀវភៅកត់ត្រាស្ថិតិ | ប្រហាក់ប្រហែលគ្នា- ទាប<br>ខុសគ្នាតិចតួច -មធ្យម<br>ភាពមិនស្របគ្នា - ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ |

| | | |
|---|---|---|
| | | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង<br>ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ការធ្វើនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ | ទាប / មធ្យម / ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង<br>ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ការធ្វើនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ | មធ្យម ឬខ្ពស់ | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង |
| ការធ្វើនេសាទនៅជិតព្រំដែននៃតំបន់អភិរក្សនិងការការពារនិងនៅជិតព្រំដែន | ខ្ពស់ | ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ពិនិត្យប្រភពដើមនាវា - ក្នុងស្រុក | ទាប / មធ្យម | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង |
| ពិនិត្យប្រភពដើមនាវា (ទង់ជាតិបរទេស) | ខ្ពស់ | ធ្វើអធិការកិច្ច |
| ពិនិត្យបរិមាណផលនេសាទចូលចត | ទាប ឬមធ្យម | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង |
| ពិនិត្យបរិមាណផលនេសាទដែលបានចូលចត (ដោយនេសាទឬផ្ទេរ) | ខ្ពស់ | ធ្វើអធិការកិច្ច |
| ពិនិត្យប្រភេទនិងតម្លៃនៃត្រីដែលបាននាំចូលឬកែច្នៃ | មធ្យម ឬខ្ពស់ | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង<br>ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ពិនិត្យប្រភេទនិងភាពជឿជាក់នៃឧបករណ៍តាមដានអេឡិចត្រូនិច (ឧ. ប្រព័ន្ធតាមដានត្រួតពិនិត្យនាវានេសាទ) | ប្រហាក់ប្រហែលគ្នា- ទាប<br>ខុសគ្នាតិចតួច -មធ្យម<br>ភាពមិនស្របគ្នា - ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ<br>ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល<br>ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ពិនិត្យបរិមាណនេសាទធៀបនឹងនាវានេសាទនិងឧបករណ៍ | ប្រហាក់ប្រហែលគ្នា - ទាប<br>ខុសគ្នាតិចតួច - មធ្យម<br>ភាពមិនស្របគ្នា - ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ |

| | | |
|---|---|---|
| នេសាទនៅពេលចេញនេសាទ (មិនបានរាយការណ៍អស់) | | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង |
| ពិនិត្យបរិមាណផលនេសាទធៀបនឹងទិន្នន័យពីអ្នកសង្កេតការណ៍ | ប្រហាក់ប្រហែលគ្នា - ទាប ខុសគ្នាតិចតួច - មធ្យម ភាពមិនស្របគ្នា - ខ្ពស់ | ប្រសិនបើទាប - ចំណាំតែប៉ុណ្ណោះ ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ត្រួតពិនិត្យរដូវបិទនេសាទ | ខ្ពស់ | ធ្វើអធិការកិច្ច |
| កំណត់តំបន់ដែននេសាទនិងតំបន់បិទនេសាទតាមរដូវ | ខ្ពស់ | ធ្វើអធិការកិច្ច |
| ការសាកសួរពីរដ្ឋមន្ត្រី ឬពីរដ្ឋសភា | មធ្យម ឬខ្ពស់ | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |
| ពិនិត្យរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយស្តីពីការនេសាទអាយយូយូ | មធ្យម ឬខ្ពស់ | ប្រសិនបើមធ្យម - ធ្វើអធិការកិច្ចបើមានពេល ប្រសិនបើមិនមានសកម្មភាពហានិភ័យខ្ពស់ណាមួយកើតឡើង ប្រសិនបើខ្ពស់ - ធ្វើអធិការកិច្ច |

## ៣. ផែនការសកម្មភាពសម្រាប់ការត្រួតពិនិត្យ និងអធិការកិច្ចបទល្មើសជលផលក្នុងដែននេសាទសមុទ្រ

### ៣.១. សកម្មភាពអាទិភាព

សកម្មភាពអាទិភាព ៥ ដែលចាំបាច់ត្រូវអនុវត្តដោយក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ និងក្រុមការងារបង្ក្រាបបទល្មើសជលផលថ្នាក់ខេត្ត ដើម្បីធានាថាការនេសាទអាយយូយូត្រូវបានកាត់បន្ថយ និងការពង្រឹងការអនុវត្តច្បាប់។ សកម្មភាពអាទិភាពមានដូចខាងក្រោម៖

- ពង្រឹងការគ្រប់គ្រងរដ្ឋបាល
- ការបញ្ជាទិញឧបករណ៍តាមដាន ត្រួតពិនិត្យ និងឃ្លាំមើល
- ពង្រឹងការអនុវត្តការចុះបញ្ជី/ការស្រង់ស្ថិតិនិងការផ្តល់លិខិតអនុញ្ញាត
- ពង្រឹងការអនុវត្តច្បាប់ស្តីពីឧបករណ៍នេសាទ និងតំបន់ការពារ
- ពង្រឹងការត្រួតពិនិត្យការនាំចូល នាំចេញផល ផលិតផលជលផលសមុទ្រ។

ផែនការសកម្មភាពលម្អិតមានក្នុងឧបសម្ព័ន្ធ១ ដែលអាចប្រើជាគំរូការអនុវត្ត។

តារាងម៉ាទ្រីកទី៨ខាងក្រោមកំណត់នូវសកម្មភាព និងពេលវេលាក្នុងរយៈពេល៥ឆ្នាំ ដែលមានក្នុងផែនការសកម្មភាព ត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ។

តារាងទី ៨.តារាងម៉ាទ្រីកសកម្មភាពសំខាន់ៗត្រូវអនុវត្តនៃផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រមានរៀបរាប់ដូចខាងក្រោម៖

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | **១. គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងការគ្រប់គ្រងរដ្ឋបាល** | | | | | | | |
| | **១.១. បង្កើតការិយាល័យតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានប្រសិទ្ធភាពខ្ពស់** | | | | | | | |
| ១ | បង្កើតក្រុមការងារគ្រប់គ្រងតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិដើម្បីត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព ត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ និងលទ្ធផលសម្រេចបាន | ស្នើសុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងកសិកម្ម ដើម្បីបង្កើតការិយាល័យដែលបំពេញភារកិច្ចដោយមន្ត្រីរដ្ឋបាលជលផល | ក្រុមការងារតាមដានត្រួតពិនិត្យ និងឃ្លាំមើលជាតិបានបង្កើតឡើង | | | | | រដ្ឋបាលជលផល |
| ២ | បង្កើតក្រុមការងារគ្រប់គ្រងតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្តដើម្បីត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព ត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ និងលទ្ធផលសម្រេចបានកម្រិតខេត្ត | ស្នើសុំការសម្របសម្រួលជាមួយអភិបាលខេត្តដើម្បីបង្កើតផ្នែកតាមដានត្រួតពិនិត្យ និងឃ្លាំមើល ដែលបំពេញភារកិច្ច ដោយមន្ត្រីខណ្ឌរដ្ឋបាលជលផល | ផ្នែកគ្រប់គ្រង តាមដានត្រួតពិនិត្យ និងឃ្លាំមើល ខេត្តត្រូវបានបង្កើតឡើងក្នុងខេត្តតំបន់ឆ្នេរសមុទ្រទាំង៤ | | | | | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផលកែប កំពត ខេត្តព្រះសីហនុ និងកោះកុង |
| | **១.២. បង្កើតក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់** | | | | | | | |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ៣ | ក្រុមការងារតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ជាតិបង្កើតក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់នឹងធ្វើប្រតិបត្តិការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលនៅទូទាំងប្រទេស | កិច្ចប្រជុំប្រចាំត្រីមាសនៅរាជធានីភ្នំពេញ | | ក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់ត្រូវបានបង្កើត | | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផល |
| | **១.៣. បង្កើតក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត** | | | | | | | |
| ៤ | ក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត ។ ក្រុមបង្ក្រាបបទល្មើសជលផលថ្នាក់ខេត្តធ្វើប្រតិបត្តិការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលសកម្មភាពនៅទូទាំងខេត្តតំបន់ឆ្នេរ | កិច្ចប្រជុំប្រចាំត្រីមាសជាមួយតំណាងរដ្ឋបាលជលផលនៅតាមខេត្តតំបន់ឆ្នេរ | | ក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្តត្រូវបានបង្កើត | | | | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតំបន់ឆ្នេរទាំង៤ ខណ្ឌរដ្ឋបាលជលផលកែប កំពត ខេត្តព្រះសីហនុ និងកោះកុង |
| | **២. គោលដៅយុទ្ធសាស្ត្រទី២៖ ការបញ្ជាទិញឧបករណ៍តាមដាន ត្រួតពិនិត្យ និងឃ្លាំមើល** | | | | | | | |
| | **២.១. ការបញ្ជាទិញនាវាល្បាត** | | | | | | | |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ៥ | បញ្ហាទិញនាវាល្បាតធំ១ និងនាវាល្បាតតូច១៤គ្រឿង | រដ្ឋបាលជលផលត្រូវបញ្ចប់បច្ចេកទេសនៃការបញ្ហាទិញនាវាល្បាត។ការងារទាំងនេះរួមមានលក្ខណៈនៃការសាងសង់នាវា ឧទាហរណ៍ ការកំណត់បញ្ជាក់របស់អ្នស្ត្រាលីសម្រាប់នាវាពាណិជ្ជកម្ម។ ការផលិតជាក់លាក់នៃសមាសភាគសំខាន់នៃនាវាក្រៅពីម៉ាស៊ីន ប្រអប់លេខ វ៉ាដា វិទ្យុទាក់ទង ម៉ាស៊ីនភ្លើង ឧបករណ៍សម្រាប់ធ្វើអធិការកិច្ចជាក់លាក់សម្រាប់នាវាល្បាតធំ។ ការធានាក្នុងការសាងសង់ គុណភាព ពេលវេលាប្រគល់ | លក្ខណៈបច្ចេកទេសសំខាន់ៗនៃនាវាល្បាតត្រូវបានកំណត់ និងឯកភាពជាផ្លូវការ។ | លក្ខណៈជាក់លាក់នៃការសាងសង់ជាក់លាក់ឧទាហរណ៍ការកំណត់បញ្ជាក់របស់អូស្ត្រាលីសម្រាប់នាវាពាណិជ្ជកម្ម។ ការផលិតជាក់លាក់នៃសមាសភាគសំខាន់នៃនាវាក្រៅពីម៉ាស៊ីនប្រអប់លេខ វ៉ាដា វិទ្យុទាក់ទងសកម្ម ម៉ាស៊ីនភ្លើងឈរ ឧបករណ៍សម្រាប់ធ្វើអធិការកិច្ចជាក់លាក់សម្រាប់នាវាល្បាតធំ។ ការធានាក្នុងការកសាងគុណភាពពេលវេលានិងការដឹកជញ្ជូននិងដំណើរ | | | | រដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | និងការដឹកជញ្ជូន ផ្លូវនាវាចរសមុទ្រដែលសមស្រប និងដំណើរការ (១៥ឆ្នាំ) ដែលអាចរកបាននៃគ្រឿងបន្លាស់នៃផ្នែកសំខាន់ៗ | | ការ (១៥ ឆ្នាំ) ដែលអាចរកបាននៃគ្រឿងបន្លាស់នៃសមាសភាគផ្នែកសំខាន់ៗ | | | | |
| | ដំណើរការលទ្ធកម្ម | | ដំណើរការលទ្ធកម្មត្រូវបានអនុម័ត | ដំណើរការដេញថ្លៃបានបញ្ចប់ហើយដេញថ្លៃត្រូវបានវិនិច្ឆ័យនិងទទួលបាន | ការដឹកជញ្ជូននាវាល្បាតតូចចំនួន២ | ការដឹកជញ្ជូននាវាល្បាតធំ១ និងនាវាល្បាតតូចចំនួន២ | | |
| | ២.២.បង្កើតប្រព័ន្ធទូរស័ព្ទដៃតាមដាននាវានេសាទ GSM (Goble System for Mobile communications) | | | | | | | |
| ៦ | ប្រកាសដេញថ្លៃប្រព័ន្ធតាមដាននាវានេសាទ | ការបញ្ជាទិញប្រព័ន្ធទូរស័ព្ទដៃតាមដានាវា (GSM) ត្រូវបានយល់ព្រមនិងដេញថ្លៃ ។ អ្នកផ្តល់សេវាត្រូវផ្តល់ជួយរៀបចំបន្ទប់ប្រតិបត្តិការ២៨ម៉ោង | ដំណើរការលទ្ធកម្មត្រូវបានអនុម័ត | ដំណើរការលទ្ធកម្មត្រូវបានដំណើរការជាក់ដេញថ្លៃ | ប្រព័ន្ធតាមដាននាវាតាមទូរស័ព្ទដៃចាប់ផ្តើមដំណើរការ | ប្រព័ន្ធតាមដាននាវាតាមទូរស័ព្ទដៃ បន្តដំណើរការ | ប្រព័ន្ធតាមដាននាវាតាមទូរស័ព្ទដៃ rollout concluded | រដ្ឋបាលជលផល នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម នាយកដ្ឋានកិច្ចការជលផល អធិការដ្ឋានសមុទ្រ ខណ្ឌរដ្ឋបាលជលផលទាំង៤ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | អ្នកផ្ដល់សេវាត្រូវធានាជួយរៀបចំដំឡើងឧបករណ៍ តាមដាន (៣០០០ ឧបករណ៍) ត្រូវរៀបចំផែនការនិងអនុវត្តប្រព័ន្ធGSM ត្រូវគ្រប់គ្រងកិច្ចសន្យាទូរស័ព្ទចល័តឧបករណ៍តាមដាននានាគឺជាក់ដេញថ្លៃ។ អ្នកផ្ដល់សេវាគឺជាក្រុមហ៊ុនមួយដៃគូជាមួយក្រុមហ៊ុនក្នុងស្រុករក្សាវត្តមាននិងផ្ដល់ការគាំទ្រសម្រាប់រយៈពេលនៃការដំឡើងឧបករណ៍តាមដាននានា នឹងប្រតិបត្តិការរហូតដល់ចុងឆ្នាំ ២០២៣។ | | | | | | |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ៧ | ចាប់ផ្តើមរៀបចំបន្ទប់ប្រតិបត្តិការ ឧបករណ៍តាមដាននាវា | រដ្ឋបាលជលផលត្រូវជ្រើសរើសមន្ត្រីធ្វើការក្នុងបន្ទប់ប្រតិបត្តិការតាមវេន២៤ម៉ោង/៧ថ្ងៃ។ បន្ទប់ប្រតិ-បត្តិការត្រូវបំពាក់ឧបករណ៍បរិក្ខារប្រតិបត្តិការផ្នែកទន់ និងផ្នែករឹង (ផ្តល់ដោយអ្នកផ្តល់សេវាឧបករណ៍តាមដាន និងមានម៉ូនីទ័រ៣ កុំព្យូទ័រ និងអ៊ីនធឺណេតល្បឿនលឿន។ ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីអំពីទិន្នន័យ ឧបករណ៍តាមដាននាវា ការថតរូបនិងការទំនាក់ទំនង | ដំណើរការលទ្ធកម្មត្រូវបានអនុម័ត | បន្ទប់ប្រតិបត្តិការ ឧបករណ៍តាមដាននាវា ត្រូវបានបង្កើតឡើង | | | | រដ្ឋបាលជលផល |
| ៨ | ឧបករណ៍តាមដាននាវា បានអនុវត្តសម្រាប់នាវានេសាទ | អ្នកផ្តល់សេវាកម្មត្រូវចាត់តាំងក្រុមការងារ | | | ដំឡើងឧបករណ៍តាម | បន្តដំឡើងឧបករណ៍តាម | បន្តដំឡើងឧបករណ៍តាម | រដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ការកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | ខ្នាតមធ្យម និងខ្នាតធំ នឹងធ្វើការដំឡើងជាបន្តបន្ទាប់ | ដើម្បីសាកសួរពីនីតិវិធីដំឡើងនិងកម្មវិធីផ្នែកប្រតិបត្តិការនិងផ្នែករឹង ។ បន្ទាប់មកអ្នកផ្ដល់សេវាកម្មគួរតែបើកដំណើរការការដំឡើងជាបន្តបន្ទាប់ | | | ជាននាវាដោយចាប់ផ្ដើមជាមួយនាវានេសាទខ្នាតធំ | ជាននាវានេសាទដែលមានប្រវែងចាប់ពី១២ដល់២៤ម៉ែត្រ | ជាននាវាដល់នាវានេសាទអូនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រ | នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម នាយកដ្ឋានកិច្ចការជលផល អធិការដ្ឋានសមុទ្រ ខណ្ឌរដ្ឋបាលជលផលទាំង៤ |
| **៣. គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងការអនុវត្តការចុះបញ្ជី/ការស្រង់ស្ថិតិនិងការផ្ដល់លិខិតអនុញ្ញាត** | | | | | | | | |
| ៣.១. ការចុះបញ្ជីនិងការផ្ដល់លិខិតអនុញ្ញាត | | | | | | | | |
| ៩ | មូលដ្ឋានទិន្នន័យត្រូវបានបង្កើតឡើងដើម្បីកត់ត្រានាវានេសាទសមុទ្រទាំងអស់ | បំប្លែងមូលដ្ឋានទិន្នន័យជំរឿនទៅជាមូលដ្ឋានគ្រឹះដែលកត់ត្រាទិន្នន័យនិងព័ត៌មាននាវានេសាទ រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែទទួលបាន | ៦០%អាចបំប្លែងមូលដ្ឋានទិន្នន័យជំរឿនទៅជាមូលដ្ឋានគ្រឹះទាក់ទងគ្នា ។ រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រនិងកំពង់ផែទទួលបានសិទ្ធិ | ទិន្នន័យស្ដីពីការផ្ដល់លិខិតអនុញ្ញាតបន្ថែមទៅមូលដ្ឋានទិន្នន័យ | មូលដ្ឋានទិន្នន័យដំណើរការ និងអាចស្វែងរកបានដោយអ្នកត្រួតពិនិត្យនៅលើដីគោក | មូលដ្ឋានទិន្នន័យដំណើរការនិងអាចស្វែងរកបានដោយអ្នកត្រួតពិនិត្យលើដីគោកនិងសមុទ្រ | មូលដ្ឋានទិន្នន័យអាចចែករំលែកជាមួយប្រព័ន្ធឧបករណ៍តាមដាននាវា ដើម្បីធានាប្រសិទ្ធភាពនៃការត្រួតពិនិត្យនាវានេសាទទាំងអស់លើឧបករណ៍តាមដាននាវា ដែល | រដ្ឋបាលជលផល នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម នាយកដ្ឋានកិច្ចការជលផល នាយកដ្ឋានផែនការស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ អធិការដ្ឋានសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤។ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | សិទ្ធិចូលទៅពិនិត្យមូលដ្ឋានទិន្នន័យ | ពិនិត្យមូលដ្ឋានទិន្នន័យ | | | | មានក្នុងមូលដ្ឋានទិន្នន័យ | នាយកដ្ឋានកិច្ចការជលផល ជាអ្នកគ្រប់គ្រងទិន្នន័យ |
| ១០ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តផ្តល់ "លិខិតបញ្ជាក់កំណត់ត្រា"ដល់នាវានេសាទខ្នាតតូចដែលមានប្រវែងខ្លីជាង១២ម៉ែត្រដែលមិនមែនជានាវាអូនអូស | ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងលិខិតបញ្ជាក់ កំណត់ត្រាដល់នាវានេសាទ | | | "វិញ្ញាបនបត្រកំណត់ត្រា" បានផ្តល់៥០% នៃនាវាខ្នាតតូចដែលមានប្រវែងខ្លីជាង១២ម៉ែត្រ ដែលមិនមែនជានាវាអូនអូសក្នុងខេត្តតំបន់ឆ្នេរទាំង៤ | "វិញ្ញាបនបត្រកំណត់ត្រា" បានផ្តល់១០០%នៃនាវាខ្នាតតូចដែលមានប្រវែងខ្លីជាង១២ម៉ែត្រដែលមិនមែនជានាវាអូនអូសក្នុងខេត្តតំបន់ឆ្នេរទាំង៤ | | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតំបន់ឆ្នេរ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ |
| | ៣.២. ផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទទាំងអស់ | | | | | | | |
| ១១ | ផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទខ្នាតមធ្យម ដែលមានប្រវែងវែងជាង១៨ម៉ែត្រទាំងអស់ | រៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទ | ផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរ | នាវានេសាទខ្នាតមធ្យម ដែលមានប្រវែងវែងជាង១៨ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត | បញ្ចប់ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទខ្នាតមធ្យម ដែល | | | រដ្ឋបាលជលផល នាយកដ្ឋានកិច្ចការជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | | ទាំង៤ត្រូវបានរៀបចំ | | មានប្រវែងវែងជាង១៨ម៉ែត្រទាំងអស់ | | | |
| | | "ក្រុមផ្តល់លិខិតអនុញ្ញាត" មានពី "៣-៥"នាក់។ ក្រុមផ្តល់លិខិតអនុញ្ញាតត្រូវមានពី២ ទៅ ៣ក្រុម | ក្រុមផ្តល់លិខិតអនុញ្ញាតត្រូវបានតែងតាំង | លិខិតអនុញ្ញាតដល់នាវានេសាទត្រូវបានផ្តល់ | លិខិតអនុញ្ញាតដល់នាវានេសាទត្រូវបានផ្តល់ | | | |
| ១២ | ផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទខ្នាតមធ្យម ដែលមានប្រវែង១២ម៉ែត្រ ទៅ១៨ម៉ែត្រទាំងអស់ | ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទ | ផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរទាំង៤ត្រូវបានផ្តល់ | | នាវានេសាទទាំងអស់ដែលមានប្រវែង១២ម៉ែត្រ ទៅ១៨ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត និងសៀវភៅកត់ត្រាស្ថិតិ | នាវានេសាទទាំងអស់ដែលមានប្រវែង១២ម៉ែត្រទៅ១៨ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត និងសៀវភៅកត់ត្រាស្ថិតិ | | រដ្ឋបាលជលផលនាយកដ្ឋានកិច្ចការជលផល ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ |
| | | "ក្រុមផ្តល់លិខិតអនុញ្ញាត" មានពី "៣-៥"នាក់។ ក្រុមផ្តល់ | ក្រុមផ្តល់លិខិតអនុញ្ញាតត្រូវបានបង្កើត | លិខិតអនុញ្ញាតដល់នាវានេសាទត្រូវបានផ្តល់ | លិខិតអនុញ្ញាតដល់នាវា | | | រដ្ឋបាលជលផលនាយកដ្ឋានកិច្ចការជលផល ខណ្ឌរដ្ឋ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | លិខិតអនុញ្ញាតត្រូវមានពី២ ទៅ ៣ក្រុម | | | នេសាទត្រូវបានផ្តល់ | | | បាលជលផលតំបន់ឆ្នេរទាំង៤ |
| ១៣ | ផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទអួនអូសទាំងអស់ដែលមានប្រវែងខ្លីជាង១២ម៉ែត្រ | ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទ "ក្រុមផ្តល់លិខិតអនុញ្ញាត" ក្រុមនេះមានពី "៣-៥"នាក់ ។ ក្រុមផ្តល់លិខិតអនុញ្ញាតត្រូវមានពី២ ទៅ ៣ក្រុម | ផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរទាំង៤ត្រូវបានរៀបចំ | ២៥%នៃនាវានេសាទអួនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត | ៥០%នៃនាវានេសាទអួនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត | ៧៥%នៃនាវានេសាទអួនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត | ១០០%នៃនាវានេសាទអួនអូសដែលមានប្រវែងខ្លីជាង១២ម៉ែត្រត្រូវបានផ្តល់លិខិតអនុញ្ញាត | រដ្ឋបាលជលផល នាយកដ្ឋានកិច្ចការជលផល ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ |
| ១៤ | បន្តការផ្តល់លិខិតអនុញ្ញាត | រដ្ឋបាលជលផលត្រូវរៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទបន្ត | ផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរទាំង៤ត្រូវបានរៀបចំ | ១០០% នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយរដ្ឋបាលជលផលត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទ ដែលចេញដោយរដ្ឋបាលជលផលត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយរដ្ឋបាលជលផលត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយរដ្ឋបាលជលផលត្រូវបានបន្ត | រដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | ខណ្ឌរដ្ឋបាលផលផលត្រូវរៀបចំក្រុមការងារដើម្បីចុះទៅពិនិត្យនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតធ្វើនេសាទបន្ត | ផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរទាំង៤ត្រូវបានរៀបចំ | ១០០%នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយខណ្ឌរដ្ឋបាលផលផល ត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទ ដែលចេញដោយខណ្ឌរដ្ឋបាលផលផលត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយខណ្ឌរដ្ឋបាលផលផល ត្រូវបានបន្ត | ១០០%នៃលិខិតអនុញ្ញាតនេសាទដែលចេញដោយខណ្ឌរដ្ឋបាលផលផល ត្រូវបានបន្ត | ខណ្ឌរដ្ឋបាលផលផលថ្នាក់ខេត្តតំបន់ឆ្នេរទាំង៤ |
| | ៣.៣.ការវាយតម្លៃផលនេសាទ | | | | | | | |
| ១៥ | រៀបចំផែនការនិងអនុវត្តការស្រាវជ្រាវវាយតម្លៃផលនេសាទ | រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនិង អ្នកជំនាញមកពីអង្គការ FAO ឬ SEAFDEC រៀបចំការវាយតម្លៃផលនេសាទ | ផែនការអង្កេតលើការវាយតម្លៃផលនេសាទជាមួយ SEAFDEC/ FAO ត្រូវបានរៀបចំ | ផែនការបច្ចេកទេស និងធ្វើការសាកល្បងវិធីសាស្ត្រនៃការវាយតម្លៃផលនេសាទត្រូវបានរៀបចំ | ទិន្នន័យនៃការវាយតម្លៃផលនេសាទនាវានេសាទខ្នាតមធ្យម និងខ្នាតធំ | វិភាគទិន្នន័យនិងលទ្ធផលនៃការវាយតម្លៃផលនេសាទ | ពិនិត្យឡើងវិញនីតិវិធីនិងចាប់ផ្តើមផែនការសម្រាប់ការវាយតម្លៃផលនេសាទលើកក្រោយក្នុងឆ្នាំ២០២៤ | រដ្ឋបាលជលផលវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនិងអង្គការ SEAFDEC/ FAO |
| | | ដែលនឹងរួមបញ្ចូលការវាស់វែងប្រវែងត្រីនិងការវិភាគវាយតម្លៃប្រសិទ្ធភាពផលចាប់ | ពិនិត្យឡើងវិញនូវមូលដ្ឋានទិន្នន័យដែលមានស្រាប់ធ្វើបច្ចុប្បន្នភាពនិង | សាកល្បងគំរូនៃទិន្នន័យនិងលទ្ធផល | មូលដ្ឋានទិន្នន័យទាំងថ្នាក់ជាតិនិងថ្នាក់ខេត្តត្រូវបានរៀបចំ | ការវិភាគទិន្នន័យនិងលទ្ធផលនៃការវាយតម្លៃផលនេសាទ | | រដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | | អភិវឌ្ឍមូលដ្ឋានទិន្នន័យ | | | | | |
| | | | | | រដ្ឋបាលជលផលជួយខណ្ឌរដ្ឋបាលជលផលក្នុងការរៀបចំនិងគាំទ្រការវាយតម្លៃផលនេសាទសម្រាប់នាវាខ្នាតតូច | ការវិភាគទិន្នន័យនិងលទ្ធផលនៃការវាយតម្លៃផលនេសាទ | | រដ្ឋបាលជលផល វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផល |
| ១៦ | | រៀបចំក្រុមការងារចុះពិនិត្យនាវានេសាទនៅកន្លែងឡើងផលនេសាទនិងប្រមូលទិន្នន័យផលនេសាទតាមទំហំនិងប្រសិទ្ធភាពផលចាប់ | ផែនការស្រាវជ្រាវការវាយតម្លៃផលចាប់ដោយចាប់ផ្តើមជាមួយអង្គការSEAFDEC និង FAO ត្រូវបានរៀបចំ | ផែនការបច្ចេកទេសនិងធ្វើការសាកល្បងវិធីសាស្ត្រវាយតម្លៃផលចាប់ត្រូវបានរៀបចំ | ទិន្នន័យនៃការវាយតម្លៃផលនេសាទនៃនាវាខ្នាតតូចត្រូវបានបញ្ចូលក្នុងមូលដ្ឋានទិន្នន័យ | វិភាគទិន្នន័យនិងលទ្ធផលនៃការវាយតម្លៃផលនេសាទ | ពិនិត្យឡើងវិញនីតិវិធីនិងចាប់ផ្តើមផែនការសម្រាប់ការការវាយតម្លៃផលនេសាទលើកក្រោយក្នុងឆ្នាំ២០២៤ | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | **៣.៤. ការស្រង់ស្ថិតិផែនសាទ/កន្លែងឡើងផលនេសាទ** | | | | | | | |
| ១៧ | ស្រង់ស្ថិតិផែនេសាទឬកន្លែងឡើងផលនេសាទ | រដ្ឋបាលជលផលជួយដល់ខណ្ឌរដ្ឋបាលជលផល ក្នុងការរៀបចំផែនការនិងចុះស្រង់ស្ថិតិផែនេសាទឬកន្លែងឡើងផលនេសាទ | | ផែនការនិងចុះស្រង់ស្ថិតិផែនេសាទឬកន្លែងឡើងផលនេសាទត្រូវបានរៀបចំ | | ទិន្នន័យផែនេសាទឬកន្លែងឡើងផលនេសាទត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យ | | នាយកដ្ឋានផែនការគណនេយ្យនិងសហប្រតិបត្តិការអន្តរជាតិ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ |
| | | កត់ត្រាស្ថិតិផែនេសាទឬកន្លែងឡើងផលនេសាទថ្មី | | | | ស្ថិតិផែនេសាទឬកន្លែងឡើងផលនេសាទត្រូវស្រង់ | | ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ |
| | **៤. គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងការអនុវត្តច្បាប់ស្តីពីឧបករណ៍នេសាទ និងតំបន់ការពារ** | | | | | | | |
| | **៤.១. កំណត់ឧបករណ៍នេសាទស្របច្បាប់ និងខុសច្បាប់ និងត្រួតពិនិត្យការប្រើឧបករណ៍នេសាទក្នុងដែននេសាទសមុទ្រ** | | | | | | | |
| ១៨ | ធ្វើបច្ចុប្បន្នភាពឧបករណ៍នេសាទស្របច្បាប់ | រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល និងសហគមន៍នេសាទ រៀបចំកិច្ចប្រជុំដើម្បីកំណត់ឧបករណ៍នេសាទស្របច្បាប់និងខុសច្បាប់។ បន្ទាប់មក | ប្រកាសស្តីពីឧបករណ៍នេសាទស្របច្បាប់រួមបញ្ចូលទាំងនិយមន័យនៃលក្ខខណ្ឌនេសាទត្រូវបានព្រាង | ប្រកាសស្តីពីឧបករណ៍នេសាទស្របច្បាប់រួមបញ្ចូលទាំងនិយមន័យនៃលក្ខខណ្ឌនេសាទត្រូវបានអនុម័តនិងផ្សព្វផ្សាយ | | | | នាយកដ្ឋានកិច្ចការជលផល នាយកដ្ឋានអភិវឌ្ឍជលផល សហគមន៍នេសាទ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | ឧបករណ៍នេសាទស្របច្បាប់ត្រូវបានចេញដោយប្រកាស និងផ្សព្វផ្សាយ។ | | | | | | សមុទ្រ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |
| ១៩ | កំណត់តំបន់នេសាទសមុទ្រសម្រាប់ឧបករណ៍នេសាទដែលអនុញ្ញាតនិងរៀបរាប់លក្ខខណ្ឌក្នុងការនេសាទ | រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល និងសហគមន៍នេសាទ រៀបចំកិច្ចប្រជុំដើម្បីកំណត់តំបន់ឱ្យប្រើឧបករណ៍នេសាទស្របច្បាប់។ បន្ទាប់មកឧបករណ៍នេសាទស្របច្បាប់ត្រូវបានរៀបចំប្រកាសនិងធ្វើការផ្សព្វផ្សាយ | រៀបចំប្រកាសដើម្បីកំណត់តំបន់នេសាទសមុទ្រសម្រាប់ឧបករណ៍នេសាទដែលអនុញ្ញាតនិងលក្ខខណ្ឌក្នុងការនេសាទត្រូវបានព្រាង | តំបន់នេសាទសមុទ្រសម្រាប់ឧបករណ៍នេសាទដែលអនុញ្ញាតនិងលក្ខខណ្ឌក្នុងការនេសាទ ត្រូវបានអនុ-ម័តនិងផ្សព្វផ្សាយ | | | | នាយកដ្ឋានកិច្ចការជលផល នាយកដ្ឋានអភិរក្ស វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| ២០ | ធ្វើបច្ចុប្បន្នភាពឧបករណ៍ហាមឃាត់ | រដ្ឋបាលជលផល រៀបចំកិច្ចប្រជុំដើម្បីកំណត់ ឧបករណ៍នេសាទខុសច្បាប់។ បន្ទាប់មកឧបករណ៍ | រៀបចំប្រកាសដើម្បីកំណត់ដែននេសាទសមុទ្រសម្រាប់ឧបករណ៍ | ប្រកាសដើម្បីកំណត់ដែននេសាទសមុទ្រសម្រាប់ឧបករណ៍នេសាទហាមឃាត់ | | | | នាយកដ្ឋានកិច្ចការជលផល នាយកដ្ឋានអភិរក្ស វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | នេសាទខុសច្បាប់ត្រូវបានរៀបចំប្រកាសនិងធ្វើការផ្សព្វផ្សាយ | នេសាទហាមឃាត់ត្រូវបានព្រាង | ត្រូវបានអនុម័តនិងផ្សព្វផ្សាយ | | | | សមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| ២១ | កំណត់ប្រវែង ទំហំ និងចំនួនឧបករណ៍នេសាទសម្រាប់ការនេសាទ | រដ្ឋបាលជលផលរៀបចំកិច្ចប្រជុំដើម្បីកំណត់ប្រវែង ទំហំ និងចំនួនឧបករណ៍នេសាទ និងរៀបចំប្រកាសនិងធ្វើការផ្សព្វផ្សាយ | រៀបចំសេចក្តីព្រាងប្រកាសស្តីពីប្រវែងទំហំ និងចំនួនឧបករណ៍នេសាទសម្រាប់ការនេសាទជាលក្ខណៈគ្រួសារ ឬនេសាទប្រពៃណី | បញ្ចប់សេចក្តីប្រកាសស្តីពីប្រវែងទំហំ និងចំនួនឧបករណ៍នេសាទសម្រាប់ការនេសាទជាលក្ខណៈគ្រួសារ ឬនេសាទប្រពៃណី | | | | នាយកដ្ឋានកិច្ចការជលផល នាយកដ្ឋានអភិរក្ស វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| | **៤.២. រៀបចំធ្វើចំណាត់ថ្នាក់ដែននេសាទ ដើម្បីកំណត់ដែននេសាទសម្រាប់នាវានេសាទអូនអូសក្នុងតំបន់ឆ្នេរ និងការនេសាទក្នុងតំបន់ការពារ និងអភិរក្ស** | | | | | | | |
| ២២ | ស្រាវជ្រាវដើម្បីកំណត់និងធ្វើផែនទីតំបន់ផ្កាថ្មស្មៅសមុទ្រ ឬតំបន់ដែលមានសក្តានុពលធនធានជលផលសំខាន់ៗដទៃទៀតដែលកំណត់ជាតំបន់ការពារ ឬអភិរក្ស | រដ្ឋបាលជលផលធ្វើការស្រាវជ្រាវដើម្បីកំណត់និងធ្វើផែនទីតំបន់ផ្កាថ្មស្មៅសមុទ្រ ឬតំបន់ដែលមានសក្តានុពលធនធាន | ផែនការស្រាវជ្រាវតំបន់ផ្កាថ្មស្មៅសមុទ្រ និងតំបន់ដែលមានសក្តានុ-ពលធនធានជលផលសំខាន់ៗដទៃ | តំបន់ផ្កាថ្មស្មៅសមុទ្រ ឬតំបន់ដែលមានសក្តានុពលធនធានជលផលសំខាន់ៗដទៃទៀតត្រូវបានកំណត់ | ផ្កាថ្ម ស្មៅសមុទ្រឬតំបន់ដែលមានសក្តានុពលធនធានជលផលសំខាន់ៗដទៃ | | | នាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | ផលផលសំខាន់ៗដទៃទៀតដែលកំណត់ជា (តំបន់អភិរក្ស) ត្រូវបានធ្វើអត្តសញ្ញាណ។ ធ្វើសំណាកក្នុងតំបន់ដែលសង្ស័យថាមាន ឬធ្លាប់មានវត្តមានតំបន់ផ្កាថ្មនិងស្មៅសមុទ្រ | ទៀតត្រូវបានរៀបចំ | | ទៀត ត្រូវបានកំណត់អត្តសញ្ញាណ និងប្រកាសថាជា "តំបន់ការពារ ឬអភិរក្ស" ដែលគ្មាននាវានេសាទអួនអូស | | | សមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| ២៣ | | ផ្តល់ព័ត៌មានផែនទីនៃតំបន់ការពារ ឬអភិរក្សទៅក្រុមការងារកំណត់តំបន់ដែលត្រូវបានបង្កើតឡើង | ដំណើរការចាប់ផ្តើម (២៥%) | ផែនទី កំណត់ទីតាំងផ្កាថ្ម ស្មៅសមុទ្រ ឬតំបន់ដែលមានសក្តានុពលធនធានជលផលសំខាន់ៗដទៃទៀតត្រូវបានរៀបចំបោះពុម្ពនិងផ្សព្វ-ផ្សាយ | | | | នាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ២៤ | | រៀបចំប្រកាសស្តីពី "តំបន់ ការពារ ឬ អភិរក្សផ្កាថ្ម ស្មៅសមុទ្រ ឬតំបន់ដែលមានសក្តានុពលធនធានជលផល សំខាន់ៗដទៃទៀត | ដំណើរការចាប់ផ្តើម (២៥%) | ផែនទី កំណត់ទីតាំងផ្កាថ្ម ស្មៅសមុទ្រ ឬ តំបន់ដែលមានសក្តានុពលធនធានជលផលសំខាន់ៗដទៃទៀត និងកំណត់តំបន់ស្រទាប់១ម៉ាយ ដែលគ្មាន "នាវាអួនអូស" ត្រូវបានរៀបចំ បោះពុម្ពនិងផ្សព្វផ្សាយ | | | | នាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| ២៥ | រៀបចំផែនការ គ្រប់គ្រងតំបន់ការពារ ឬ តំបន់អភិរក្ស រួមទាំងការដាក់ពង្រាយ "ប្រអប់ថ្ម" | រដ្ឋបាលជលផល និងអ្នកជំនាញក្នុងតំបន់ផ្សេងទៀតរៀបចំផែនការសកម្មភាពនិងផែនការដាក់ពង្រាយប្រអប់ថ្ម។ ការរៀបរចនា ប្រអប់ថ្មនិងដាក់ពង្រាយក្នុងតំបន់ការពារ ឬ តំបន់អភិរក្ស | ២៥%ផ្កាថ្ម និងស្មៅសមុទ្រត្រូវបានការពារតាមរយៈការដាក់ឱ្យប្រើ "ប្រអប់ថ្ម" | ១០០%ផ្កាថ្ម និងស្មៅសមុទ្រត្រូវបានការពារតាមរយៈការដាក់ឱ្យប្រើ "ប្រអប់ថ្ម" | | | | នាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ២៦ | រៀបចំតំបន់នេសាទក្នុងតំបន់ដែលមានខ្សែទឹករាក់ជាង ២០ម៉ែត្រដើម្បីដោះស្រាយបញ្ហានាវាអូនអូសក្នុងតំបន់ឆ្នេរដែលមិនមានជម្លោះជាមួយការនេសាទក្នុងតំបន់ការពារនិងអភិរក្សដូចជាផ្កាថ្មនិងស្មៅសមុទ្រ | រដ្ឋបាលជលផលកំណត់តំបន់នៅក្នុងខ្សែទឹករាក់ជាង២០ម៉ែត្រដែលជាកន្លែងដែលនាវានេសាទអូនអូសអាចនេសាទបាននឹងមិនបំផ្លាញផ្កាថ្ម និងស្មៅសមុទ្រ | ដំណើរការចាប់ផ្តើម (២៥%) | ៥០%នៃការកំណត់តំបន់នេសាទតាមតំបន់ភូមិសាស្ត្រក្នុងតំបន់មានខ្សែទឹករាក់ជាង២០ម៉ែត្រអាចនាវាអូនអូសអាចនេសាទបានដែលមិនធ្វើឱ្យខូចខាតដល់ការនេសាទក្នុងតំបន់ការពារនិងអភិរក្សដូចជាផ្កាថ្មនិងស្មៅសមុទ្រ | ១០០%នៃការកំណត់តំបន់នេសាទតាមតំបន់ភូមិសា-ស្ត្រក្នុងតំបន់មានខ្សែទឹករាក់ជាង២០ម៉ែត្រអាចនាវាអូនអូសអាចនេសាទបានដែលមិនធ្វើឱ្យខូចខាតដល់តំបន់ការពារនិង អភិរក្ស | | | នាយកដ្ឋានកិច្ចការជលផល<br>នាយកដ្ឋានអភិរក្សវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ<br>ខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរទាំង៤ និងសហគមន៍នេសាទ |
| | **៤.៣. ការត្រួតពិនិត្យ និងអធិការកិច្ច៖ នាវានេសាទក្នុងស្រុក នាវានេសាទបរទេសនៅតាមព្រំដែន និងតំបន់មានវិវាទ** | | | | | | | |
| ២៧ | ប្រើនាវាល្បាត(នាវាធំនិងតូច) ដើម្បីល្បាត៖ នៅតាមបណ្តោយតំបន់ព្រំដែន ចាប់ពីដែនទឹកនៃសមុទ្រដែនដី | ក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលកម្រិតថ្នាក់នៃអធិការដ្ឋានជលផលសមុទ្រត្រូវធ្វើការវាយ | ល្បាត៤ ថ្ងៃក្នុងមួយខែនៅតាមបណ្តោយព្រំដែន | ល្បាត៤ ថ្ងៃក្នុងមួយខែនៅតាមបណ្តោយព្រំដែន | ល្បាត៤ ថ្ងៃក្នុងមួយខែនៅតាមបណ្តោយព្រំដែន | ល្បាត៤ ថ្ងៃក្នុងមួយខែនៅតាមបណ្តោយព្រំដែន | ល្បាត៤ ថ្ងៃក្នុងមួយខែនៅតាមបណ្តោយព្រំដែន | រដ្ឋបាលជលផល<br>អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | រហូតដល់ចុងខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | តម្លៃហានិភ័យប្រចាំខែ ដោយផ្អែកលើព័ត៌មាន ដើម្បីកំណត់តំបន់ដែលមានហានិភ័យខ្ពស់។ រដ្ឋបាលជលផលរៀបចំធ្វើផែនការ ផែនការប្រចាំខែតាមរយៈការសម្របសម្រួល ជាមួយគណៈកម្មការជាតិសន្តិសុខលម្ហសមុទ្រ ដើម្បីរៀបចំផែនការនិងធ្វើល្បាតក្នុងតំបន់សមុទ្រដែលមានហានិភ័យខ្ពស់ | | | | | | |
| ២៨ | ប្រើនាវាល្បាតធំដើម្បីបំពេញតម្រូវការៈ តំបន់នៃសាទ (ក្នុងតំបន់ចាប់ពីខ្សែបន្ទាត់ជម្រៅទឹក២០ម៉ែត្ររហូតដល់ចុងខាងក្រៅនៃតំបន់ | ក្រុមបង្ក្រាបបទល្មើសជលផលកម្រិតធ្ងន់នៃអធិការដ្ឋានជលផលសមុទ្រត្រូវធ្វើការវាយតម្លៃហានិភ័យប្រចាំខែ | ល្បាត១០ថ្ងៃក្នុងមួយខែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | ល្បាត១០ថ្ងៃក្នុងមួយខែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | ល្បាត១០ថ្ងៃក្នុងមួយខែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | ល្បាត១០ថ្ងៃក្នុងមួយខែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | ល្បាត១០ថ្ងៃក្នុងមួយខែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | នៃសាទ) នៅតាមបណ្តោយព្រំដែនសមុទ្រជាមួយវៀតណាមភាគខាងត្បូងនិងជាមួយថៃនៅភាគខាងជើងឆៀងខាងលិច | ដោយផ្អែកលើព័ត៌មានដើម្បីកំណត់តំបន់ដែលមានហានិភ័យខ្ពស់។ បន្ទាប់មករដ្ឋបាលជលផល ត្រូវរៀបចំធ្វើផែនការល្បាតប្រចាំខែ តំបន់សមុទ្រដែលមានហានិភ័យខ្ពស់ | | | | | | |
| ២៩ | ប្រើនាវាល្បាតតូចដើម្បីល្បាតក្នុងតំបន់មានខ្សែទឹករាក់ជាង២០ម៉ែត្រ និងអាចហួសពីនោះ (ក្នុងដែនរដ្ឋបាលនៃខេត្តនីមួយៗ) | ខណ្ឌរដ្ឋបាលជលផលក្រុមបង្ក្រាបបទល្មើសជលផលថ្នាក់ខេត្តត្រូវសហការជាមួយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ អនុវត្តការវាយតម្លៃហានិភ័យប្រចាំខែផ្អែកលើព័ត៌មានដើម្បីកំណត់តំបន់ដែលមានហានិភ័យខ្ពស់។ បន្ទាប់មក | ល្បាត១០ ថ្ងៃក្នុងមួយខែក្នុងដែនទឹកនៃខេត្ត។ ពិនិត្យផ្តោតទៅលើនាវានេសាទអាយយូយូជាចម្បង និងតាមដានការត្រួតពិនិត្យជាប្រចាំបើមានពេលវេលា។ ត្រួតពិនិត្យនាវានេសាទចំនួន៥% ក្នុងមួយ | ល្បាត១០ ថ្ងៃក្នុងមួយខែក្នុងដែនទឹកនៃខេត្ត។ ពិនិត្យផ្តោតទៅលើនាវានេសាទអាយយូយូ និង ជាចម្បង និងតាមដានការត្រួតពិនិត្យជាប្រចាំបើមានពេលវេលា។ ត្រួតពិនិត្យនាវានេសាទចំនួន៥% | ល្បាត១០ ថ្ងៃក្នុងមួយខែក្នុងដែនទឹកនៃខេត្ត។ ពិនិត្យផ្តោតទៅលើនាវានេសាទអាយយូយូ ជាចម្បង និងតាមដានការត្រួតពិនិត្យជាប្រចាំបើមានពេល | ល្បាត១០ ថ្ងៃក្នុងមួយខែក្នុងដែនទឹកនៃខេត្ត។ ពិនិត្យផ្តោតទៅលើនាវានេសាទអាយយូយូ ជាចម្បង និងតាមដានការត្រួតពិនិត្យជាប្រចាំបើមានពេលវេលា។ ត្រួតពិនិត្យនាវា | ល្បាត១០ ថ្ងៃក្នុងមួយខែក្នុងដែនទឹកនៃខេត្ត។ ពិនិត្យផ្តោតទៅលើនាវានេសាទអាយយូយូ ជាចម្បង និងតាមដានការត្រួតពិនិត្យជាប្រចាំបើមានពេលវេលា។ ត្រួតពិនិត្យនាវា | ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តតំបន់ឆ្នេរទាំង៤ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | | ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំធ្វើផែនការល្បាតប្រចាំខែ ជាមួយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ ដើម្បីធ្វើល្បាតក្នុងតំបន់សមុទ្រដែលមានហានិភ័យខ្ពស់ | ខែនៃខេត្តតំបន់ឆ្នេរនីមួយៗ | ក្នុងមួយខែនៃខេត្តតំបន់ឆ្នេរនីមួយៗ | វេលា។ ត្រួតពិនិត្យនាវានេសាទចំនួន ៥% ក្នុងមួយខែនៃខេត្តតំបន់ឆ្នេរនីមួយៗ | នេសាទចំនួន៥% ក្នុងមួយខែនៃខេត្តតំបន់ឆ្នេរនីមួយៗ | នេសាទចំនួន ៥% ក្នុងមួយខែនៃខេត្តតំបន់ឆ្នេរនីមួយៗ | |
| | | | | | | | | |
| ៣០ | បង្កើតបណ្តាញចែករំលែក និងផ្តល់ព័ត៌មានរវាងខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលឆ្លងព្រំដែនខេត្ត | បង្កើតបណ្តាញទំនាក់ទំនង និងជ្រើសរើសមន្ត្រីទទួលខុសត្រូវតាមខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរនីមួយៗ ព្រមទាំងរៀបចំកិច្ចប្រជុំប្រចាំត្រីមាស | បណ្តាញទំនាក់ទំនងត្រូវបានបង្កើត និងមន្ត្រីទទួលខុសត្រូវ ត្រូវបានជ្រើសរើស។ កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ | កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ | កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ | កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ | កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ | រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តតំបន់ឆ្នេរទាំង៤ |
| ៣១ | បញ្ចប់ការរៀបចំការពិព័ណ៌-នាអំពីការនេសាទរបស់កម្ពុជា (ដូចជាតំបន់ដែន | ការរៀបចំការពិព័ណ៌-នាអំពីការនេសាទរបស់កម្ពុជាក្នុងដែន | | ៥០% | ៥០% | | | រដ្ឋបាលជលផល |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| | នៃសាទសមុទ្រដែលស្ថិតនៅក្រោមយុត្តាធិការជាតិ) | នៃសាទសមុទ្រដែលស្ថិតនៅក្រោមយុត្តាធិការជាតិ) | | | | | | |
| ៣២ | | បញ្ចប់ការរៀបចំការពិព័ណ៌នាអំពីការនេសាទរបស់កម្ពុជាក្នុងដែននេសាទសមុទ្រដែលស្ថិតនៅក្រោមយុត្តាធិការជាតិ | | ២៥% | ៥០% | ដែននេសាទសមុទ្រដែលស្ថិតនៅក្រោមយុត្តាធិការជាតិសច្ចាប័ន | | រដ្ឋបាលជលផល |
| | **៤.៤. ការឃ្លាំមើលពីលើអាកាស** | | | | | | | |
| ៣៣ | ការឃ្លាំមើលពីលើអាកាស | ធ្វើការល្បាតតាមអាកាសនៅពេលយប់ដើម្បីកំណត់របាយនាវានេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃព្រះរាជាណាចក្រកម្ពុជា ដោយក្រុមការងារពិសេស | ធ្វើការវាយតម្លៃទៅលើការឃ្លាំមើលពីលើអាកាសតាមរយៈការហោះហើរដោយមនុស្ស ឬយន្តហោះគ្មានមនុស្សបើកដើម្បីស្វែងរកនាវាខុសច្បាប់ | | | | | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ៣៤ | | សិក្សាដើម្បីកំណត់ការឃ្លាំមើលពីលើអាកាសនាពេលអនាគតតាមរយៈយន្តហោះគ្មានមនុស្សបើកនិងប្រព័ន្ធមានឬគ្មានមនុស្សបើក ដែលរួមមានការវិភាគតម្លៃ | | អនុវត្តអនុសាសន៍នៃការឃ្លាំមើល | | | | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |
| ៣៥ | | អនុវត្តអនុសាសន៍នៃការឃ្លាំមើលលើអាកាស | | ប្រសិនបើឯកភាពចាប់ផ្តើមធ្វើលទ្ធកម្មឬសេវាកម្ម | | | | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |
| | ៤.៥. ការត្រួតពិនិត្យផែនៃសាទ កន្លែងឡើងផលនេសាទនិងការនាំចេញ-នាំចូល | | | | | | | |
| ៣៦ | ការត្រួតពិនិត្យកំពង់ផែតាមរថយន្ត | រដ្ឋបាលជលផលធ្វើអធិការកិច្ចនៅកំពង់ផែ និងកន្លែងឡើងផលនេសាទដើម្បីអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ និងកន្លែងនាំចេញនិងនាំចូល (កំពង់ផែ និងតាមព្រំដែន) | ផែនការត្រួតពិនិត្យកំពង់ផែ និងថវិកា និងមន្ត្រីត្រួតពិនិត្យត្រូវបានរៀបចំ | ធ្វើអធិការកិច្ចកំពង់ផែ | ធ្វើអធិការកិច្ចកំពង់ផែ | ធ្វើអធិការកិច្ចកំពង់ផែ | ធ្វើអធិការកិច្ចកំពង់ផែ | រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |

| ល.រ | សកម្មភាព | ភារកិច្ចត្រូវធ្វើ | លទ្ធផល | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | |
| ៣៧ | ធ្វើអធិការកិច្ចតាមរថយន្តដោយខណ្ឌរដ្ឋបាលជលផលនៅតាមខេត្តតំបន់ឆ្នេរ | ខណ្ឌរដ្ឋបាលជលផលធ្វើអធិការកិច្ចនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ | ធ្វើអធិការកិច្ចតាមរថយន្តនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ៥% នៃនាវានេសាទក្នុងមួយខែនៅតាមខេត្តតំបន់ឆ្នេរ | ធ្វើអធិការកិច្ចតាមរថយន្តនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ៥%នៃនាវានេសាទក្នុងមួយខែនៅតាមខេត្តតំបន់ឆ្នេរ | ធ្វើអធិការកិច្ចតាមរថយន្តនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ៥%នៃនាវានេសាទក្នុងមួយខែនៅតាមខេត្តតំបន់ឆ្នេរ | ធ្វើអធិការកិច្ចតាមរថយន្តនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ៥% នៃនាវានេសាទក្នុងមួយខែនៅតាមខេត្តតំបន់ឆ្នេរ | ធ្វើអធិការកិច្ចតាមរថយន្តនៅកំពង់ផែនិងកន្លែងឡើងផលនេសាទ៥%នៃនាវានេសាទក្នុងមួយខែនៅតាមខេត្តតំបន់ឆ្នេរ | ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តតំបន់ឆ្នេរទាំង៤ |

## ៤. ការចំណាយ

### ៤.១. ធនធានមនុស្ស

#### ៤.១.១. សកម្មភាពគ្រប់គ្រង

តារាងទី៩ ខាងក្រោមបង្ហាញអំពីសកម្មភាពប្រតិបត្តិការអាទិភាពជាក់លាក់ ស្ថានភាពធនធានមនុស្សនិងកម្រិតសកម្មភាពដែលនឹងត្រូវចាប់ផ្តើមដោយ រដ្ឋបាលជលផល និង ខណ្ឌរដ្ឋបាលជលផលដើម្បីអនុវត្តផែនការជាតិត្រួតពិនិត្យ និងអធិការកិច្ច ប្រកបដោយប្រសិទ្ធភាព។

តារាងទី ៩.សកម្មភាពប្រតិបត្តិការអាទិភាពជាក់លាក់ធនធានមនុស្សនិងសកម្មភាពជាក់លាក់

| សកម្មភាពអាទិភាពដែលត្រូវអនុវត្ត | ដែននេសាទ | ស្ថាប័នអនុវត្ត | ការងារត្រូវអនុវត្ត | រយៈពេល | ធនធានមនុស្សនៅរដ្ឋបាលជលផល | ធនធានមនុស្សនៅខណ្ឌរដ្ឋបាលជលផល |
|---|---|---|---|---|---|---|
| | >២០ម | រដ្ឋបាលជលផល | | ១៥ថ្ងៃ/ខែ | មន្ត្រី៨-១៥នាក់ដែលមានស្រាប់ | |

| | | | | | | |
|---|---|---|---|---|---|---|
| ១. សកម្មភាពល្បាតជាក់លាក់ដោយនាវាក្នុងសមុទ្រ | <២០ម | ខណ្ឌរដ្ឋបាលជលផល | -នេសាទក្នុងតំបន់អភិរក្ស (មាត្រា១៨នៃច្បាប់ស្តីពីជលផល ឆ្នាំ២០០៦)<br>-ឧបករណ៍នេសាទខុសច្បាប់ក្នុងសមុទ្រ<br>-នាវានេសាទបរទេសក្នុងកម្ពុជា | ១០ថ្ងៃ/ខែសម្រាប់ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តសមុទ្រទាំង៤ | | - កែប: ២នាក់ +៦នាក់ (មន្ត្រីកិច្ចសន្យា)<br>-កំពត: ៨នាក់ +៤នាក់<br>- ព្រះសីហនុ: ៩នាក់ +៦នាក់<br>-កោះកុង: ៥នាក់ +៥នាក់ |
| ២. សកម្មភាពល្បាតជាក់លាក់នៅលើដីគោក | | រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | ត្រួតពិនិត្យឧបករណ៍នេសាទខុសច្បាប់នៅលើដី | ៨ថ្ងៃ/ខែសម្រាប់រដ្ឋបាលជលផលថ្នាក់ខេត្តទាំង៤ | មន្ត្រី៨-១៥នាក់ដែលមានស្រាប់ | - កែប: ២នាក់ +៦នាក់ (មន្ត្រីកិច្ចសន្យា)<br>-កំពត: ៨នាក់ +៤នាក់<br>- ព្រះសីហនុ: ៩នាក់ +៦នាក់<br>-កោះកុង: ៥នាក់ +៥នាក់ |
| ៣. នាវានេសាទកម្ពុជាដែលនេសាទនៅខាងក្រៅដែនសមុទ្រកម្ពុជា | នៅក្រៅដែនយុត្តាធិការជាតិ | រដ្ឋបាលជលផល | រដ្ឋបាលជលផលនិងនាយកដ្ឋានផែនការ ហិរញ្ញវត្ថុនិងសហប្រតិបត្តិការអន្តរជាតិ។ នាពេលអនាគត តើមាននាវានេសាទកម្ពុជាធ្វើនេសាទនៅក្រៅដែនយុត្តាធិការជាតិ | | | |

**៤.១.២. សកម្មភាពល្បាតនៅលើដីគោកផ្សេងទៀត**

តារាងទី១០ ខាងក្រោមបង្ហាញពីស្ថានភាពធនធានមនុស្ស និងកម្រិតសកម្មភាពដែលនឹងត្រូវចាប់ផ្តើមដោយរដ្ឋបាលជលផល និងសកម្មភាពអាទិភាពជាក់លាក់ ដែលមានមូលដ្ឋាននៅលើដីគោក ដែលខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចប្រកបដោយប្រសិទ្ធភាព។

**តារាងទី ១០.ស្ថានភាពធនធានមនុស្ស និងកម្រិតសកម្មភាព**

| សកម្មភាពអាទិភាព ដែលត្រូវអនុវត្ត | ស្ថាប័នអនុវត្ត | កម្រិតសកម្មភាពការងារ | ពេលវេលា | ធនធានមនុស្សនៅ រដ្ឋបាលជលផល | ធនធានមនុស្សនៅ ខណ្ឌរដ្ឋបាលជលផល |
|---|---|---|---|---|---|
| ៤.ប្រព័ន្ធផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ | រដ្ឋបាលជលផល | >១៨ម៉ែត្រ | ចាប់ផ្តើមនៅឆ្នាំ២០២០ និងបន្តរាល់ឆ្នាំ | មន្ត្រី២នាក់ដែលមានស្រាប់ | |
| | ខណ្ឌរដ្ឋបាលជលផល | <១៨ម៉ែត្រ | ចាប់ផ្តើមនៅឆ្នាំ២០២១និងបន្តរាល់ឆ្នាំ | | មន្ត្រី៣នាក់ ដែលមានស្រាប់ |
| ៥.ផ្តល់ប័ណ្ណសម្គាល់នាវានេសាទដល់នាវានេសាទខ្នាតតូច | ខណ្ឌរដ្ឋបាលជលផល | នាវានេសាទខ្នាតតូច | លក្ខណៈគ្រួសារ | - ២០២០បណ្តុះបណ្តាល<br>-២០២១ អនុវត្ត(៥%ក្នុង១ ឆ្នាំ) | |
| ៦.ប្រមូលទិន្នន័យ និងប្រព័ន្ធរាយការណ៍ផលចាប់ (សៀវភៅកត់ត្រាស្ថិតិ) | រដ្ឋបាលជលផល | រៀបចំផែនការស្រាវជ្រាវផលនេសាទ | ចាប់ផ្តើមនៅឆ្នាំ ២០២០ | មន្ត្រី២នាក់មកពីនាយកដ្ឋានកិច្ចការផលផល<br>-មន្ត្រី២នាក់មកពីនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ | មន្ត្រីមានស្រាប់ប៉ុន្តែត្រូវសហការជាមួយមន្ត្រីខណ្ឌរដ្ឋបាលជលផល |
| | ខណ្ឌរដ្ឋបាលជលផល | ចូលរួមរៀបចំផែនការស្រាវជ្រាវផលនេសាទ | ចាប់ផ្តើមនៅឆ្នាំ២០២០ | | |
| ៧.ការធ្វើសំណាកតាមបែបវិទ្យាសាស្ត្រ | រដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលនិងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ | នេសាទលក្ខណៈគ្រួសារ | សាកល្បងនៅឆ្នាំ២០២០ អនុវត្តនៅឆ្នាំ២០២១ | រដ្ឋបាលជលផលៈ មន្ត្រី៨មានស្រាប់និងសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ | រដ្ឋបាលជលផល មន្ត្រី៨មានស្រាប់ចំពោះនេសាទគ្រួសារធ្វើសំណាកយកគំរូចៃដន្យ។ រៀបចំផែនការដោយភ្ជាប់ជាមួយនាយកដ្ឋានផែនការហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ |

| | | | | | |
|---|---|---|---|---|---|
| ៨.ប្រព័ន្ធឯកសារអេឡិចត្រូនិច នាំចេញ និងនាំចូល | រដ្ឋបាលជលផល | ការនាំចូល និងនាំចេញទាំងអស់ | | | |
| | ខណ្ឌរដ្ឋបាលជលផល | កន្លែងចូលចតទាំងអស់/ខេត្ត /២ឆ្នាំ (ទីកន្លែងសាកល្បង១កន្លែង/ខេត្ត / ឆ្នាំ) | | -រដ្ឋបាលជលផលមានមន្ត្រី២រូប (នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ)<br>-អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ៩. ការកត់ត្រានៃតំបន់ចូលចត | រដ្ឋបាលជលផល | កន្លែងចូលចតទាំងអស់/ខេត្ត /២ឆ្នាំ | ទីកន្លែងសាកល្បង១កន្លែង/ខេត្ត / ឆ្នាំ | | |

### ៤.១.៣. ថវិកា និងការចំណាយ

បញ្ជីចំណាយចរន្ត និងចំណាយមូលធនសម្រាប់ការអនុវត្តផែនការមានក្នុងតារាងទី១១។ គម្រោងការចំណាយសំខាន់ៗ ត្រូវបានស្នើក្នុងផ្នែកបញ្ហាអាទិភាព។ សកម្មភាពដែលមានគូសបន្ទាត់ពីក្រោមគឺជាសកម្មភាពសំខាន់ៗ។ សកម្មភាពផ្សេងៗទៀតនឹងរួមចំណែកយ៉ាងធំធេងដល់ការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ប៉ុន្តែមិនសូវចាំបាច់ទេ។

ការចំណាយផ្អែកលើការសម្រេចគោលនយោបាយដូចជា៖

ក. សៀវភៅកត់ត្រាស្ថិតិមានសារសំខាន់ ប៉ុន្តែត្រូវចំណាយលើការបោះពុម្ព និងការផ្សព្វផ្សាយ។ សៀវភៅកត់ត្រាស្ថិតិគឺជាឧបករណ៍ប្រមូលទិន្នន័យលំបាកហើយត្រូវការបញ្ចូលទិន្នន័យគ្រប់ពេលនេសាទ និងត្រួតពិនិត្យការកត់ត្រាយ៉ាងល្អិតល្អន់។ ការស្រាវជ្រាវ និងការវាយតម្លៃផលនេសាទគួរត្រូវបានអនុវត្ត ដើម្បីបង្កើនការប្រមូលទិន្នន័យនេសាទឱ្យបានត្រឹមត្រូវ។

ខ. ប្រព័ន្ធត្រួតពិនិត្យនាវានេសាទមានតម្លៃថ្លៃណាស់។ ការបង្កើនការត្រួតពិនិត្យតាមប្រព័ន្ធតាមដាននាវានេសាទមានអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការចំណាយលើការល្បាត លើកកម្ពស់ការគ្រប់គ្រងធនធានជលផល និងនាវានេសាទ។

រដ្ឋបាលជលផលមានជម្រើស៣ដូចខាងក្រោម៖

ក. ចំណាយលើការទិញឧបករណ៍ប្រព័ន្ធតាមដានត្រួតពិនិត្យ ស្ថានីយត្រួតពិនិត្យ និងបង់ថ្លៃសេវា (៦,៥លានដុល្លារ)

ខ. ចំណាយលើការទិញឧបករណ៍ប្រព័ន្ធតាមដានត្រួតពិនិត្យ និងស្ថានីយឃ្លាំមើល (៨៥០ ០០០ដុល្លារ ហើយឱ្យអ្នកនេសាទបង់ថ្លៃសេវាប្រចាំខែ១០-៣០ដុល្លារ)

គ. អ្នកនេសាទត្រូវទិញឧបករណ៍តាមដានតម្លៃ៣០០ដុល្លារ និងបង់ថ្លៃសេវាប្រចាំខែពី១០ ទៅ៣០ដុល្លារ ប៉ុន្តែសម្រាប់នាវានេសាទអួនអូសខ្នាតតូច (ខ្លីជាង១២ម៉ែត្រ) ការចំណាយគឺបង្វិលសងដោយរដ្ឋាភិបាលវិញ (សូមមើលឧបសម្ព័ន្ធ៣)។

តារាងទី ១១.ការចំណាយប្រតិបត្តិការ និងមូលធននៃការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ (គិតជា ១០០០ដុល្លារអាមេរិក)

| តម្លៃឧបករណ៍ និងសេវាកម្មក្នុងការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ (សកម្មភាពអាទិភាពមានគូសបន្ទាត់ពីក្រោម ) | តម្លៃដើមទុន | | | ចំណាយប្រតិបត្តិការ | | | | | | | តម្លៃចំណាយសម្រាប់ ៥ ឆ្នាំ | សំខាន់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សមាសធាតុ | តម្លៃក្នុងមួយឯកតា | ចំនួនធាតុ | ចំណាយទុនសរុប | ចំណាយក្នុង១ថ្ងៃ/ឯកតា | ចំណាយក្នុង១ខែ/ឯកតា | ចំនាយប្រចាំឆ្នាំឬ១ឯកតា | ចំនួនគ្រឿង/លើក | តម្លៃប្រតិបត្តិការក្នុងមួយឯកតា | ការអនុវត្តក្នុងឆ្នាំ | ចំណាយប្រតិបត្តិការសរុប ៥ ឆ្នាំ | | |
| **សិក្ខាសាលាស្តីពីច្បាប់ និងភាគីពាក់ព័ន្ធ** | | | | | | | | | | | | |
| ថ្លៃសិក្ខាសាលាសម្រាប់ច្បាប់ក្នុងស្រុកភាគច្រើនជាសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនៅតាមបណ្តាខេត្តនិងភ្នំពេញ ។ កិច្ចប្រជុំមាន ១០ លើកស្តីពីលិខិតបទដ្ឋានគតិយុត្ត និង ៣ លើកក្នុងប្រកាស១។ ក្នុង១លើកមានអ្នកចូលរួម ៣០នាក់ | | | | | | ៥ | ៣០ | | | ១៥០ | ១៥០ | ១៥០ |
| សិក្សា និងរៀបចំ ដើម្បីដាក់តម្កល់លិខិតឧបករណ៍ EEZ ស្តីពីច្បាប់ សមុទ្រ។ កិច្ចប្រជុំជាច្រើនលើកនិងទីប្រឹក្សាអន្តរជាតិ | | | | | | | | | | ២០០ | ២០០ | ២០០ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **ការគ្រប់គ្រងនាវា៖ ផ្តល់លិខិតអនុញ្ញាតនិងលិខិតបញ្ជាក់កំណត់ត្រានាវានេសាទ** | | | | | | | | | | | |
| រដ្ឋបាលជលផលផ្តល់លិខិតអនុញ្ញាត | | | | | | | ៥០ | ៥ | ២៥០ | ២៥០ | ២៥០ |
| មន្ទីរកសិកម្មផ្តល់លិខិតបញ្ជាក់កំណត់ត្រានាវានេសាទ | | | | | ២០ | ៤ | ៨០ | ៥ | ៤០០ | ៤០០ | ៤០០ |
| ការកត់ត្រាកន្លែងចូលចត -ជាផ្នែកមួយនៃកាតព្វកិច្ចធម្មតា | | | | | | | ០ | | ០ | | |
| នាវាល្បាត | | | | | | | | | | | |
| នាវាល្បាតសមុទ្រក្រៅ (នាវាល្បាតប្រវែង២២ ម៉ែត្រ) | ៨៥០ | ១ | ៨៥០ | ២ | ៤០ | ៤៨០ | ១ | ៤៨០ | ៥ | ២ ៤០០ | ៣ ២៥០ | ៣ ២៥០ |
| នាវាល្បាតតំបន់ឆ្នេរជម្រើសទី១ នាវា១៥ ម ច្រើនថ្ងៃក្នុងមួយលើក | ៣០០ | ៣ | ៩០០ | ០,៣ | ៣ | ៣៦ | ៣ | ១០៨ | ៥ | ៥៤០ | ១ ៤៤០ | ១ ៤៤០ |
| នាវាល្បាតតំបន់ឆ្នេរជម្រើសទី ២, នាវា៨ ម -ចេញល្បាត១ថ្ងៃ / យប់ តែប៉ុណ្ណោះ - មិនចតពេលយប់ក្នុងសមុទ្រ | ១០០ | ៣ | ៣០០ | ០,២៥ | ២,៥ | ៣០ | ៣ | ៩០ | ៥ | ៤៥០ | ៧៥០ | |
| បន្ថែមនាវាល្បាត ឈើ១គ្រឿង (១២-១៤ម៉ែត្រ) | ២៥០ | ២ | ៥០០ | ០,៤៨ | ៤,៨ | ៥៧,៦ | ២ | ១១៥, ២ | ៥ | ៥៧,៦ | ១ ០៧៦ | |
| ល្បាតនៅលើដីគោក (ទិញរថយន្ត៦គ្រឿង) | ៤០ | ៦ | ២៤០ | ០,០៤ | ០,៨ | ៩,៦ | ៦ | ៥៧,៦ | ៥ | ២៨៨ | ៥២៨ | ៥២៨ |
| ការស្រាវជ្រាវតាមអាកាសសម្រាប់តែ ២ឆ្នាំ | | | | ៤ | ៦៤ (១៦ថ្ងៃ) | ៤៤៨ | ១ | ៤៤៨ | ២ | ៨៩៦ | ៨៩៦ | |
| | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការការពារទីជម្រក (ក្រោមចំកោកម្មវិធីអភិរក្ស) | ០,៥ | ១ ០០០ | ៥០០ | | | | | | | | | |
| ផែនទីនៃតំបន់អភិរក្ស ផ្កាថ្ម និងស្មៅសមុទ្រ | ២០ | ១ | ២០ | | | | | | | | ២០ | ២០ |
| បណ្តុះបណ្តាលលើការប្រើឧបករណ៍ (តំណត់យក ការវាយតម្លៃផលស្តុក និងបណ្តុះបណ្តាលការវាយតម្លៃផលស្តុក មូលដ្ឋានទិន្នន័យនិងកម្មវិធីរបស់វាដោយ FAO | ៥០០ | ២ | ៥០០ | | | | | | | | ៥០០ | ៥០០ |
| **សរុប** | | | ៣ ៨១០ | | | | | | | ៦ ០៩០ | ៩ ៩០០ | ៥ ៩៨៨ |

**តារាងទី ១២. ការចំណាយប្រតិបត្តិការ និងមូលធននៃការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ (គិតជា ១០០០ដុល្លារអាមេរិក)**

| តម្លៃឧបករណ៍ និងសេវាកម្មក្នុងការអនុវត្តផែនការ សកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ (សកម្មភាពអាទិភាព មានគូសបន្ទាត់ពីក្រោម) | តម្លៃដើមទុន | | | ចំណាយសម្រាប់ការអនុវត្ត | | | | | | | ថវិកាសម្រាប់ ៥ឆ្នាំ | ថវិកាសំខាន់ៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សមាសធាតុ | តម្លៃក្នុងមួយឯកតា | ចំនួនធាតុ | ចំណាយទុនសរុប | ចំណាយក្នុង១ថ្ងៃ/ឯកតា | ចំណាយក្នុង១ខែ/ឯកតា | ចំណាយប្រចាំឆ្នាំឬ ១ឯកតា | ចំនួនគ្រឿង | តម្លៃប្រតិបត្តិការក្នុង ១ឯកតា | ការអនុវត្តក្នុងឆ្នាំ | ចំណាយប្រតិបត្តិការសរុប ៥ឆ្នាំ | ជម្រើសទី ១ | ជម្រើសទី ២ |
| តម្រូវឱ្យមានកាតព្វកិច្ចចាំបាច់ -សម្រាប់នាវានេសាទហួសពីដែនទឹកដែលស្ថិតក្រោមយុត្តាធិការជាតិ | | | | | | | | ចំណាយប្រតិបត្តិការឆ្នាំ១គ្រឿងប្រព័ន្ធតាមដាននាវា | | តម្លៃឆ្នាំប្រតិបត្តិការប្រព័ន្ធផ្កាយរណបតាមដានប្រព័ន្ធ | ជម្រើសទី១ | ជម្រើសទី២ |

| | | | | | | | | | | នាវា នេសាទ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រព័ន្ធតាមដាននាវានេសាទហួសពីដែនយុត្តាធិការជាតិ (១០គ្រឿង), ជម្រើសទី១. អ្នកផ្តល់សេវាកម្ម ពិនិត្យតាមដាននាវានៅតម្លៃ១ ពាន់ដុល្លារក្នុងមួយនាវា | ៣,៦ | ១០ | ៣៦ | ០,០០៣ | ០,០៩ | ២,០៨ | ១០ | | ៥ | ១០,៤ | ៤៦,៤ | |
| ប្រព័ន្ធតាមដាននាវានេសាទហួសពីដែនយុត្តាធិការជាតិ (១០គ្រឿង), ជម្រើសទី២. ស្ថានីយផ្កាយរណប និងសូហ្វវែរផ្គត់ផ្គង់ដោយកម្ពុជាខ្លួនឯងដែលជាម្ចាស់និងដំណើរការដោយជនជាតិកម្ពុជា | ១០០ | ១ | ១០០ | ០,០០៣ | ០,០៩ | ២,០៨ | ១០ | | ៥ | ១០,៤ | | ១១០,៤ |
| សរុប | | | | | | | | | | | ៤៦,៤ | ១១០,៤ |
| ប្រព័ន្ធតាមដាននាវា -សម្រាប់នាវាក្នុងប្រទេស | | | | | | | | | | | | |
| ជម្រើសទី១៖ រាជរដ្ឋាភិបាលកម្ពុជាផ្តល់គ្រឿងបរិក្ខារ AIS ប៉ុន្តែអ្នកនេសាទបង់ថ្លៃចំណាយសម្រាប់ការទំនាក់ទំនងនិងការដំឡើង | | | | | | | | | | | | |
| ឧបករណ៍ប្រព័ន្ធឃ្លាំមើលនាវាចរ Sat - AIS - លទ្ធកម្មដោយរដ្ឋាភិបាល | ០,៣ | ៣ ០០០ | ៩០០ | | | | | | | | ៩០០ | |
| សេវាកម្មប្រព័ន្ធឃ្លាំមើលនាវាចរ Sat - AIS - ចេញលុយដោយ អ្នកនេសាទ | | | | ០,០០៣ | ០,០៩ | ១,០៨ | ៣ ០០០ | ៣ ២៤០ | ៥ | ១៦ ២០០ | | |
| បន្ទប់របស់ប្រព័ន្ធឃ្លាំមើលនាវាចរ Sat - AIS - កម្ពុជាជាម្ចាស់ និងប្រតិបត្តិការក្នុងបន្ទប់ប្រតិបត្តិការ | ៥០ | ១ | ៥០ | | | | | | | | ៥០ | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ជម្រើសទី២.** | | | | | | | | | | | | |
| ប្រព័ន្ធឃ្លាំមើលនាវាចរតាម ប្រព័ន្ធទូរស័ព្ទចល័តដែលអ្នកនេសាទទិញប្រព័ន្ធឃ្លាំមើលនាវាចរ ពីអ្នកផ្តល់សេវា និងបង់ថ្លៃចំណាយទំនាក់ទំនង | ០,២៥ | ៣ ០០០ | ៧៥០ | | | | | | ៥ | | | |
| តម្លៃសេវាកម្មប្រព័ន្ធឃ្លាំមើលនាវាចរ តាមប្រព័ន្ធទូរស័ព្ទចល័ត | | | | ០,០០១ | ០,០៣ | ០,៣៦ | ៣ ០០០ | ១ ០៨០ | ៥ | ៥ ៤០០ | | |
| ប្រព័ន្ធឃ្លាំមើលនាវាចរតាម ប្រព័ន្ធទូរស័ព្ទចល័តដែលរដ្ឋាភិបាលទិញប្រព័ន្ធឃ្លាំមើល និងបង់ថ្លៃចំណាយទំនាក់ទំនង | ០,២៥ | ៣ ០០០ | ៧៥០ | | | | | | | | | ៧៥០ |
| ស្ថានីយប្រព័ន្ធឃ្លាំមើលនាវាចរតាម ប្រព័ន្ធទូរស័ព្ទចល័តឬខាងក្រៅ | ១០០ | ១ | ១០០ | | | | | | | | | ១០០ |
| សរុប | | | | | | | | | | | ៩៥០ | ៨៥០ |

## ៥. ការតាមដាន និងការវាយតម្លៃ

### ៥.១. ការផ្ទៀងផ្ទាត់ និងសូចនាករដែលសម្រេចបាន

របាយការណ៍ល្មើសជលផលជាតិ និងការអនុវត្តផ្ទាល់ក្នុងសមុទ្រនិងលើគោក អាចត្រូវបានពង្រឹងដោយការកំណត់និយមន័យនៃវិធានការផ្ទៀងផ្ទាត់ និងការចុះបញ្ជីសម្រាប់សកម្មភាពត្រួតពិនិត្យនីមួយៗ របាយការណ៍អធិការកិច្ចត្រូវបញ្ចូលក្នុងមូលដ្ឋានទិន្នន័យ និងវិភាគឱ្យបានទៀងទាត់ (ប្រសិទ្ធភាពការងារ តារាងពិន្ទុ និងស្ថិតិ) យ៉ាងតិចមួយឆ្នាំម្តងដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ផលប៉ះពាល់កម្រិតនៃការអនុវត្ត។

របាយការណ៍ផ្ទៀងផ្ទាត់ត្រូវចែករំលែកដល់សមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ (សេចក្តីសន្និដ្ឋានស្តីពីផលប៉ះពាល់នៃសកម្មភាពត្រួតពិនិត្យ ស្ថានភាពនៃការអនុវត្តច្បាប់ ប្រភេទនៃបទល្មើសជលផលដែលបានជួបប្រទះនិងសកម្មភាពបន្ត)។

ការអនុវត្តប្រព័ន្ធត្រួតពិនិត្យបទល្មើសជលផល ការវាយតម្លៃគុណភាពក្នុងសកម្មភាពត្រួតពិនិត្យ និងការវាយតម្លៃដោយអង្គភាពផ្ទៃក្នុងឬក្រៅ នូវប្រសិទ្ធភាពនៃការអនុវត្ត តាមគោលបំណង និងនីតិវិធីដែលបានកំណត់។ សូចនាករគោលដៅមានបង្ហាញជូនក្នុងតារាងទី១៣ ប៉ុន្តែគោលដៅពិតប្រាកដមានផ្តល់ជូនក្នុងតារាងម៉ាទ្រីកសកម្មភាពទី៨។

**តារាងទី ១៣.សូចនាករគោល**

| សកម្មភាព | គោលដៅ % នៃបទល្មើសជលផលក្នុងពេលធ្វើអធិការកិច្ចមួយលើក | | | |
|---|---|---|---|---|
| | កម្រិតបច្ចុប្បន្ន | ឆ្នាំ ២០២០ (ឆ្នាំទី១) | ២០២៤ (ឆ្នាំទី៥) | ទិន្នន័យដែលបានកត់ត្រាពីសកម្មភាពអនុវត្តដោយប្រព័ន្ធ អេឡិចត្រូនិកមានភាពល្អប្រសើរ ដូចជា "Smart" ឬ "Abalobi" |
| ធ្វើអធិការកិច្ចនាវានេសាទក្នុងកំពង់ផែ កន្លែងផ្ទេរផលនេសាទ កន្លែងឡើងផលនេសាទ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ធ្វើអធិការកិច្ចនាវានេសាទនៅសមុទ្រ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| វិធានការរដ្ឋម្ចាស់កំពង់ផែ និងត្រួតពិនិត្យកំពង់ផែរដ្ឋ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ធ្វើអធិការកិច្ចដោយប្រព័ន្ធតាមដានត្រួតពិនិត្យនិងបំពាក់ឧបករណ៍តាមដានលើនាវានេសាទខ្នាតធំនិងមធ្យមទាំងអស់ | ១០០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ធ្វើអធិការកិច្ចនិងផ្តល់អាជ្ញាប័ណ្ណកន្លែងកែច្នៃផលនេសាទ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ល្បាតនិងត្រួតពិនិត្យយ៉ាងសកម្មកន្លែងសហគមន៍នេសាទ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |
| ធ្វើអធិការកិច្ចពលករលើនាវានេសាទនិងរោងចក្រកែច្នៃ។ | >៨០% | ៥០% | ៥% | ទិន្នន័យត្រូវបានផ្ទៀងផ្ទាត់និងវិភាគ |

| | | | | |
|---|---|---|---|---|
| ចាប់ផ្តើមនិងបញ្ចប់ប្រព័ន្ធចុះបញ្ជីនាវានេសាទ | >៥% | | ១០០% | ការទំនាក់ទំនងជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងរបាយការណ៍ពីខណ្ឌរដ្ឋបាលជលផល |
| ចាប់ផ្តើមនិងបញ្ចប់ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត | >៥% | ៥០% | ១០០% | រដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលជលផលបន្តផ្តល់និងបញ្ចប់ប្រព័ន្ធលិខិតអនុញ្ញាត |
| កំណត់ទិន្នផលផលចាប់ក្នុងមួយឯកតានៃត្រីសំខាន់៥ប្រភេទ | រដ្ឋបាលជលផលកំណត់ប្រភេទ | ចាប់ផ្តើមប្រមូលទិន្នន័យ | ប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតានៃត្រីសំខាន់៥ប្រភេទត្រូវបានកំណត់ | វិភាគប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតាដកស្រង់ពីសៀវភៅកត់ត្រាស្ថិតិនិងវាយតម្លៃស្ថានភាពនៃត្រីសំខាន់៥ប្រភេទ |
| កំណត់ផលចាប់មិនលើសកម្រិតកំណត់និរន្តរភាពអតិបរមា | រដ្ឋបាលជលផលកំណត់ប្រភេទ | ការប្រមូលទិន្នន័យបានចាប់ផ្តើម | ១០០% នេសាទនៅកម្រិតកំណត់និរន្តរភាពអតិបរមា | វិភាគប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតាដកស្រង់ពីសៀវភៅកត់ត្រាស្ថិតិនិងវាយតម្លៃផលស្តុកប្រភេទត្រី៥សំខាន់ៗ |

## ៥.២. និរន្តរភាពវិស័យជលផល

ការអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រទទួលបានជោគជ័យកម្រិតណានោះ អាស្រ័យទៅតាមកត្តាមួយចំនួនដូចខាងក្រោម៖

**ការត្រួតពិនិត្យផលចាប់សរុបមិនឱ្យលើសកម្រិតកំណត់និរន្តរភាពអតិបរមា (MSY-Maximum Sustainalbe Yield)**

បន្ទាប់ពីការកំណត់ទិន្នផលកម្រិតកំណត់និរន្តរភាពអតិបរមា ការត្រួតពិនិត្យត្រូវបានអនុវត្ត ដើម្បីធានាផលនេសាទសរុបមិនត្រូវលើសពីកម្រិតកំណត់និរន្តរភាពអតិបរមា។ ទិន្នន័យផលចាប់សរុប ដែលរួមទាំងប្រភេទវារិសត្វចាំបាច់ត្រូវធ្វើការវាយតម្លៃផងដែរ ប្រសិនបើផលចាប់នៅកន្លែងឡើងផលនេសាទលើសពីកម្រិតអតិបរមា (ឬការផលិតលើស) នៃផលស្តុក។ ប្រសិនបើទិន្នផលនេសាទនៅកន្លែងឡើងផលនេសាទទាបជាងទិន្នផលដែលបានប៉ាន់ប្រមាណនោះ ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលទទួលបានជោគជ័យ ផ្ទុយមកវិញប្រសិនបើទិន្នផលនៅកន្លែងឡើងផលនេសាទលើសពីទិន្នផលនេសាទ ការត្រួតពិនិត្យ និងអធិការកិច្ចចាំបាច់ត្រូវកែលម្អ និងវិធានការគ្រប់គ្រងត្រូវតែកែសម្រួលដូចជារដូវបិទនេសាទ តំបន់បិទនេសាទ ឬការកំណត់ឧបករណ៍នេសាទ។

កំពង់ផែនេសាទត្រូវទទួលខុសត្រូវក្នុងការរាយការណ៍ និងផ្តល់ទិន្នន័យទៅខណ្ឌរដ្ឋបាលជលផល។ ទិន្នន័យត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការប្រមូលបាន។ ទម្ងន់សរុបនៃផលចាប់នៅកន្លែងឡើងផលនេសាទ ដែលទទួលបានពីនាវានេសាទនីមួយៗត្រូវធ្វើរបាយការណ៍សង្ខេបជារៀងរាល់ត្រីមាសទាក់ទងនឹងបរិមាណ និងប្រសិទ្ធភាពនេសាទប្រៀបធៀបទៅនឹងកម្រិតគោលដៅ។ អ្នកប្រមូលទិន្នន័យនៃខណ្ឌរដ្ឋបាលជលផលត្រូវផ្តល់របាយការណ៍ត្រួតពិនិត្យសង្ខេបប្រចាំសប្តាហ៍ទៅកាន់មជ្ឈមណ្ឌលតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជូនដំណឹងទៅស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសកម្មភាពបន្ថែមទៀត ដូចជាការកាត់បន្ថយចំនួននាវានេសាទ និងការបិទតំបន់នេសាទ។

## ៥.៣. ការកាត់បន្ថយសកម្មភាពដែលធ្វើឱ្យមហន្តរាយដល់ផលស្តុក

### ការវាយតម្លៃសកម្មភាពតាមដានការនេសាទអាយយូយូ

មន្ត្រីម្នាក់ៗត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនស្តីពីការងារត្រួតពិនិត្យ និងអធិការកិច្ចទាំង៩ចំណុច ដែលបានរៀបរាប់ក្នុងតារាងទី៩ និងតារាងទី១០។ សកម្មភាពទី១៖ មន្ត្រីម្នាក់ត្រូវទទួលខុសត្រូវក្នុងការបញ្ចូលរបាយការណ៍ឃ្លាំមើលទៅក្នុងទិន្នន័យមូលដ្ឋានថ្នាក់ជាតិ និងទទួលបានព័ត៌មានត្រឡប់មកវិញទាក់ទងនឹងរបាយការណ៍ផ្សេងទៀតពីទិន្នន័យមូលដ្ឋានថ្នាក់ជាតិ។ សកម្មភាពទី២ដល់ទី៦ ត្រូវធ្វើរបាយការណ៍ម្តងក្នុងមួយសប្តាហ៍ ប្រសិនបើមានករណីបន្ទាន់ត្រូវធ្វើរបាយការណ៍ភ្លាម។ សកម្មភាពទី៧ មុនពេលចេញឯកសារ កំណត់ត្រា ត្រូវពិនិត្យមើលការនេសាទអាយយូយូដែលសង្ស័យនិងការរំលោភបំពាន។ បើសិនមានបញ្ហាណាមួយកើតឡើង ការស៊ើបអង្កេតបន្ថែមនឹងត្រូវអនុវត្តការផ្តល់លិខិតអនុញ្ញាតថ្មីអាចត្រូវបានព្យួរនិងការអនុញ្ញាតពីមុនអាចនឹងត្រូវដកហូត។ ករណីធម្មតារបាយការណ៍ត្រូវធ្វើម្តងក្នុងមួយខែ។

បើសិនមានការសង្ស័យទាក់ទងនឹងការនេសាទអាយយូយូណាមួយកើតឡើង របាយការណ៍ត្រូវតែដាក់ភ្លាមៗក្នុងមូលដ្ឋានទិន្នន័យ។ លើសពីនេះទៀតក្រុមការងារតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល ត្រូវរាយការណ៍ និងជូនដំណឹងដល់សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនសកម្មភាពតាមដានបន្ថែមទៀត។

## ៥.៤. ការវិភាគថ្លៃចំណេញ

### ការវិភាគការចំណាយ និងថ្លៃចំណេញ៖

ការិយាល័យតាមដាន ត្រួតពិនិត្យនិងឃ្លាំមើលទទួលខុសត្រូវក្នុងការគណនាថវិកា ដែលត្រូវការសម្រាប់វាយតម្លៃសកម្មភាព។ សកម្មភាពរួមមាន ការត្រួតពិនិត្យឯកសារជាមួយប្រទេសម្ចាស់នាវានេសាទ និងកំណត់ការពិន័យចំពោះបទល្មើសនេសាទអាយយូយូ។ ការិយាល័យក៏ទទួលខុសត្រូវផងដែរ ក្នុងការប្រៀបធៀបតម្លៃនៃការតាមដាន និងការឃ្លាំមើលជាមួយនឹងតម្លៃសេដ្ឋកិច្ចនៃធនធានសមុទ្រ។ បន្ទាប់ពីការសិក្សាវាយតម្លៃវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុត របៀបធ្វើរបាយការណ៍ និងការរាយការណ៍ត្រូវបានកំណត់។ ការសិក្សាវាយតម្លៃត្រូវធ្វើឡើងយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

## ៥.៥. សន្និដ្ឋាន

បញ្ហាប្រឈមនានាចំពោះនិរន្តរភាពនៃវិស័យជលផលមានច្រើននិងមានភាពខុសគ្នា។ ទោះជាយ៉ាងណាក៏ដោយបញ្ហាចម្បងគឺខ្វះការវិនិយោគក្នុងការគ្រប់គ្រង និងរដ្ឋបាលក្នុងវិស័យនេះ និងលទ្ធផលនៃការកើនឡើងនៃអាជីវកម្មនេសាទដែលមិនមាននិរន្តរភាព។

ផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ ជួយឱ្យការគ្រប់គ្រងវិស័យជលផលសមុទ្រឈានឆ្ពោះទៅរកនិរន្តរភាពនិងធ្វើឱ្យកាន់តែប្រសើរឡើង។ ការវិនិយោគនិងការគាំទ្រពីបរទេសនាំឱ្យរដ្ឋបាលជលផលអាចអនុវត្តផែនការនេះបាន។ ជាចុងក្រោយ ដើម្បីបន្តនិរន្តរភាព ព្រះរាជាណាចក្រកម្ពុជាត្រូវសម្រេចចិត្តធ្វើអន្តរាគមន៍ក្នុងវិស័យជលផល និងបរិស្ថានសមុទ្រ និងការប្តេជ្ញាចិត្តអនុវត្តផែនការសកម្មភាពនេះទាំងនៅក្នុងប្រទេសនិងលើឆាកអន្តរជាតិឱ្យបានក្នុងកម្រិតមួយសមស្រប។

យុទ្ធសាស្ត្រអន្តរាគមន៍សំខាន់ៗមានដូចខាងក្រោម៖

- ធានាថានាវានេសាទទាំងអស់ត្រូវគោរពតាមច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា
- ធានាថាសកម្មភាពនេសាទ ឬសកម្មភាពពាក់ព័ន្ធទាំងអស់ត្រូវគោរពតាមច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជារួមទាំងការនេសាទ ការកែច្នៃ ការនាំចូល និងការនាំចេញ

- អនុវត្តវិធានការនានា ដើម្បីធានាការសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រវាងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងកាត់បន្ថយការត្រួតភារកិច្ចរវាងស្ថាប័ន ឬអង្គភាព
- រក្សាផលស្តុកឱ្យមាននិរន្តរភាពតាមរយៈការកាត់បន្ថយ និងការលុបបំបាត់ការនេសាទអាយយូយូ និងការកែលម្អការគ្រប់គ្រងតាមរយៈការអភិវឌ្ឍផែនការគ្រប់គ្រងជលផល។

**សកម្មភាពជាយុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖**

**ក. រៀបចំអនុវត្តការងាររដ្ឋបាល**

- រៀបចំផ្នែករដ្ឋបាល ដើម្បីចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រទាំងអស់
- ពង្រឹងការអនុវត្តតាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងមន្ទីរសាធារណការនិងដឹកជញ្ជូន ក្នុងការចុះបញ្ជីនាវានេសាទ
- រដ្ឋបាលជលផលត្រូវផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទខ្នាតធំ និងខ្នាតមធ្យមទាំងអស់ និងត្រូវកត់ត្រានាវានេសាទទាំងអស់ដែលមានប្រវែងខ្លីជាង១២ម៉ែត្រដែលមិនមែនជានាវានេសាទអួនអូស
- ផ្តល់សៀវភៅកត់ត្រាស្ថិតិដល់នាវានេសាទខ្នាតធំ និងខ្នាតមធ្យម
- អនុវត្តការវាយតម្លៃផលនេសាទចំពោះការនេសាទខ្នាតតូច
- ចុះបញ្ជីផែនេសាទ និងកន្លែងឡើងផល ផលិតផលជលផលសាធារណៈ និងឯកជនទាំងអស់។

ខ. អនុវត្តយុទ្ធសាស្ត្រ "ការអប់រំតាមរយៈការពិន័យ"

គ. បង្កើតក្រុមការងារបង្ក្រាបនិងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ថ្នាក់ជាតិ និងក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត

ឃ. ផ្គត់ផ្គង់គ្រឿងបរិក្ខារឱ្យបានគ្រប់គ្រាន់ រួមមាននាវាល្បាត ប្រព័ន្ធឃ្លាំមើលនាវានេសាទ និងឧបករណ៍ផ្សេងៗ ដើម្បីអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ។

ដើម្បីអនុវត្តផែនការត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទប្រគល់សិទ្ធិដល់រដ្ឋបាលជលផលក្នុងការកែសម្រួលផែនការសកម្មភាព និងពេលវេលានៅក្នុងតារាងម៉ាទ្រីកទី៨ និងកែសម្រួលសូចនាករគោលដៅដែលសម្រេចបាននៅក្នុងតារាងទី១៣ស្តីពីសូចនាករគោលឱ្យសមស្របទៅតាមការអនុវត្តប្រចាំឆ្នាំនីមួយៗ ដោយធ្វើការពិគ្រោះយោបល់ជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធ។

## ៦.ឧបសម្ព័ន្ធ

### ៦.១. ឧបសម្ព័ន្ធ១ ផែនការសកម្មភាព

នៅពេលផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចត្រូវបានអនុម័តសកម្មភាពអនុវត្តជាក់ស្តែងមានបង្ហាញនៅក្នុងតារាងម៉ាទ្រីកសកម្មភាពទី៨ គួបផ្សំនឹងសកម្មភាពណែនាំអនុវត្តដូចខាងក្រោម៖

**សកម្មភាពទី១. បង្កើតក្រុមបង្ក្រាប និងដោះស្រាយបទល្មើសជលផលកម្រិតធ្ងន់ថ្នាក់ជាតិ និងក្រុមបង្ក្រាបនិងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត**

ក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផល គឺតម្រូវឱ្យមាននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីធានានូវការយកចិត្តទុកដាក់ដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទអាយយូយូដែលមានសកម្មភាពមួយចំនួនដូចខាងក្រោម៖

**ក. រដ្ឋបាលជលផលត្រូវ** សម្របសម្រួលក្នុងការបង្កើតក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផលសមុទ្រកម្រិតធ្ងន់ ដើម្បីអនុវត្តការស៊ើបអង្កេត និងការអន្តរាគមន៍ដែលបានគ្រោងទុក។ ក្រុមការងារនេះរួមមានមន្ត្រីរដ្ឋបាលជលផលមាននីតិសម្បទាជានគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលការពារព្រំដែនទឹក ហើយត្រូវដឹកនាំដោយមន្ត្រីជាន់ខ្ពស់រដ្ឋបាលជលផលដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ។

**ខ. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលជលផល** ជួយសម្របសម្រួលដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផល ក្នុងការបង្កើតក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលនៅតាមខេត្តតំបន់ឆ្នេរនីមួយៗ។ ក្រុមការងារនេះត្រូវអនុវត្តការត្រួតពិនិត្យ និងអធិការកិច្ចជាប្រចាំទៅតាមផែនការដែលបានគ្រោងទុក។ ក្រុមការងារគ្រប់គ្រងការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលថ្នាក់ខេត្ត ត្រូវបង្កើតក្រុមការងារបង្ក្រាប និងដោះស្រាយបទល្មើសជលផលថ្នាក់ខេត្ត ក្នុងខេត្តនីមួយៗ។

**សកម្មភាពទី២. ផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រ**

រដ្ឋបាលជលផលត្រូវចាប់ផ្តើមចេញលិខិតអនុញ្ញាតនេសាទ ដោយមិនរង់ចាំការចុះបញ្ជីនាវានេសាទជាមុននោះទេ។ រដ្ឋបាលជលផលត្រូវជំរុញឱ្យម្ចាស់នាវានេសាទសមុទ្រចុះបញ្ជីជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកសមុទ្រ និងកំពង់ផែ និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតាមតំបន់ឆ្នេរ។ រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តតាមសកម្មភាពមួយចំនួនដូចខាងក្រោម៖

ក. រៀបចំ និងធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងនាវានេសាទរួមមាន ផ្នែកផ្តល់លិខិតអនុញ្ញាត ផ្នែកប្រមូល និងវាយតម្លៃផលនេសាទ ផ្នែកកត់ត្រាផែនេសាទ និងកន្លែងឡើងផលនេសាទ និងអនុវត្តប្រព័ន្ធតាមដាននាវានេសាទ ដែលមានប្រវែងវែងជាង១២ម៉ែត្រ និងនាវានេសាទអូនអូសទាំងអស់។

ក.១. ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រដែលបានផ្តល់ប័ណ្ណជំរឿន ត្រូវផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទ។ ទិន្នន័យនាវានេសាទសមុទ្រនេះត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានជំរឿននាវានេសាទសមុទ្រ។ កំណត់ចំណាំ៖ច្បាប់ស្តីពីជលផល ដែលបានកែសម្រួលឬធ្វើវិសោធនកម្មថ្មី (នាវាដែលបានទទួលប័ណ្ណជំរឿន) ត្រូវចាត់ទុកថាជាកំណត់ត្រាអំពីនាវានេសាទសមុទ្ររបស់ កម្ពុជា។ ផែនការអនុវត្តមានដូចខាងក្រោម៖

- ឆ្នាំទី១ រៀបចំផែនការសម្រាប់ក្រុមផ្តល់លិខិតអនុញ្ញាត និងតារាងពេលវេលាតាមខេត្តតំបន់ឆ្នេរទាំង៤

- ឆ្នាំទី២ ចាប់ផ្ដើមពីការផ្ដល់លិខិតអនុញ្ញាតនាវានេសាទសមុទ្រខ្នាតធំ និងខ្នាតមធ្យម ដែលមានប្រវែងវែងជាង១៨ម៉ែត្រ
- ចាប់ពីឆ្នាំទី៣ដល់ឆ្នាំទី៥ ត្រូវអនុវត្តតាមតារាងម៉ាទ្រីកទី៨។

**បន្ថែមលើសកម្មភាពក្នុងចំណុច (ក) ការងារសំខាន់ៗ ត្រូវអនុវត្តព្រមគ្នាមានដូចជា៖**

ខ. ចាប់ផ្ដើមត្រួតពិនិត្យនាវានេសាទសមុទ្រនៅតាមឆ្នេរសមុទ្រ និងផែនេសាទ ក្នុងកម្រិត៥%នៃចំនួននាវានេសាទសមុទ្រក្នុងមួយខែក្នុងមួយខេត្ត

គ. រដ្ឋបាលជលផលត្រូវរៀបចំផែនការអនុវត្តប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលដោយសហការជាមួយខណ្ឌរដ្ឋបាលជលផល

ឃ. រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងនាវានេសាទដូចជាកម្មវិធីទូរស័ព្ទដៃសម្រាប់ចុះបញ្ជី ផ្ដល់លិខិតអនុញ្ញាត និងសៀវភៅកត់ត្រាស្ថិតិដល់នាវានេសាទខ្នាតធំ និងមធ្យម

ង. សៀវភៅកត់ត្រាស្ថិតិ៖

- នាវានេសាទខ្នាតធំ និងមធ្យម ដែលមានលិខិតអនុញ្ញាតត្រូវមានភ្ជាប់សៀវភៅកត់ត្រាស្ថិតិ
- សៀវភៅកត់ត្រាស្ថិតិត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់និងបញ្ជាក់ដោយខណ្ឌរដ្ឋបាលជលផលជារៀងរាល់ខែ

ច. ទិន្នន័យផលនេសាទនៃនាវានេសាទខ្នាតមធ្យមនិងខ្នាតតូចត្រូវធ្វើការវាយតម្លៃយ៉ាងតិចពីរឆ្នាំម្ដង

ឆ. ស្រង់ស្ថិតិផែនេសាទ និងកន្លែងឡើងផល ផលិតផលនេសាទទាំងអស់។

**សកម្មភាពទី៣. ការការពារ និងអភិរក្សធនធានជលផល**

មាត្រា១៨បានចាត់ថ្នាក់កន្លែងការពារ និងអភិរក្សជាពិសេសតំបន់ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង។ តំបន់ការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ីមានសារសំខាន់សម្រាប់ជីវិតរស់នៅរបស់បង្កង បង្គា សប្បីសត្វ និងតំបន់ចិញ្ចឹមជីវិតរបស់ពួកកូនវារិសត្វនានា ដូច្នេះការការពារវាជាការចាំបាច់សម្រាប់និរន្តរភាពវិស័យជលផល។ ការប្រែប្រួលទីជម្រកដ៏សំខាន់នៃស្មៅសមុទ្រ ផ្កាថ្ម និងព្រៃកោងកាង ធ្វើឱ្យមានបម្រែបម្រួលប្រភេទវារិសត្វ។

ការត្រួតពិនិត្យបទល្មើសជាសកម្មភាពសំខាន់ ខណៈការតាមដាន និងការឃ្លាំមើលក៏អាចប្រើជាយុទ្ធសាស្ត្រដើម្បីទប់ស្កាត់ និងលុបបំបាត់ការនេសាទអាយយូយូដ៏មានប្រសិទ្ធភាពផងដែរ។

រដ្ឋបាលជលផលបានចាប់ផ្ដើមមានវិធានការ ទប់ស្កាត់ និងរារាំងការនេសាទក្នុងតំបន់ដែលងាយរងគ្រោះដូចជា តំបន់ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង ដោយដាក់ប្រអប់បេតុង និងបោះបង្គោល ដើម្បីការពារការនេសាទដោយនាវានេសាទខ្នាតធំ និងខ្នាតមធ្យម។ ប្រអប់បេតុងត្រូវដាក់នៅតាមជាយៗតំបន់ផ្កាថ្ម និងស្មៅសមុទ្រ ប៉ុន្តែមិនត្រូវដាក់ពង្រាយក្នុងកន្លែងដែលអាចបំផ្លិចបំផ្លាញដល់តំបន់ទាំងនោះ។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

ក. កំណត់អត្តសញ្ញាណតំបន់ផ្កាថ្ម ស្មៅសមុទ្រ និងតំបន់ព្រៃកោងកាង

ខ. គូសផែនទីតំបន់ទាំងនោះ និងតំបន់ទ្រនាប់របស់វា ហើយកំណត់ថាជាតំបន់ការពារ និងអភិរក្សដែលហាមឃាត់ការនេសាទ។ ការហាមឃាត់នេះគឺជាផ្នែកមួយនៃលក្ខខណ្ឌក្នុងការនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (ហួសពី១២ម៉ាយ) និងត្រូវកំណត់ថាជាតំបន់ដែលមានសារសំខាន់ក្នុងការអភិរក្ស

គ. ចាប់ផ្ដើមសាងសង់ "ប្រអប់ថ្ម" ឱ្យបានគ្រប់ចំនួនដែលអាចដាក់ពង្រាយពាសពេញក្នុងតំបន់ដែលត្រូវទប់ស្កាត់ និងរារាំងការនេសាទ។ រដ្ឋបាលជលផលសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការដាក់ពង្រាយប្រអប់ថ្ម

ឃ. ធ្វើសកម្មភាពល្បាតដោយនាវាក្នុងតំបន់ការពារ និងអភិរក្សទីជម្រក ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ។ ការល្បាតចំណាយពេលវេលាប្រមាណ២០% នៅក្នុង និងនៅជិតតំបន់ការពារ និងអភិរក្ស

ង. បង្កើតប្រព័ន្ធតាមដាន និងអង្កេត។

**សកម្មភាពទី៤. ផ្ដោតគោលដៅចំពោះឧបករណ៍នេសាទខុសច្បាប់ និងការនេសាទខុសច្បាប់**

ការប្រើឧបករណ៍នេសាទខុសច្បាប់បានបំផ្លិចបំផ្លាញយ៉ាងខ្លាំងលើធនធានវារិជាតិ ទីជម្រក និងប្រព័ន្ធអេកូឡូស៊ី។ ផលនេសាទដែលបានពីឧបករណ៍នេសាទខុសច្បាប់ធ្វើឱ្យប៉ះពាល់ដល់ការទទួលតម្លៃប្រាក់ចំណេញនៃការនេសាទស្របច្បាប់ និងធ្វើឱ្យអ្នកនេសាទស្របច្បាប់ ពិបាកក្នុងការធ្វើនេសាទ ឬប្រឈមមុខនឹងការមិនគោរពតាមច្បាប់ផងដែរ ហើយចាប់ផ្ដើមនេសាទខុសច្បាប់ដូចគ្នា។ ដូច្នេះរដ្ឋបាលជលផលត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមសេចក្ដីប្រកាសលេខ៣១៩ប្រ.ក.ក.ស.ក ស្ដីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យនេសាទក្នុងដែនសមុទ្រ និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយផ្អែកលើការសិក្សាវាយតម្លៃបច្ចេកទេសឧបករណ៍នេសាទថ្មីៗ។

រៀបចំបញ្ជីឧបករណ៍នេសាទខុសច្បាប់មានដូចជាអួនអូសប្រដាប់ដោយគ្រឿងឆក់ លបប្រើសច្រើន ឈ្នាងអូសឈ្លើងសមុទ្រ អួនក្រឡាញឹកនៅផ្នែកកន្ទុយអួន អួនអូសគូ អួនហោះ និងនេសាទប្រើភ្លើងពេលយប់។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

ក. រៀបចំផែនការរួមជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីត្រួតពិនិត្យឧបករណ៍នេសាទខុសច្បាប់

ខ. ត្រួតពិនិត្យនាវានេសាទ៥% ក្នុង១ខែ ក្នុង១ខេត្ត

គ. កំណត់គោលដៅបឋមសម្រាប់ល្បាតតាមព្រំដែនប្រចាំត្រីមាស

ឃ. ល្បាតដោយនាវានៅពេលយប់ដោយក្រុមយប់ និងល្បាតដោយរថយន្តចុះពិនិត្យផែនេសាទពេលថ្ងៃដោយក្រុមថ្ងៃ

ង. ល្បាតដោយនាវានៅតំបន់ការពារ និងអភិរក្សទីជម្រក ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ។ ចំណាយ ២០% នៃការល្បាតនៅក្នុង និងជិតតំបន់ការពារ និងអភិរក្ស

ច. រឹបអូស និងបំផ្លាញឧបករណ៍នេសាទខុសច្បាប់ទាំងអស់តាមនីតិវិធីត្រឹមត្រូវ

ឆ. ចេញលិខិតព្រមានផ្លូវការដល់ជនល្មើសទាំងអស់ និងចម្លងជូនអភិបាលខេត្ត និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ជ.ធ្វើការសិក្សាប្រៀបធៀប ដើម្បីកំណត់ផលប៉ះពាល់នៃឧបករណ៍នេសាទលើពពួកវារិសត្វគោលដៅ ពពួកវារិសត្វមិនមែនគោលដៅ ទីជម្រកស្រទាប់បាតឬផលប៉ះពាល់បរិស្ថានផ្សេងទៀត។

**សកម្មភាពទី៥. នាវានេសាទបរទេស និងធនធានជលផលក្នុងតំបន់ព្រំដែនសមុទ្រ**

បច្ចុប្បន្នគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ គណៈកម្មការបង្ក្រាបបទល្មើសនានា និងការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ និងនគរបាលការពារព្រំដែនទឹកក៏មានភារកិច្ចល្បាត និងត្រួតពិនិត្យតំបន់នៅតាមព្រំដែនសមុទ្រផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលជាសេនាធិការត្រូវសម្របសម្រួលរៀបចំផែនការ និងអនុវត្តផែនការល្បាតជាមួយស្ថាប័នទាំងអស់ខាងលើ។ រដ្ឋបាលជលផលត្រូវបង្កើនប្រសិទ្ធភាពត្រួតពិនិត្យតាមតំបន់ព្រំដែនសមុទ្រដែលស្ថិតនៅក្រោមយុត្តាធិការជាតិ និងអនុវត្តការល្បាតសមុទ្រយ៉ាងហោចណាស់ម្ដងនៅតំបន់ព្រំដែននីមួយៗ ដែលមានរយៈពេលយ៉ាងតិច៤ថ្ងៃក្នុងមួយសប្ដាហ៍។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

ក. ធ្វើការទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ គណៈកម្មការបង្ក្រាបបទល្មើសនានា និងការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងនគរបាលការពារព្រំដែនទឹក ដើម្បីរៀបចំផែនការល្បាតប្រចាំត្រីមាស និងល្បាតក្នុងតំបន់ស្ថិតនៅក្រោមយុត្តាធិការជាតិ។

ខ. រដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវល្បាតដោយនាវាយ៉ាងហោចណាស់១ដងក្នុងតំបន់តាមព្រំដែនយ៉ាងតិច៤ថ្ងៃក្នុងមួយសប្តាហ៍។

គ. រដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវបង្កើតផែនការប្រតិបត្តិការមួយស្តីពីរបៀបដោះស្រាយជាមួយនឹងនាវាដែលបានប្រទះឃើញនិងឃាត់ទុក។

**សកម្មភាពទី៦. ការគ្រប់គ្រងការនាំចូល និងនាំចេញផល ផលិតផលជលផលសមុទ្រ**

ច្បាប់ជលផលបច្ចុប្បន្នបានចែងថាការនាំចូល និងនាំចេញត្រូវមានលិខិតអនុញ្ញាតក៏ដោយប៉ុន្តែការអនុវត្តច្បាប់នៅមានកម្រិត។ ការនាំចេញ និងការនាំចូលផល ផលិតផលជលផលរស់ ឬស្រស់លើសពី១០គីឡូក្រាមត្រូវមានលិខិតអនុញ្ញាត។

រដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ខេត្តត្រូវទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីរៀបចំវិធីសាស្ត្ររួមមួយក្នុងការត្រួតពិនិត្យការនាំចូល និងនាំចេញផល ផលិតផលជលផលនៅតាមព្រំដែនក៏ដូចជាការអនុម័តលេខកូដពាណិជ្ជកម្ម ដែលមានលក្ខណៈស៊ីចង្វាក់ដើម្បីកំណត់ផល ផលិតផលជលផល។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

**ក.** រៀបចំ ឬពិនិត្យឡើងវិញនូវដំណើរការចេញលិខិតអនុញ្ញាតនាំចូល និងនាំចេញ និងទំនាក់ទំនងជាមួយភ្នាក់ងារដឹកជញ្ជូន ភ្នាក់ងារនាំចេញ និងនាំចូលរួមទាំងការប្រើលេខកូតក្នុងតារាងស្តង់ដារតម្លៃ។

**ខ.** សហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ រៀបចំវិធីសាស្ត្ររួមមួយដើម្បីផ្ទៀងផ្ទាត់ និងត្រួតពិនិត្យការនាំចូល និងនាំចេញផល ផលិតផលជលផលនៅតាមព្រំដែន។

**គ.** ចាប់ផ្តើមត្រួតពិនិត្យដោយក្រុមប្តូរវេនគ្នានៅតាមព្រំដែន កំពង់ផែនិងកន្លែងឡើងផល ផលិតផលជលផល។

**ដើម្បីអនុវត្តសកម្មភាពខាងលើឱ្យមានប្រសិទ្ធភាព ធនធានមនុស្សនិងសម្ភារចាំបាច់មួយចំនួនត្រូវការជាចាំបាច់មានដូចជា៖**

- មន្ត្រីដែលមានជំនាញផ្នែកច្បាប់ និងថវិកាដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- បន្ថែមមន្ត្រីគឺខេត្តកែប៦រូប ខេត្តកំពត៨រូប ខេត្តព្រះសីហនុ៦រូប និងខេត្តកោះកុង៩រូប
- ធនធានមនុស្សដើម្បីដំណើរការក្នុងការផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលដែលអាចជាលិខិត ឬការចុះឈ្មោះសុំលិខិតអនុញ្ញាតតាមរយៈប្រព័ន្ធអេឡិចត្រូនិកនៅតាមកម្មវិធីទូរស័ព្ទ ឬប្រព័ន្ធកុំព្យូទ័រអនឡាញ
- ធនធានដើម្បីធានានូវការការពារ និងការស្តារទីជម្រកជាមួយនឹងការសាងសង់ប្រអប់ថ្ម
- ផលិតផែនទីដែលរៀបរាប់លម្អិតអំពីតំបន់ផ្កាថ្ម ស្មៅសមុទ្រ និងកោងកាងដើម្បីកំណត់ព្រំប្រទល់តំបន់ការពារ និងអភិរក្ស
- ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលដើម្បីតាមដាននាវានេសាទទាំងអស់
- នាវាល្បាតខ្នាតធំមួយ (ប្រវែង ២០-៣០ម៉ែត្រ) សំបកដែកមានរបាំងការពារ មានល្បឿនលឿន ដើម្បីល្បាតនៅតាមតំបន់ព្រំដែននិងក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ព្រមទាំងមានបំពាក់នាវាត្រួតពិនិត្យខ្នាតតូចដើម្បីល្បាតក្នុងតំបន់ទឹករាក់ និងតាមឆ្នេរសមុទ្រ

- នាវាល្បាតខ្នាតតូច៥ (ប្រវែងប្រហែល១២ម៉ែត្រ) ដែលមានរបាំងការពារ និងការពារស្លាបចក្រដើម្បីល្បាត ក្នុងតំបន់ទឹករាក់ និងល្បាតក្នុងតំបន់ឆ្នេរសមុទ្រ
- រថយន្តល្បាត៣-៦គ្រឿងសម្រាប់ត្រួតពិនិត្យនៅផែនេសាទ និងកន្លែងឡើងផលផលិតផលនេសាទ។

### ៦.២. ឧបសម្ព័ន្ធ២

#### ក.ការបែងចែកកន្លែងនេសាទក្នុងតំបន់ឆ្នេរ

បញ្ហាសំខាន់បំផុតមួយដែលនាវានេសាទអួនអូសស្រទាប់បាតមិនអាចអនុវត្តបាន គឺការធ្វើនេសាទនៅក្នុងតំបន់ហាមឃាត់ដែលស្ថិតនៅក្នុងតំបន់ខ្សែបន្ទាត់ជម្រៅទឹក២០ម៉ែត្រ។ ប្រភេទផលនេសាទចម្បងសំខាន់ៗដែលនេសាទបានដោយនាវាអួនអូសគឺបង្គាដែលរស់នៅក្នុងល្បាប់ភក់ ខ្សាច់រាក់ៗ ថ្មតូចៗ ផ្កាថ្ម និងស្មៅសមុទ្រក្នុងបាតសមុទ្រ។ នាវានេសាទជាពិសេសនាវាអួនអូសធ្វើនេសាទនៅតាមតំបន់ឆ្នេរដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ ដោយមិនគិតពីសណ្ឋានដីស្រទាប់បាត។ ការបែងចែកកន្លែងនេសាទសម្រាប់អួនអូសក្នុងដែនទឹកដែលមានជម្រៅទឹក២០ម៉ែត្រគឺត្រូវបានស្នើឡើង។ ទោះជាយ៉ាងណាក៏ដោយតំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងតំបន់ដែលនៅជិតនឹងព្រៃកោងកាង (ដោយមិនគិតពីតំបន់កំណកកករហូរចាក់តាមមាត់ពាម) ត្រូវដាក់ជាកន្លែងការពារ ឬកន្លែងអភិរក្ស។ នាវាអួនអូសខ្នាតធំ និងខ្នាតមធ្យមភាគច្រើនមានឧបករណ៍កំណត់ទីតាំង (GPS) ដូច្នេះនាវាអួនអូសខ្នាតតូច គួរតែមានបំពាក់ឧបករណ៍កំណត់ទីតាំងដើម្បីជួយសម្រួលដល់ការកំណត់ទីតាំងក្នុងពេលធ្វើនេសាទ។ និយាមកាកំណត់ទីតាំងហាមឃាត់ក្នុងការធ្វើនេសាទអួនអូស ត្រូវបញ្ចូលក្នុងឧបករណ៍កំណត់ទីតាំងរបស់នាវានេសាទអួនអូស។ ការបំពាក់ជាបន្ទាន់នៃប្រព័ន្ធតាមដានត្រួតពិនិត្យលើនាវាអួនអូសទាំងអស់នឹងជួយសម្រួលដល់ការអនុវត្តតាមការបែងចែកកន្លែងនេសាទ និងជួយសម្រួលដល់លទ្ធភាពក្នុងការករកើតឡើងវិញនូវធនធានវារិជាតិក្នុងកន្លែងការពារ និងកន្លែងអភិរក្ស។

រដ្ឋបាលជលផលត្រូវចាប់ផ្តើមរៀបចំលិខិតបទដ្ឋានច្បាប់នានាជាបន្ទាន់ដើម្បីបែងចែកតំបន់នេសាទនៅក្នុងខ្សែបន្ទាត់ជម្រៅទឹករាក់ជាង២០ម៉ែត្រ។ ការបែងចែកតំបន់ទាំងនេះត្រូវមានចែងជាលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

ប្រកាសស្តីពីការរៀបចំតំបន់ទាំងនេះត្រូវអនុម័តយល់ព្រមដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

#### ខ. វិធានការអកម្មដើម្បីបង្កើនការការពារបរិស្ថាន និងទប់ស្កាត់នាវាអួនអូស

ទិន្នន័យស្រាវជ្រាវនិងទិន្នន័យវាយតម្លៃបានបង្ហាញថារបាយស្មៅសមុទ្រនៅមានចំណុចត្រូវកែលម្អ។ នៅខេត្តកោះកុង ក៏មានរបាយស្មៅសមុទ្រច្រើនដែរ។ ឆកកំពង់សោមស្ទើរតែគ្មានរបាយស្មៅសមុទ្រទេ។ ខណៈដែលផលប៉ះពាល់នៃប្រព័ន្ធអេកូឡូស៊ីមានសារសំខាន់នោះស្មៅសមុទ្រត្រូវបានដាំសារជាថ្មី ពិសេសក្នុងតំបន់ដែលមានភាពកករ។ ប្រសិនបើស្មៅសមុទ្រត្រូវបានដាំឡើងវិញនោះព្រៃកោងកាងគួរតែត្រូវបានដាំឡើងវិញដែរ ដើម្បីកាត់បន្ថយភាពកករ។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- រៀបចំតារាងម៉ាទ្រីកសកម្មភាពសម្រាប់អាទិភាពកន្លែងការពារ និងកន្លែងអភិរក្ស
- ជ្រើសរើសតំបន់ស្មៅសមុទ្រដែលមានគុណភាពល្អជាអាទិភាពខ្ពស់បំផុត
- ជ្រើសរើសតំបន់ស្មៅសមុទ្រ (មិនគិតពីគុណភាព) ដែលមានសារៈសំខាន់ដល់ប្រភេទសត្វជិតផុតពូជ ឬតំបន់ចិញ្ចឹមជីវិតសម្រាប់កូនវារិសត្វដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់មានអាទិភាពខ្ពស់បំផុត
- ជ្រើសរើសតំបន់មានការរំខាន ប៉ុន្តែមិនធ្វើឱ្យខូចខាតស្រទាប់បាតនៃស្មៅសមុទ្រជាអាទិភាពទី២។

កែលម្អបំណែកតូចៗនៃស្មៅសមុទ្រទៅជាបណ្តុំធំៗ ឬវាលស្មៅសមុទ្រនៅជាច់ៗគ្នានៃរុក្ខជាតិសមុទ្រ ជ្រើសរើសតំបន់សាកល្បងដើម្បីកំណត់ថា តើបណ្តុំធំៗនៃស្មៅសមុទ្រអាចនឹងកកើតឡើងវិញបាន។

អាទិភាពទី៣ ស្វែងរកប្រភពមូលនិធិដើម្បីធ្វើវិនិយោគ

### គ.ការសាងសង់និងការដាក់ពង្រាយប្រអប់ថ្ម

ការសាងសង់ប្រអប់ថ្មមានមុខងារចម្បងគឺដើម្បីកាត់បន្ថយការធ្វើនេសាទក្នុងតំបន់ស្មៅសមុទ្រ និងផ្កាថ្មដែលបានជ្រើសរើស (រូបទី២.១ និង២.២) ។ ប្រអប់ថ្មប្រឆាំងនឹងនាវាអួនអូស(រូបទី២.១) ដើម្បីការពារជាចម្បងប្រឆាំងនឹងនាវាអួនអូសក្នុងតំបន់ហាមឃាត់។

ការសាងសង់ប្រអប់ថ្ម (រូបទី២.២) ដើម្បីប្រឆាំងនឹងឧបករណ៍នេសាទដទៃទៀត។

ការសាងសង់ប្រអប់ថ្ម (រូបទី២.៣) ដើម្បីស្តារទីជម្រកនឹងត្រូវបានធ្វើឡើងជាបន្តបន្ទាប់។

**រូបទី ២.១.ប្រអប់ថ្មប្រឆាំងនឹងឧបករណ៍នេសាទអួនអូស**




វិធីសាស្រ្តសាងសង់៖ ធ្វើពីស៊ីម៉ងត៍ទំហំ១ម x១ម x0,៣ម (ថ្ម ខ្សាច់ ស៊ីម៉ងត៍ ដែកសរសៃ) ដែលមានដែកផ្លូវរថភ្លើងទំហំ៤x 0,៨0ម កាច់កោង៣0ដឺក្រេ និងដោតនៅកម្ពស់0.២៥ សង់ទីម៉ែត្រពីផ្ទៃខាងលើ។

ការដាក់ពង្រាយ៖ ដាក់ចន្លោះ១ពីគ្នាកម្រិត៣៥% ក្នុងទំហំ ១00ហិកតា។ (ដាក់៦៥ប្រអប់ថ្មប្រឆាំងនឹងនាវានេសាទអួនអូសក្នុង១00ហិកតា)។ ដាក់ពង្រាយដំបូងនៅតាមផ្លូវ ឬទិសដៅពីនាវានេសាទខុសច្បាប់បើកសំដៅទៅតំបន់ស្មៅសមុទ្រ។ ព្យាយាមកំណត់អត្តសញ្ញាណតំបន់ស្មៅសមុទ្រល្អបំផុត ឬតំបន់ស្មៅសមុទ្រក្រាស់បំផុត និងធានាការដាក់ប្រអប់ថ្មនៅជិតកន្លែងតំបន់ស្មៅដ៏ល្អឥតខ្ចោះទាំងនេះ។

**រូបទី ២.២.ប្រអប់ថ្មប្រឆាំងនឹងឧបករណ៍នេសាទ**




**វិធីសាស្រ្តសាងសង់៖** ធ្វើពីបេតុងទំហំ0,៥មx0,៥មx0,៥ម ដាក់លើដុំបេតុងបាតទំហំ 0,៧៥ម x 0,៧៥ម x0.១ម (ថ្ម ខ្សាច់ ស៊ីម៉ងត៍ ដែកសរសៃ); ដែកសរសៃទំហំ១៦មម ចំនួន៤ដើម x១ម -បង្កប់ក្នុងប្លុកជម្រៅ១.៥ដ.ម ដោតពីលើកម្ពស់៣0 - ៦0 ស.ម។ ចោះរន្ធ៤ ទុកបន្ថែមទំហំ ២0មម ដើម្បីជំនួសការបាក់ ឬខូចនាពេលអនាគត។

**ការដាក់ពង្រាយ៖** ដាក់ចន្លោះ១ពីគ្នាកម្រិត៣៥% ក្នុងទំហំ១00ហិកតា។ (ដាក់៦៥ប្រអប់ថ្មប្រឆាំងនឹងនាវានេសាទត្រីក្នុង១00ហិកតា) ។ ព្យាយាមដាក់ពង្រាយប្រអប់ថ្មទាំងនេះនៅក្នុងចន្លោះបណ្តុំផ្កាថ្មនីមួយៗ។

**រូបទី ២.៣.ប្រអប់ថ្មជាជម្រកវារិសត្វ**



**វិធីសាស្រ្តសាងសង់៖** ធ្វើប្រអប់ថ្មប្រហោងទំហំ ៣ម x៣មx៣ម ដែលមានជ្រុងនីមួយៗទំហំ០.១ម x០.១ម x០.១ម (ថ្ម ខ្សាច់ ស៊ីម៉ង់ត៍ដែកសរសៃធ្វើជាឆ្អឹងខាងក្នុង)

**ការដាក់ពង្រាយ៖** ជ្រើសរើសកន្លែងទីជម្រកល្អបំផុតសម្រាប់ត្រីកាម៉ុង (ពិចារណាជម្រៅទឹក និងគុណភាពទឹក) ។

អត្រានៃការដាក់ពង្រាយគឺប្រមាណ៥ប្រអប់ ក្នុង១០០ ហិកតា។ ការរចនាខាងក្រោមមានភាពស្មុគស្មាញប៉ុន្តែការរចនារូបរាងរាបស្មើ និងការតម្រៀបឆ្លងកាត់នឹងងាយស្រួល។

## ឃ. ការសម្របសម្រួល និងសមត្ថភាព

យោងតាមការកែទម្រង់មុខងារសាធារណៈ អាជ្ញាធរខេត្តមានសិទ្ធិអំណាចគ្រប់គ្រងធនធានជលផលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការកែទម្រង់នេះសមស្របសម្រាប់ការគ្រប់គ្រងការនេសាទទឹកសាប ប៉ុន្តែយោងតាមច្បាប់ស្តីពីជលផល ដែនយុត្តាធិការរបស់អាជ្ញាធរខេត្តបញ្ចប់នៅត្រឹមដែននៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ តាមការអនុវត្តជាក់ស្តែងការគ្រប់គ្រងធនធានធម្មជាតិប្រចាំថ្ងៃគឺជាភារកិច្ចរបស់អាជ្ញាធរខេត្ត។ ប៉ុន្តែអាជ្ញាធរខេត្តមិនទាន់មានយន្តការគ្រប់គ្រង និងបង្រ្កាបបទល្មើសនេសាទឆ្លងព្រំដែនខេត្តនោះទេ។ ដូច្នេះអាជ្ញាធរខេត្តតំបន់ឆ្នេរគួរបង្កើតកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីគ្រប់គ្រងធនធានជលផល និងបង្រ្កាបបទល្មើសជលផលរួមគ្នា។

រដ្ឋបាលជលផលមានធនធាន មធ្យោបាយ និងសម្ភារប្រសើរជាងខណ្ឌរដ្ឋបាលជលផល ដូចជានាវាល្បាត និងសមត្ថភាព មន្រ្តីក្នុងការបង្រ្កាបបទល្មើស។ ធនធាន មធ្យោបាយ និងសម្ភារសម្រាប់បង្រ្កាបបទល្មើសរបស់អាជ្ញាធរខេត្តភាគច្រើន មិនដំណើរការបានល្អ ធ្វើឱ្យមានការពិបាកក្នុងការធ្វើការត្រួតពិនិត្យនិងអធិការកិច្ចប្រកបដោយប្រសិទ្ធភាពនៅតាមបណ្តាខេត្តតំបន់ឆ្នេរ។ ដូច្នេះរដ្ឋបាលជលផល ត្រូវធ្វើកិច្ចសហប្រតិបត្តិការ និងជួយដល់ខណ្ឌរដ្ឋ-បាលជលផលនៃខេត្តនីមួយៗ ក្នុងការល្បាតតាមដែននេសាទសមុទ្ររបស់ខ្លួនក្នុងតំបន់ឆ្នេរ (តំបន់ក្នុងខ្សែបន្ទាត់ដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ) យ៉ាងតិច៧ថ្ងៃក្នុងមួយខែក្នុងរយៈពេល៥ឆ្នាំ រហូតដល់ខណ្ឌរដ្ឋបាលជលផលមានធនធានជាក់លាក់ និងឧបករណ៍ល្បាតគ្រប់គ្រាន់ ដើម្បីអនុវត្តការល្បាតបានដោយខ្លួនឯង។

## ៦.៣. ឧបសម្ព័ន្ធ៣. ការអនុវត្តប្រព័ន្ធតាមដាននាវានេសាទ

ការរៀបចំសម្រាប់ការដាក់ឱ្យប្រើប្រព័ន្ធតាមដាននាវានេសាទដោយទូរស័ព្ទដៃ៖

**ការរៀបចំនីតិវិធី៖**

**ក.** រដ្ឋបាលជលផលត្រូវជ្រើសរើសអ្នកផ្តល់សេវាកម្ម សម្រាប់ផ្តល់ទិន្នន័យ (ទីតាំងរបស់នាវា) រួមទាំងកម្មវិធីផ្នែករឹង ផ្នែកទន់ និងការបណ្តុះបណ្តាល ដល់ការិយាល័យតាមដានត្រួតពិនិត្យនាវានេសាទ។

**ខ.** អ្នកផ្តល់សេវាកម្មដែលបានជ្រើសរើសនឹងលក់ឧបករណ៍តាមដាននាវានេសាទ ទៅឱ្យអ្នកនេសាទ ដោយបង្កើតកិច្ចសន្យាផ្លូវការសម្រាប់រយៈពេល២ឆ្នាំ។

**គ.** ឧបករណ៍តាមដាននាវានេសាទ ដែលលក់ឱ្យអ្នកនេសាទគួររួមបញ្ចូលនូវមុខងារដែលមានអត្ថប្រយោជន៍ដល់អ្នកនេសាទផ្ទាល់ដូចជា ប្រព័ន្ធរាវទីដោយស្វ័យប្រវត្តិ។

**ឃ.** នាវានេសាទត្រូវបានបំពាក់ឧបករណ៍តាមដាន មុនពេលដែលម្ចាស់ស្នើសុំលិខិតអនុញ្ញាតឱ្យធ្វើនេសាទ។

កាលវិភាគនៃការអនុវត្តប្រព័ន្ធតាមដាននាវានេសាទត្រូវចាប់ផ្តើមបំពាក់ឧបករណ៍តាមដាននាវានេសាទពីនាវាខ្នាតធំ និងខ្នាតមធ្យមមុន។

**តម្លៃ៖** នាវានេសាទខ្នាតធំ និងមធ្យមតម្រូវឱ្យទិញឧបករណ៍ប្រព័ន្ធតាមដាននាវានេសាទ និងកិច្ចសន្យាសេវាទូរស័ព្ទ។ ចំពោះនេសាទអូនអូសខ្នាតតូច(ប្រវែងខ្លីជាង១២ម៉ែត្រ) ឧបករណ៍តាមដាននាវានេសាទ ត្រូវមានការឧបត្ថម្ភពីរដ្ឋាភិបាល។

ប្រព័ន្ធតាមដាននាវានេសាទបំពាក់លើនាវាអូនអូសខ្នាតតូច (ប្រវែងខ្លីជាង១២ម៉ែត្រ) ត្រូវដាក់នៅឆ្នាំទី៣នៃការអនុវត្តផែនការ។ ការឧបត្ថម្ភឧបករណ៍ទាំងនេះអាចទូទាត់ដោយផ្ទាល់ទៅឱ្យអ្នកផ្គត់ផ្គង់ដោយផ្អែកលើចំនួននៃការលក់ (អ្នកនេសាទមិនត្រូវបង់ប្រាក់ទេ) ឬការបញ្ចុះថ្លៃលើលិខិតអនុញ្ញាតសម្រាប់ឆ្នាំទី១នៃការអនុវត្តផែនការ។

### ៦.៤. ឧបសម្ព័ន្ធ៤ ការវាយតម្លៃផលនេសាទ

ការរៀបចំសម្រាប់ការវាយតម្លៃផលនេសាទសមុទ្រគឺ៖

សៀវភៅកត់ត្រាស្ថិតិត្រូវដាក់ឱ្យប្រើសម្រាប់តែនាវានេសាទខ្នាតធំ និងមធ្យម ព្រោះវាត្រូវការធនធានច្រើនសម្រាប់ដំណើរការ។ សៀវភៅកត់ត្រាស្ថិតិនាវានេសាទខ្នាតមធ្យមដែលមានប្រមាណពី២០០០ទៅ៣០០០គ្រឿងមិនសូវមានអត្ថប្រយោជន៍ទេ។ ព័ត៌មានភាគច្រើនគឺមិនអាចទុកចិត្តបាន។

លើសពីនេះទៅទៀតការវាយតម្លៃផលនេសាទត្រូវពឹងផ្អែកលើវិធានការចម្រុះដូចខាងក្រោម៖

**ក.** របាយការណ៍នេសាទដោយស្ម័គ្រចិត្តរបស់អ្នកនេសាទដោយប្រើកម្មវិធីកត់ត្រាដូចជា Smart ឬ Abalobi (តាមបទពិសោធនានាត្រូវយកប្រមាណ២០% ពីអ្នកនេសាទខ្នាតតូចដែលភាគច្រើនជាស្ត្រី ដែលយល់ឃើញថាកម្មវិធីនេះមានប្រយោជន៍ ដើម្បីកត់ត្រាការលក់ និងគ្រប់គ្រងអាជីវកម្មគ្រួសារ)

**ខ.** ការវាយតម្លៃផលនេសាទសមុទ្រត្រូវអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្ររួមមាន៖

ខ.១. វាយតម្លៃផលនេសាទសមុទ្រតាមរយៈការកត់ត្រានៅតាមផែនេសាទ ឬកន្លែងឡើងផលនេសាទពីនាវានេសាទទាំងអស់ដោយជ្រើសរើសផែនេសាទ ឬកន្លែងឡើងត្រីក្នុងចំនួនថ្ងៃកំណត់មួយ ហើយត្រូវអនុវត្តឡើងវិញក្នុងរយៈពេល២ឆ្នាំម្តង។ ការវាយតម្លៃនេះនឹងផ្តល់ការយល់ដឹងល្អអំពីស្ថានភាពផលស្តុក និងការប្រែប្រួលរបស់វា (តាមរយៈការធ្វើឡើងវិញ)។

ខ.២. ការយកស្ថិតិពីផែនេសាទ ឬកន្លែងឡើងផលនេសាទដែលបានជ្រើសរើស ត្រូវធ្វើឡើងពេញ១ឆ្នាំ។ ស្ថិតិនេះផ្តល់ជារបាយការណ៍ស្ថិតិប្រចាំខែ និងប្រចាំឆ្នាំ។

## ឯកសារយោង


1. UNIDO/MAFF 2015: Value Chain Assessment of Marine Fisheries Sector and Roadmap for Development. United Nations Industrial Development Organization/ Ministry of Agriculture, Forestry and Fisheries.
2. MAFF (2015): The Strategic Planning Framework for Fisheries: Update for 2015-2024. Ministry of Agriculture, Forestry and Fisheries and FIA Fisheries Statistics for 2017.
3. Teh, L, Shon D, Zylich K and Zeller D (2014): Reconstructing Cambodia's marine fisheries catch 1950-2010. The University of British Columbia Working Paper #2014-18.
4. FiA (2018): Assessment report of fishing capacity and IUU in Cambodia's EEZ and high seas.
5. FiA Fishery Statistics for 2016. Fishery Administration of Cambodia, Ministry of Agriculture, Forestry and Fisheries.
6. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
7. អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ឆ្នាំ២០០៤ និងជំរឿនប្រជាជន ឆ្នាំ២០០៨។
8. ផែនទីភូមិសាស្ត្រនយោបាយរបស់កម្ពុជានៅក្នុងអាស៊ីនិងពិភពលោក។
9. វិទ្យាស្ថានសភាកម្ពុជា។